សមាគមអាដហុក
ADHOC

# ផ្លូវរបត់ ?

# សិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាន និងសិទ្ធិធនធានធម្មជាតិនៅកម្ពុជា








បោះពុម្ពដោយ
**សមាគមអាដហុក**

ខែកុម្ភៈ ២០១៣

# ផ្លូវរបត់?

## សិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាន
## និងសិទ្ធិធនធានធម្មជាតិនៅកម្ពុជា

បោះពុម្ពដោយ
**សមាគមអាដហុក**

ខែកុម្ភៈ ២០១៣

# មាតិកា


១ ខ្លឹមសារសង្ខេប

៦ ទិដ្ឋភាពទូទៅ

៨ ១. ក្របខណ្ឌច្បាប់ និងស្ថានភាពជាក់ស្តែង

| | |
|---|---|
| ក. ក្របខណ្ឌច្បាប់កម្ពុជាពាក់ព័ន្ធនឹងសិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាន និងសិទ្ធិធនធានធម្មជាតិ | ៨ |
| ច្បាប់កម្ពុជា | ៨ |
| ច្បាប់អន្តរជាតិ | ៩ |
| សិទ្ធិដែលរងផលប៉ះពាល់ពីការរំលោភបំពានសិទ្ធិដីធ្លីសិទ្ធិលំនៅដ្ឋាននិងសិទ្ធិធនធានធម្មជាតិ | ១១ |
| ខ. ស្ថានភាពជាក់ស្តែង៖ បរាជ័យជាទូទៅក្នុងការអនុវត្តសិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាន និងសិទ្ធិធនធានធម្មជាតិ | ១២ |
| ការទន្ទ្រានយកដីធ្លី | ១២ |
| សម្បទានដីសេដ្ឋកិច្ច | ១២ |
| សម្បទានដីសង្គមកិច្ច | ១៩ |
| វិវាទដីធ្លី | ២១ |
| ការបណ្តេញចេញដោយបង្ខំ | ២២ |
| ធនធានធម្មជាតិ | ២៣ |

២៨ ២. ផលប៉ះពាល់អវិជ្ជមាននិងផលវិបាកផ្សេងៗ

| | |
|---|---|
| ក. អសន្តិសុខនៃការកាន់កាប់ដីធ្លី | ២៨ |
| ខ. ភាពគ្មានដីធ្លី, ភាពក្រីក្រនិងបញ្ហាពាក់ព័ន្ធ | ២៨ |
| គ. ផលប៉ះពាល់អវិជ្ជមានលើជីវភាពរស់នៅ, សន្តិសុខស្បៀងនិងសិទ្ធិវប្បធម៌ | ៣២ |
| ឃ. ផលប៉ះពាល់អវិជ្ជមានលើធនធានធម្មជាតិ | ៣៣ |

៣៥ ៣. ការដោះស្រាយវិវាទ

| | |
|---|---|
| ក. មធ្យោបាយជាធរមានក្នុងការដោះស្រាយវិវាទ | ៣៥ |
| ខ. ស្ថានភាពជាក់ស្តែង៖ ដំណើរការអយុត្តិធម៌, កង្វះឧបាស្រ័យ(Remedies) ប្រកបដោយប្រសិទ្ធិភាពនិងការបៀតបៀនសកម្មជន | ៣៥ |

៤៣ **៤. គំនិតផ្តួចផ្តើមថ្មីៗរបស់រដ្ឋាភិបាល**

ក. ការផ្អាកបណ្តោះអាសន្នជាផ្លូវការក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មីៗ ៤៣

ខ. គម្រោងផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីថ្មីតាមរយៈការកំណត់ព្រំប្រទល់ដីដោយក្រុមយុវជនស្ម័គ្រចិត្ត ៤៤

គ. កិច្ចសហប្រតិបត្តិការជាមួយអង្គការសង្គមស៊ីវិលនិងអង្គការដៃគូ ៤៥

៤៦ **សេចក្តីសន្និដ្ឋាននិងអនុសាសន៍**

អនុសាសន៍ ៤៧

៥០ **ឧបសម្ព័ន្ធ**

១. សម្បទានដីសេដ្ឋកិច្ចក្នុងតំបន់ការពារ ៥០

២. សម្បទានដីសេដ្ឋកិច្ច ដែលបានផ្តល់ក្រោយថ្ងៃទី៧ខែឧសភាឆ្នាំ២០១២ ៥២

# ខ្លឹមសារសង្ខេប

ឆ្នាំ២០១១ ត្រូវបានគេសង្កេតឃើញថា ជាឆ្នាំមានកំណើនដ៏ខ្ពស់នៃចំនួនសម្បទានដីសេដ្ឋកិច្ចផ្តល់ដោយរាជរដ្ឋាភិបាលកម្ពុជាទៅឲ្យក្រុមហ៊ុនឯកជន រីឯឆ្នាំ២០១២វិញ ទំនាស់ដីធ្លីកាន់តែ មានលក្ខណៈស្រួចស្រាវ ហើយការតវ៉ាកាន់តែមានចំនួនកើនឡើង។ រាជរដ្ឋាភិបាល បានបង្ហាញឲ្យ ឃើញថា ខ្លួនបានយល់អំពីភាពធ្ងន់ធ្ងរនៃស្ថានភាព ដោយផ្តើមចេញជាគំនិតផ្តួចផ្តើមផ្សេងៗក្នុង បំណងដោះស្រាយវិវាទដីធ្លី ក្នុងនោះមានការដោះស្រាយបញ្ហាមួយចំនួនពាក់ព័ន្ធនឹងសម្បទានដី សេដ្ឋកិច្ច និងមានការផ្តល់កម្មសិទ្ធិដីធ្លីរាប់ពាន់ៗសន្លឹកដល់គ្រួសារនៅតាមទីជនបទ។ ទោះជាមានការដោះស្រាយ យ៉ាងនេះក្តី ក៏មានការព្រួយបារម្ភដ៏បន្ទាន់នោះ គឺសម្ពាធជាទូទៅលើបញ្ហាដីធ្លី ភាព គ្មានដីធ្លី និងអសន្តិសុខក្នុងការកាន់កាប់ដីធ្លី កង្វះខាតការពង្រឹងការអនុវត្តច្បាប់ ការរំលោភ អំណាច និងការរំលោភលើមធ្យោបាយចិញ្ចឹមជីវិត និងធនធានធម្មជាតិ នៅតែពុំទាន់បានដោះ ស្រាយនៅឡើយ។

## ស្ថានភាពជាក់ស្តែង៖ សម្បទានដីសេដ្ឋកិច្ច សម្បទានដីសង្គមកិច្ច វិវាទដីធ្លី ការបណ្តេញចេញពីលំនៅដ្ឋានដោយបង្ខំ និងធនធានធម្មជាតិ

មកទល់ចុងខែធ្នូ ឆ្នាំ២០១២ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ ឬបម្រុងដីយ៉ាងតិចណាស់ ២,៦៥៧,៤៧០ហិកតាទុកឲ្យក្រុមហ៊ុនឯកជនក្រោមគម្រោងសម្បទានដីសេដ្ឋកិច្ច។ បើប្រៀបធៀប នឹងឆ្នាំ ២០១១ ចំនួននេះមានកំណើន ១៦.៧%។ បើទោះជាមាន សេចក្តីប្រកាសស្តីពីការផ្អាកបណ្តោះអាសន្នលើការផ្តល់សម្បទានដីសេដ្ឋកិច្ចក៏ដោយ ក៏ក្នុងឆ្នាំ២០១២នេះ រាជរដ្ឋាភិបាលបាន ចេញអនុក្រឹត្យចំនួន ៦៦ បម្រុងដីចំនួន ៣៨១,១២១ហិកតា (រាប់បញ្ចូលទាំងដី ១០៨,៥២៤ហិកតា ដែលផ្ទេរចេញពីកម្មសិទ្ធិសាធារណៈរបស់រដ្ឋទៅជាកម្មសិទ្ធិឯកជនរបស់រដ្ឋ) សម្រាប់សម្បទានដី សេដ្ឋកិច្ច។ សម្បទានដែលបានផ្តល់ជូនថ្មីៗ និងការធ្វើចំណាត់ថ្នាក់ដីថ្មីៗ គឺភាគច្រើនប៉ះពាល់លើតំបន់ការពារ។

សម្បទានដីសេដ្ឋកិច្ចជាច្រើនត្រូវបានអនុម័តដោយមានការបំពារបំពានធ្ងន់ធ្ងរលើលក្ខ ខណ្ឌតម្រូវផ្នែកច្បាប់។ ជាទូទៅប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់សម្បទានពុំដឹងឮព័ត៌មានមូល ដ្ឋានអំពីសម្បទាននោះទេ ដែលនេះគូសបញ្ជាក់ អំពីការខកខានជាលក្ខណៈប្រព័ន្ធរបស់ស្ថាប័នពាក់ព័ន្ធដែលមិនបានជូនដំណឹងដល់សាធារណជន អំពីគម្រោងនានា។ បន្ថែមលើនេះទៀត ក្រុមហ៊ុនឯកជនចង់បានដីដែលគួរត្រូវបានការពារជាអាទិភាព ដូចជាតំបន់ការពារ និងដីជនជាតិ ដើមភាគតិចជាដើម។ ជារួម ការត្រួតពិនិត្យលើការងារសម្បទានមានលក្ខណៈទន់ខ្សោយ។

ក្នុងទូទាំងឆ្នាំ២០១២ រាជរដ្ឋាភិបាលបានផ្តល់សម្បទានដីសង្គមកិច្ចចំនួន ៣៨កន្លែង គ្របដណ្តប់លើផ្ទៃដី ១០០,៧៩០ហិកតា ពោលគឺច្រើនជាងពីរដង បើធៀបនឹងទំហំដីដែលបានផ្តល់ឲ្យក្រោមគម្រោងសម្បទានដីសង្គមកិច្ចក្នុងឆ្នាំ២០១១ និង ស្មើមួយភាគបួននៃទំហំដីដែលបានផ្តល់ឲ្យ ក្រោមគម្រោងសម្បទានដីសេដ្ឋកិច្ច ក្នុងឆ្នាំ២០១២។ ត្រង់នេះ អាចចង្អុលបង្ហាញនូវការផ្លាស់ប្តូរវិជ្ជមានមួយក្នុងគោលនយោបាយសម្រាប់សម្បទានដីសង្គមកិច្ចដែលទំហំដី គឺនៅពេលមុនឆ្នាំ ២០១២ នៅមានចំនួនស្តួចស្តើងនៅឡើយ។ ទោះជាយ៉ាងនេះក្តី ក្នុងចំណោមសម្បទានដីសង្គមកិច្ច ដែលទើបបានផ្តល់ឲ្យថ្មីៗទាំង ៣៨កន្លែង មាន១៣កន្លែង កើតមាន នូវ ទំនាស់។ អំពើពុករលួយ ការគ្រប់គ្រងមិនត្រឹមត្រូវ និងការបំពារបំពានធ្ងន់ធ្ងរត្រូវបានគេរាយការណ៍ថា កើតមានឡើងពាក់ ព័ន្ធនឹងសម្បទានដីសង្គមកិច្ច ដែលអាជ្ញាធររដ្ឋខកខានពុំបានស៊ើបអង្កេតឲ្យបានត្រឹមត្រូវ។ បច្ចុប្បន្ននេះមានការព្រួយបារម្ភថា វិធានការដែលត្រូវ អនុវត្តគោលនយោបាយសម្បទានដីសង្គម កិច្ច តាមពិតគឺបានធ្វើឲ្យគ្រួសារងាយរងគ្រោះមានស្ថានភាពអាក្រក់ជាងមុន ធ្វើឲ្យភាពឥតដីធ្លី កាន់តែធ្ងន់ធ្ងរ ជាងមុន និងបង្កឲ្យមានទំនាស់ដីធ្លី។ ប្រជាពលរដ្ឋដែលត្រូវបានបណ្តេញចេញពីលំនៅដ្ឋាន ឬរំលោភបំពានដោយសារតែសម្បទានដីសង្គមកិច្ច គឺត្រូវចាញ់គ្រប់ករណីទាំងអស់ ត្បិតពួកគេត្រូវបានផាត់ចេញពីកម្មវិធីដែលគួរដោះស្រាយការកើតទុក្ខមិនសុខចិត្តរបស់ពួកគេ។

ក្នុងឆ្នាំ២០១២ សមាគមអាដហុកបានទទួលវិវាទដីធ្លីចំនួន ៧០ករណី ប៉ះពាល់ផ្ទៃដីសរុប ចំនួន ១០១,៤០៨ហិកតា និង ១០,៦៨៩គ្រួសារ។ បន្ថែមលើនេះទៀត សមាគមអាដហុកបានបន្តតាមដានវិវាទដីធ្លីចំនួន ៦២ករណីទៀត ដែលមិនទាន់បានដោះស្រាយនៅ

សេសសល់ពីឆ្នាំមុនៗ។ ខេត្តដែលទទួលរងផលប៉ះពាល់ជាងគេ បើ គិតពី ចំនួន និង កម្លាំង នៃវិវាទ ដីធ្លី គឺមាន ខេត្តបាត់ដំបង កំពង់ចាម កំពង់ធំ កោះកុង ក្រចេះ មណ្ឌលគិរី រតនគិរី និងខេត្តសៀមរាប។

សហគមន៍រាប់រយនៅទូទាំងប្រទេសកម្ពុជា បានបង្ហាញអំពីការព្រួយបារម្ភរបស់ពួកគេលើការពិតដែលថា ពួកគេត្រូវបានបដិសេធសិទ្ធិចុះបញ្ជីដីធ្លី ដែលពួកគេបានគ្រប់គ្រងដោយស្របច្បាប់។ ជាផលវិបាក គឺពួកគេត្រូវប្រឈមមុខនឹងការបណ្តេញចេញពីលំនៅដ្ឋាន។ អាជ្ញាធរនៅគ្រប់ ជាន់ថ្នាក់ បានបង្កភាពងាយស្រួលដល់ផលប្រយោជន៍ផ្នែកអាជីវកម្ម ជាជាងការទទួលស្គាល់សិទ្ធិស្របច្បាប់របស់ប្រជាពលរដ្ឋ ដោយហៅអ្នកទាំងនោះថាជា «ពួកអ្នកមកនៅឥតច្បាប់» ឬ «ពួកអ្នកមកថ្មី» និងប្រើប្រាស់រូបភាពអភិវឌ្ឍន៍ដើម្បីបណ្តេញពួកគេចេញដោយខុសច្បាប់ពី លំនៅដ្ឋាន។

ក្នុងករណីភាគច្រើន អាជ្ញាធរខកខានមិនបានអនុវត្តនូវលក្ខខណ្ឌតម្រូវផ្នែកច្បាប់ ពាក់ព័ន្ធនឹងការបណ្តេញចេញពីលំនៅដ្ឋាន និងការតាំងលំនៅដ្ឋានថ្មីនោះទេ។ ការអនុម័តច្បាប់ស្តីពីការបណ្តេញចេញពីលំនៅដ្ឋាន និងគោលនយោបាយលំនៅដ្ឋានថ្នាក់ជាតិពិតជាមានសារៈសំខាន់ ក្នុង ការពង្រឹងនីតិវិធីស្របច្បាប់និង សុវត្ថិភាពនៃការកាន់កាប់។ ច្បាប់ និងគោលនយោបាយនេះ អាចអនុញ្ញាតឲ្យអាជ្ញាធរដាក់ចេញនូវយុទ្ធសាស្ត្រមួយដើម្បីដោះស្រាយបញ្ហាភាពគ្មានដីធ្លី និងការតាំង លំនៅដ្ឋានក្រៅផ្លូវការ និងកំណត់ចេញជាការការពារសិទ្ធិមនុស្សស្របនឹងបទដ្ឋានអន្តរជាតិ។ រហូតមកទល់ថ្ងៃនេះ ការបណ្តេញចេញពីលំនៅដ្ឋានដោយបង្ខំនៅកម្ពុជា នៅតែបន្តកើតឡើងដោយខុសច្បាប់ និងនៅតែជាជម្រើសទីមួយពុំមែនជាជម្រើសចុងក្រោយនោះទេ។

បើទោះជា មានបទប្បញ្ញត្តិផ្នែកបរិស្ថាន និងការផ្អាកបណ្តោះអាសន្នជាផ្លូវការ ស្តីពីការកាប់ ឈើក្តី ក៏ធនធានធម្មជាតិរបស់កម្ពុជាកំពុងបាត់បង់យ៉ាងគំហុក។ មួយចំណែកធំនៃព្រៃឈើត្រូវបានទទួលរងផលប៉ះពាល់ដោយសម្បទានដីនិងការធ្វើអាជីវកម្មខ្នាតតូច និងការកាប់ឈើ។ អ្នកដែល ទទួលការគំរាមកំហែងជាពិសេសនោះ គឺជនជាតិដើមភាគតិច។

ស្ថានភាពដីធ្លីកាន់តែមានលក្ខណៈធ្ងន់ធ្ងរ។ ប្រជាពលរដ្ឋនិងសហគមន៍ កាន់តែយល់ដឹង អំពីសិទ្ធិរបស់ពួកគេ និងកាន់តែទាមទារយុត្តិធម៌និងគណនេយ្យភាព។ ប៉ុន្តែដីនៅតែខ្វះខាតហើយអាជ្ញាធរខកខាន ពុំបានគោរពសិទ្ធិរបស់ពលរដ្ឋ។ ប្រសិនបើបញ្ហាបច្ចុប្បន្ន ពុំត្រូវបានដោះស្រាយជាបញ្ហាអាទិភាពទេនោះស្ថេរភាពសង្គមអាចនឹងរង្គោះរង្គើ។

## ផលប៉ះពាល់អវិជ្ជមាន និងផលវិបាកផ្សេងៗ

ភាគរយដែលកាន់តែកើនឡើងច្រើនជាងធម្មតានៃប្រជាជនកម្ពុជា គឺភាពគ្មានដីធ្លី។ កម្មវិធីផ្តល់កម្មសិទ្ធិដីធ្លីដ៏ជោគជ័យ បានខកខានក្នុងការដោះស្រាយ នូវតម្រូវការរបស់ប្រជាជនកម្ពុជា ដែលត្រូវការជាចាំបាច់ជាងគេនូវសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លីនោះ ជាឧទាហរណ៍ អ្នកទាំងនោះ គឺជាក្រុមអ្នកដែលរស់នៅក្នុងតំបន់តាំងលំនៅដ្ឋានក្រៅផ្លូវការ និងតំបន់មានវិវាទក៏ដូចជា ជនជាតិ ដើមភាគតិចផងដែរ។ ឥឡូវសំណួរសួរថា នៅមានទីណាទៀតដែលប្រទេសកម្ពុជា នឹងរកដីឲ្យបាន គ្រប់គ្រាន់សម្រាប់មនុស្សជំនាន់ក្រោយ ខណៈដែលស្ទើរតែពាក់កណ្តាលនៃដីដែលអាចដាំដុះបានស្ថិតក្នុងដៃសម្បទានិកឯកជនសម្រាប់រយៈពេលរហូតដល់៩៩ឆ្នាំនោះ ?

ការអភិវឌ្ឍន៍កសិឧស្សាហកម្ម និងកំណើនជាប្រចាំនៃផលិតភាពកសិកម្ម គឺអាចដំណើរការទៅបានលុះត្រាណាតែ សម្បទានដីត្រូវទទួលបានការត្រួតពិនិត្យ និងគ្រប់គ្រងឲ្យល្អ។ ប៉ុន្តែការ កាត់បន្ថយភាពក្រីក្រ អាចលឿនជាងនេះ ប្រសិនបើទុកឲ្យមានអ្នកកាន់កាប់ដីកសិកម្មតូចៗ ដោយពង្រឹងសុវត្ថិភាពនៃការកាន់កាប់ដីរបស់គេនោះ។ ការផ្លាស់ប្តូរស្ថានភាពដែលកំពុងពើបប្រទះ ដោយប្រជាជនកម្ពុជាភាគច្រើននៅពេលនេះ (កសិករក្លាយជាកម្មកររកប្រាក់កម្រៃ) មានសណ្ឋាន ដូចនឹងដំណើរការសេដ្ឋកិច្ចនៅអឺរ៉ុប នាសតវត្សរ៍ទី១៩ ពាក់ព័ន្ធនឹងការចាកចោលទីជនបទ និងការផ្លាស់ប្តូរនៃចំណែកដ៏ធំនៃវណ្ណៈកសិករទៅជាកម្មកររកប្រាក់កម្រៃដែលគ្មានដី។ រាជរដ្ឋាភិបាល បានប្រើប្រាស់ចំណាកស្រុកជាសន្ទុះសម្ពាធមួយក្នុងការនាំចេញកម្លាំងពលកម្មដែលគ្មាន

ជំនាញ និងដ៏ថោករបស់កម្ពុជាទៅកាន់ប្រទេសជិតខាង។

សិទ្ធិចិញ្ចឹមជីវិតនិងសិទ្ធិវប្បធម៌របស់ជនជាតិដើមភាគតិច និងក្រុមអ្នកមិនមែនជនជាតិដើម ភាគតិច គឺត្រូវបង់ថ្លៃដ៏ខ្ពស់ចំពោះគោលនយោបាយអភិវឌ្ឍន៍នេះ។ ជាទូទៅសហគមន៍ ពុំត្រូវបានប្រឹក្សាយោបល់មុន នឹងការអនុវត្តគម្រោង និងពុំមានការទាមទារតវ៉ាអ្វីសេសសល់ឡើយនៅចំពោះ មុខព្រឹត្តិន័យនេះ។ ការកាប់ឈើដោយខុសច្បាប់ សម្បទានដី និងគម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗ បន្តជះឥទ្ធិពលអវិជ្ជមានលើធនធានធម្មជាតិ។ ព្រៃចម្បង ដូចជាព្រៃឡង់ កំពុងជួបគ្រោះថ្នាក់ដែលអាចមានផលប៉ះពាល់អវិជ្ជមានយ៉ាងធំធេងលើសត្វព្រៃ និងប្រព័ន្ធជីវៈចម្រុះ។ ជលផលនិងទឹក ក៏ទទួលការគំរាមកំហែងផងដែរដោយសារតែកំណើនការបំពុល និងការធ្វើអាជីវកម្ម។

> ការអនុវត្តនិងគោលនយោបាយបច្ចុប្បន្ន គឺពុំមានចីរភាពទេ។ បច្ចុប្បន្ន គេព្រួយបារម្ភថា តំបន់ការពារ (រួមទាំងព្រៃ និងជម្រកសត្វព្រៃ) កំពុងបាត់បង់យ៉ាងគំហុក និងថាពុំមានដីធ្លីដែលអាចដាំដុះបានច្រើនគ្រប់គ្រាន់នៅសេសសល់សម្រាប់ការងារកសិកម្ម ឬចិញ្ចឹមសត្វនោះទេ។

## ការដោះស្រាយវិវាទ

នៅលើក្រដាសមានមធ្យោបាយដោះស្រាយវិវាទជាច្រើនវិធីដែលពាក់ព័ន្ធនឹងសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាន ក្នុងនោះរួមទាំងការសម្រុះសម្រួល អង្គរដ្ឋបាល និងប្រព័ន្ធតុលាការផង។ ក្នុងការ អនុវត្តជាក់ស្តែងជាញឹកញាប់ស្ថាប័ន និងដំណើរការដោះស្រាយវិវាទផ្លូវការ គឺត្រូវបានទុកមួយ ឡែកសិន ឬពុំដំណើរការសោះតែម្តង។ ជាញឹកញាប់វិវាទចូលដល់ដំណាក់កាលចុងក្រោយ ព្រោះ ថាភាគីដែលទន់ខ្សោយជាងត្រូវបានគំរាមកំហែង បៀតបៀន ឬបង្ខិតបង្ខំឲ្យទទួលយក សំណងពុំសមស្រប។ កត្តាចម្បងដែលជះឥទ្ធិពលលើការដោះស្រាយវិវាទដីធ្លី គឺសកម្មភាពរបស់ភាគីដែលខ្លាំងជាងក្នុងវិវាទ ក្នុងការបំភិតបំភ័យអ្នកទន់ខ្សោយជាងទទួលសិទ្ធិផ្តាច់មុខក្នុងការទទួលបាន ការគាំទ្រពីអាជ្ញាធរសាធារណៈផ្សេងៗ ធ្វើសកម្មភាពដោយនីវទណ្ឌភាព និងប្រើប្រាស់ប្រព័ន្ធតុលាការ។ មនុស្សជាច្រើនខ្វះខាតការទទួលបានឧបាស្រ័យប្រកបដោយប្រសិទ្ធភាព និងពុំជឿជាក់លើតុលាការ ដែលគាំទ្របុគ្គល និងក្រុមហ៊ុនដែលមានខ្សែធំ និងមានទ្រព្យធនជាងប្រជាពល រដ្ឋក្រីក្រ។

ក្នុងឆ្នាំ២០១២ បុគ្គលិកសិទ្ធិមនុស្សបានមើលឃើញការបង្ក្រាបទៅលើការតវ៉ាដោយសន្តិវិធី និងការបៀតបៀនទៅលើសកម្មជនសិទ្ធិលំនៅដ្ឋាននិងសិទ្ធិដីធ្លី។ ក្នុងករណីជាច្រើនការប្រជុំពង្រឹងសហគមន៍រៀបចំដោយអង្គការសង្គមស៊ីវិល ត្រូវបានរារាំងឬរំខាន។ អ្វីដែលកាន់តែគួរឲ្យព្រួយ បារម្ភទៀតនោះ គឺអំពើហិង្សា និងការគំរាមកំហែងប្រើអំពើហិង្សាក៏កាន់តែប្រើប្រាស់ច្រើនឡើងៗ ទៅលើតំណាងសហគមន៍ក៏ដូចជាសកម្មជននិងបុគ្គលិក សិទ្ធិលំនៅដ្ឋាន និងសិទ្ធិដីធ្លី។

បទចោទព្រហ្មទណ្ឌជាទូទៅទាំងបី (ការញុះញង់ ការបរិហារកេរ្តិ៍ និងការផ្តល់ព័ត៌មានខុស) ត្រូវបានប្រើប្រាស់ដើម្បីបំភិតបំភ័យ និងបៀតបៀនអ្នកការពារសិទ្ធិមនុស្ស។ ផ្ទុយទៅនឹងលិខិត និងស្មារតីនៃច្បាប់ព្រហ្មទណ្ឌ តុលាការបានប្រើប្រាស់ការឃុំខ្លួនមុនការជំនុំជម្រះ ជាវិធានច្បាប់មួយ (ពុំមានករណីលើកលែង) និងឃុំខ្លួនមនុស្សដើម្បីបំបាក់ឆន្ទៈរបស់ពួកគេ។ ក្នុងឆ្នាំ២០១២ ប្រជា ពលរដ្ឋ ២៣២នាក់ ត្រូវបានចាប់ខ្លួនពាក់ព័ន្ធនឹងបញ្ហាលំនៅដ្ឋាន និងដីធ្លីពោល គឺកើន១៤៤% បើធៀបនឹងឆ្នាំ២០១១។ ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ប្រជាពលរដ្ឋ ៣៨នាក់កំពុងស្ថិតក្នុងគុកនៅឡើយ និង ៥០នាក់ កំពុងរត់គេចខ្លួន។ រឿងក្តីល្បីៗមួយចំនួនដូចជា ការជំនុំជម្រះលោក ម៉ម សុណង់ដូ និងតំណាងអ្នកបឹងកក់ និងតំណាងអ្នកបុរីកីឡា និងការធ្វើឃាតលើរូបលោក ឈុត វុទ្ធី បណ្តាលឲ្យមានបន្ទុកច្រើនលើការងារសិទ្ធិមនុស្ស។ បច្ចុប្បន្ន ការភ័យខ្លាចគឺមាននៅគ្រប់ទីកន្លែងទាំងអស់ ខណៈដែលប្រព័ន្ធយុត្តិធម៌បានគាំទ្រជាប់លាប់ឡើងទៅលើទស្សនៈ និង បទចោទដែលកាន់តែខ្លាំងដៃឡើងៗរបស់រាជរដ្ឋាភិបាលប្រឆាំងនឹងសកម្មជនដីធ្លីនានា។ ជាលទ្ធផល វាកាន់តែមានគ្រោះថ្នាក់ឡើងៗក្នុងការធ្វើតំណាងឲ្យសហគមន៍ និងក្នុងការការពារសិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាន និងសិទ្ធិធនធានធម្មជាតិរបស់ប្រជាជនកម្ពុជា។

តុលាការកម្ពុជាមានលក្ខណៈខ្លាំងក្លាចំពោះអ្នកខ្សោយ និងទន់ខ្សោយចំពោះអ្នកខ្លាំង។ និរទណ្ឌភាពពាក់ព័ន្ធនឹងការបំពានអំណាច កង្វះខាតការពង្រឹងការអនុវត្តច្បាប់ និងកង្វះខាតឯករាជ្យភាពប្រព័ន្ធតុលាការ ធ្វើឲ្យខូចកេរ្តិ៍ឈ្មោះកម្ពុជា។ អាជ្ញាធរមិនអាចរំពឹងថានឹងដោះស្រាយវិបត្តិដីធ្លីបៀបនេះបានទេ។

## គំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលក្នុងឆ្នាំ២០១២

នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ នាយករដ្ឋមន្ត្រីហ៊ុនសែន បានប្រកាសដាក់ចេញនូវបទ បញ្ជាមួយឲ្យមានការផ្អាកបណ្តោះអាសន្នជាផ្លូវការក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មី និងពង្រឹងអ្វី ដែលហៅថាគោលនយោបាយ "ស្បែកខ្លា"។ បទបញ្ជាលេខ០០១ ក៏អំពាវនាវឲ្យធ្វើការពិនិត្យឡើងវិញនូវរាល់សម្បទានកន្លងមកទាំងអស់ដើម្បីផ្ទៀងផ្ទាត់ការអនុវត្តតាមបទប្បញ្ញត្តិ និងច្បាប់ជាធរមាន។

សមាគមអាដហុកស្វាគមន៍យ៉ាងកក់ក្តៅចំពោះគំនិតផ្តួចផ្តើមដែលកន្លងមក គឺជាគំនិតផ្តួច ផ្តើមដ៏ចាំបាច់។ យ៉ាងណាមិញ មានចន្លោះប្រហោងដ៏សំខាន់ក្នុងការផ្អាកបណ្តោះអាសន្នជាផ្លូវការនេះ។ សម្បទានដីសេដ្ឋកិច្ច ដែលកំពុងស្ថិតក្រោមការពិចារណានៅពេលដែលការផ្អាកបណ្តោះអាសន្នត្រូវបានប្រកាសឡើង គឺត្រូវផាត់ចេញពីការផ្អាកនេះ។ តាមពិតសមាគមអាដហុកបានរក ឃើញថា សម្បទានដីសេដ្ឋកិច្ចចំនួន៣៣ ដែលត្រូវបានផ្តល់ចាប់តាំងពីថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ រាប់បញ្ចូលទាំង ១៣កន្លែងក្នុងខែមិថុនា និង ១០កន្លែងក្នុងខែសីហា (ចាប់តាំងពី ខែកញ្ញា ដល់ ខែធ្នូ ឆ្នាំ២០១២ សម្បទានដីសេដ្ឋកិច្ចតែ៤កន្លែងប៉ុណ្ណោះត្រូវបានផ្តល់)។ ប្រសិនបើ រាជរដ្ឋាភិបាល ពុំបានបើកបង្ហាញព័ត៌មានអំពីចំនួនសម្បទានដីសេដ្ឋកិច្ចពិតប្រាកដ ដែលកំពុងត្រូវ បានរៀបចំដាក់ស្នើនៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ទេនោះ ម្លោះអ្នកអង្កេតការណ៍ឯករាជ្យ អាចនឹងឆ្ងល់អំពីឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយអានុភាពនៃគោលនយោបាយ សម្បទានដីសេដ្ឋកិច្ច។ ការផ្តល់សម្បទានបន្ថែម បើទោះជាមានការផ្អាកបណ្តោះអាសន្នជាផ្លូវការ ហើយនោះនឹងមានន័យថា ការសន្យាដែលធ្វើឡើងជាមួយនឹងក្រុមហ៊ុនឯកជន គឺសំខាន់ជាងការ សន្យាធ្វើឡើងជាមួយប្រជាពលរដ្ឋកម្ពុជា។

នៅថ្ងៃទី១៥ ខែមិថុនា លោកនាយករដ្ឋមន្ត្រីបានប្រកាសអំពីចេតនារបស់គាត់ក្នុងការដាក់ ចេញនូវកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីថ្មីមួយ ដែលនឹងត្រូវអនុវត្តដោយក្រុមយុវជនស្ម័គ្រចិត្ត ជាអ្នក កំណត់ព្រំប្រទល់ដីជូនប្រជាពលរដ្ឋ។ គិតមកត្រឹមថ្ងៃទី២២ ខែធ្នូឆ្នាំ២០១២ ប័ណ្ណកម្មសិទ្ធិដីចំនួន ៧១,២២០សន្លឹក បានប្រគល់ជូនប្រជាពលរដ្ឋ ហើយក្រុមយុវជនស្ម័គ្រចិត្ត បានកំណត់ព្រំប្រទល់ដី ចំនួន ៣៣៣,២៧៥ប្លង់ គ្របដណ្តប់លើផ្ទៃដីប្រមាណ ៤៣៣,៩៨៧ហិកតា។

សមាគមអាដហុក សូមស្វាគមន៍ចំពោះការវិវឌ្ឍនេះ។ ទោះជាយ៉ាងនេះក្តី ដោយសារតែតំបន់មានវិវាទស្ថិតនៅក្រៅផែនការនេះ ប្រជាពលរដ្ឋដែលត្រូវការជាចាំបាច់នូវប័ណ្ណកម្មសិទ្ធិដី នៅតែពុំបានទទួលឡើយ។ ប៉ុន្តែការទទួលស្គាល់សិទ្ធិកាន់កាប់ដីភោគៈ (ស្របតាមច្បាប់ភូមិបាល) គួរតែ ត្រូវបានបញ្ចូលបន្ថែមទៅក្នុងកម្មវិធីនៃការកំណត់ព្រំប្រទល់ដីនេះផង។ បើធ្វើដូចនេះ នោះនឹងពិតជាបានពង្រឹងនូវសុវត្ថិភាពកាន់កាប់ដីធ្លី ដោយដោះស្រាយនូវតម្រូវការជាចាំបាច់របស់ប្រជាពលរដ្ឋដែលរស់នៅក្នុងទីតាំងលំនៅដ្ឋានក្រៅផ្លូវការឬក្នុងតំបន់ ដែលអាចនឹងទទួលផលប៉ះ ពាល់ដោយគម្រោងអភិវឌ្ឍន៍។ ផែនការនេះ ក៏ពុំបានដោះស្រាយស្ថានភាពរបស់សហគមន៍ជន ជាតិដើមផងដែរទេ។ របាយការណ៍ដែលសមាគមអាដហុក ទទួលបានពីការិយាល័យតាមខេត្ត មួយចំនួនរបស់ខ្លួនចង្អុលបង្ហាញថា សមាជិកនៃសហគមន៍ជនជាតិដើមភាគតិចកំពុងទទួលសម្ពាធឲ្យទទួលយកប័ណ្ណកម្មសិទ្ធិដីឯកជនជាជាងប័ណ្ណកម្មសិទ្ធដីសមូហភាព។

គំនិតផ្តួចផ្តើមរបស់អង្គនីតិប្រតិបត្តិដែលមានបំណងផ្តល់ប័ណ្ណកម្មសិទ្ធិដីដល់គ្រួសារនៅ តាមទីជនបទ និងការពារដីពួកគេពីការទន្ទ្រានគឺត្រូវបានទទួលស្វាគមន៍ប៉ុន្តែវាពុំទាន់គ្រប់គ្រាន់នៅឡើយ។ គំនិតផ្តួចផ្តើមទាំងនេះពុំបំពេញតាមតម្រូវការរបស់

ប្រជាពលរដ្ឋនិងសហគមន៍ ដែលត្រូវការប័ណ្ណកម្មសិទ្ធិដីជាចាំបាច់ឡើយ។ ជាមួយនឹងជំនួយផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសអន្តរជាតិដ៏សំខាន់ រាជរដ្ឋាភិបាលនឹងពុំមានលេសអ្វីនោះទេ ប្រសិនបើខ្លួនពុំដោះស្រាយរឿងកើតទុក្ខមិនសុខ ចិត្តរបស់អ្នកដែលត្រូវការជាចាំបាច់នូវសន្តិសុខនៃការកាន់កាប់ដីធ្លីនោះ។

ឆ្នាំ២០១២ អាចជាផ្លូវរបត់សម្រាប់សិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាននៅកម្ពុជា។ គំនិតផ្តួចផ្តើមថ្មីៗរបស់រាជរដ្ឋាភិបាលបណ្តាលឲ្យមានការទទួលស្គាល់ថា មានអ្វីម្យ៉ាងខុសឆ្គង និងថាវិបត្តិដីធ្លីបានចាប់ផ្តើមគំរាមកំហែងស្ថេរភាពរបស់ប្រទេស។ ក្នុងប៉ុន្មានឆ្នាំខាងមុខនេះ កំណើនភាគរយនៃទំនាស់ដីធ្លី ហាក់នឹងកើតមានដោយការទន្ទ្រានយកដីទាំងនៅទីក្រុង និងទីជនបទ។ បច្ចុប្បន្ន សម្បទានដីសេដ្ឋកិច្ចគ្របដណ្តប់លើភាគរយដ៏ធំធេងនៃដីដាំដុះរបស់កម្ពុជា ហើយរាជរដ្ឋាភិបាលនឹងពុំអាចបន្តផ្តល់សម្បទានច្រើនដូចប៉ុន្មានឆ្នាំចុងក្រោយឡើយ។ ទោះជាយ៉ាងនេះក្តី សម្បទានដីសេដ្ឋកិច្ចអាចត្រូវបានយកពីតំបន់ការពារ ដីកោះ ឬសម្បទានដែលបានលុបចោល ប៉ុន្តែវិវាទតិចតួចទំនងនឹងកើតឡើងពាក់ព័ន្ធករណីនេះ។ ផ្ទុយទៅវិញវិវាទ ពាក់ព័ន្ធនឹងការទន្ទ្រានយកដី គឺទំនងជានៅមានបន្តដោយសារតែសេចក្តីលោភលន់ និងនិទណ្ឌភាព។

បច្ចុប្បន្ន អ្វីដែលត្រូវការជាចាំបាច់ជាងគេ បន្ថែមលើការពង្រឹងនីតិរដ្ឋ និងការពិនិត្យឡើងវិញនូវគោលនយោបាយអភិវឌ្ឍន៍ គឺការទទួលស្គាល់ថាការអភិវឌ្ឍរបស់កម្ពុជាពុំមានបទប្បញ្ញត្តិអ្វីឡើយ។ ផលប្រយោជន៍អ្នកខ្លាំង ត្រូវបានបែងចែកពុំសមាមាត្រគ្នា សោះពីការចាត់ចែងដីធ្លី និងគោលនយោបាយដីធ្លី ខណៈដែលប្រជាពលរដ្ឋទន់ខ្សោយ និងសហគមន៍ជាក្រុមដែលត្រូវបានគេ ផាត់ចេញ ក៏ដូចជាធនធានធម្មជាតិរបស់ប្រទេសទាំងមូល ជាអ្នកទទួលរងនូវបន្ទុកនៃការ ផ្លាស់ប្តូរ។

រាជរដ្ឋាភិបាល ពុំមានភាពផ្តាច់មុខលើអត្ថន័យនៃការអភិវឌ្ឍទេ។ សំឡេងរិះគន់ចាំបាច់ត្រូវបានអនុញ្ញាតឲ្យលើកឡើងនូវការព្រួយបារម្ភអំពីគម្រោងអភិវឌ្ឍន៍ និងអានុភាពអវិជ្ជមានរបស់វាលើប្រជាពលរដ្ឋដែលក្រីក្រនិងទន់ខ្សោយ។ ជម្រើសផ្សេងៗ ដែលអាចអនុវត្តទៅបានមានដូចជា ការជួយដល់កសិករដែលកាន់កាប់ដីតូចៗ។ បើពុំមានយុទ្ធសាស្ត្រទូលំទូលាយមួយ ក្នុងការដោះ ស្រាយ បញ្ហាវចនាសម្ព័ន្ធ ដូចជាការផាត់ចេញ អយុត្តិធម៌ និងការបំពានអំណាច ពាក់ព័ន្ធនឹងដីធ្លី និងលំនៅដ្ឋាន នោះគំនិតផ្តួចផ្តើមបណ្តោះអាសន្នរបស់រាជរដ្ឋាភិបាល នឹងគ្រាន់តែអាចដោះស្រាយបញ្ហាសម្រាប់រយៈពេលខ្លីប៉ុណ្ណោះ។ ជំហានទីមួយដែលត្រូវបំពេញបង្គ្រប់ដោយជំហានទីពីរ (ដែលកាន់តែពិបាកជាង)គឺ៖ ពង្រឹងការអនុវត្តច្បាប់ជាធរមាន និងពង្រឹងសុវត្ថិភាពនៃការកាន់កាប់ សម្រាប់ប្រជាពលរដ្ឋទាំងអស់គ្នាពោល គឺពុំមែនសម្រាប់តែអ្នកដែលរស់នៅក្នុងតំបន់គ្មានវិវាទនោះទេ។ បច្ចុប្បន្ន រាជរដ្ឋាភិបាល គួរតែធ្វើការជ្រើសរើសមួយដ៏ច្បាស់លាស់។



*ដីធ្លីត្រូវបានកាប់ឆ្ការសម្រាប់ការធ្វើអាជីវកម្មកសិឧស្សាហកម្មនៅជិតទីក្រុងបានលុង ខេត្តរតនគិរី*

# ទិដ្ឋភាពទូទៅ

ឆ្នាំ២០១២ បានគូសបញ្ជាក់ថា បញ្ហា និងវិវាទពាក់ព័ន្ធនឹងសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាន ក៏ដូចជាការទន្ទ្រានលើធនធានធម្មជាតិ គឺជាការព្រួយបារម្ភចម្បង។ យ៉ាងណាមិញ ដោយហេតុថា ឆ្នាំ២០១១ គេសង្កេតឃើញថា មានកំណើនយ៉ាងខ្ពស់នៃចំនួនសម្បទានដីសេដ្ឋកិច្ច ផ្តល់ដោយរាជរដ្ឋាភិបាលកម្ពុជាទៅឲ្យក្រុមហ៊ុនឯកជន ធ្វើឲ្យទំនាស់ក្នុងឆ្នាំ២០១២ កាន់តែមានលក្ខណៈស្រួចស្រាវ ហើយការតវ៉ាកាន់តែមានចំនួនច្រើនឡើង។ រាជរដ្ឋាភិបាលបង្ហាញឲ្យឃើញថា ខ្លួនបានយល់អំពីភាពធ្ងន់ធ្ងរនៃស្ថានភាព ដោយផ្តើមចេញជាគំនិតផ្តួចផ្តើមផ្សេងៗក្នុងបំណងដោះស្រាយវិវាទ ដីធ្លីក្នុងនោះមានដោះស្រាយបញ្ហាមួយចំនួនពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីដល់គ្រួសារនៅតាមទីជនបទរាប់ពាន់ពាន់សន្លឹក។ ទោះជាមានការដោះស្រាយយ៉ាងនេះ ក្តីក៏ការព្រួយបារម្ភដ៏បន្ទាន់នោះ គឺសម្ពាធជាទូទៅលើបញ្ហាដីធ្លី ភាពគ្មានដីធ្លី និងអសន្តិសុខក្នុងការ កាន់កាប់ដីធ្លី កង្វះខាតការពង្រឹងការអនុវត្តច្បាប់ ការបំពានអំណាច និងការរំលោភបំពានលើ មធ្យោបាយចិញ្ចឹមជីវិត និងធនធានធម្មជាតិនៅតែមិនទាន់បានដោះស្រាយនៅឡើយ។ បន្ថែមពី លើនេះទៀតឆ្នាំ២០១២ បុគ្គលិកសិទ្ធិមនុស្សបានមើលឃើញថា មានការបង្ក្រាបទៅលើសកម្មជនសិទ្ធិលំនៅដ្ឋាន និងសិទ្ធិដីធ្លី ដែលមិនធ្លាប់កើតមានពីមុនមក ហើយបានបំផ្លាញកេរ្តិ៍ឈ្មោះរបស់ ប្រទេសកម្ពុជា ផងដែរ។

រាជរដ្ឋាភិបាល បន្តលើកកម្ពស់ការធ្វើអាជីវកម្មកសិឧស្សាហកម្ម ក្រោមទម្រង់នៃការជួលដី ខ្នាតធំធ្វើជាយុទ្ធសាស្រ្តអភិវឌ្ឍន៍ចម្បងរបស់ខ្លួន។ ប៉ុន្តែចំពោះសម្បទានដីសេដ្ឋកិច្ច និងប្រភេទ សម្បទានផ្សេងៗទៀត អត្ថប្រយោជន៍ពិតរបស់វា គឺរួមមានប្រាក់ចំណូលបន្ថែមសម្រាប់រដ្ឋ និងការ ងារសម្រាប់ប្រជាពលរដ្ឋ ការវិនិយោគផ្ទាល់ពីបរទេស កំណើនសមត្ថភាពនាំចេញ និងការពង្រឹងផលិតភាពក្នុងវិស័យកសិកម្ម។ ទោះជាយ៉ាងនេះក្តី វាបានបង្កប់ក្រោមគោលនយោបាយសម្បទាន ដីសេដ្ឋកិច្ច (ថាមានដីធ្លីសំបូរបែបសម្រាប់ធ្វើអាជីវកម្ម) គឺលែងពិតប្រាកដឡើយ។ ផ្ទុយទៅវិញ ការព្រួយបារម្ភដ៏បន្ទាន់ គឺសម្ពាធលើបញ្ហាដីធ្លី និងមធ្យោបាយចិញ្ចឹមជីវិត កាន់តែមានលក្ខណៈខ្លាំងក្លាឡើងៗ ដែលមិនអាចនឹងធ្វើមិនអើពើទៀតបានទេ។ ដូចគ្នានេះដែរ ការរំលោភបំពានលើសិទ្ធិ លំនៅដ្ឋានក្នុងតំបន់នៅទីក្រុង និងសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច ក៏កាន់តែមានលក្ខណៈធ្ងន់ ធ្ងរ ផងដែរ។

របាយការណ៍នេះ មានបំណងនឹងអធិប្បាយអនុលោមតាមទស្សនវិស័យអភិវឌ្ឍន៍ និងសិទ្ធិ មនុស្ស ដើម្បីឲ្យមានលក្ខណៈទូលំទូលាយ ពាក់ព័ន្ធនឹងបញ្ហាសម្បទានសេដ្ឋកិច្ច វិវាទដីធ្លី ការបណ្តេញចេញពីលំនៅដ្ឋាន ដោយបង្ខំ និងការទន្ទ្រានលើធនធានធម្មជាតិ។ ទោះជាយ៉ាងនេះក្តី ឧស្សាហកម្មរុករកធនធានរ៉ែ គឺស្ថិតនៅក្រៅវិសាលភាពរបាយការណ៍នេះ។ គំហើញ និងការវិភាគនានា គឺផ្អែកទៅលើទិន្នន័យជាផ្លូវការដែលយើងទទួលបាន និងសកម្មភាពស៊ើបអង្កេតផ្ទាល់របស់ សមាគមអាដហុក។ ដំបូងរបាយការណ៍នេះ បំភ្លឺអំពីគម្លាតរវាងក្របខណ្ឌច្បាប់កម្ពុជា និងស្ថាន ភាពជាក់ស្តែង ពាក់ព័ន្ធនឹងសិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាន និងសិទ្ធិធនធានធម្មជាតិ។ របាយការណ៍នេះចង់សង្កត់ធ្ងន់ថាគម្លាតនេះ គឺពិតជាសំខាន់ខ្លាំងណាស់ដោយសារតែខកខានមិនធ្វើរបស់អាជ្ញាធរកម្ពុជាក្នុងការអនុវត្តន៍ច្បាប់។ ទីពីរ របាយការណ៍ធ្វើការវិភាគ អំពីផលវិបាកនៃការរំលោភបំពានសិទ្ធិពាក់ព័ន្ធនឹងអសន្តិសុខក្នុងការកាន់កាប់ដីធ្លី ភាពគ្មានដីធ្លី ភាពក្រីក្រ មធ្យោបាយចិញ្ចឹមជីវិត និងបញ្ហាពាក់ព័ន្ធ។ ទីបី របាយការណ៍ពិនិត្យទៅលើដំណើរការដំណោះស្រាយវិវាទ និងស្ថាប័ន និងការអនុវត្តន៍។ របាយការណ៍នេះ ក៏សង្កត់ធ្ងន់ផងដែរទៅលើកំណើននៃការបង្ក្រាបទៅលើសកម្មជនសិទ្ធិ

ដីធ្លី និងលំនៅដ្ឋាន។ ជាចុងក្រោយរបាយការណ៍នេះ ផ្តល់ជាការវិភាគបឋមស្តីពីគំនិតផ្តួចផ្តើម ដែលដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ២០១២។ របាយការណ៍នេះបានដាក់ជូននូវ អនុសាសន៍ពិស្តារដល់រាជរដ្ឋាភិបាល សហគ្រាសអាជីវកម្ម និងដៃគូអភិវឌ្ឍន៍របស់កម្ពុជា។



*បាតុករកំពុងបិទផ្លូវជាតិលេខ៧ក្នុងស្រុកស្នួល ខេត្តក្រចេះ*

# ១. ក្របខណ្ឌច្បាប់ និងស្ថានភាពជាក់ស្តែង

## ក. ក្របខណ្ឌច្បាប់កម្ពុជាពាក់ព័ន្ធសិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាន និងសិទ្ធិធនធានធម្មជាតិ

### ច្បាប់កម្ពុជា

នៅក្នុងជំពូក៣នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា បានចែងអំពីសិទ្ធិជាមូលដ្ឋាន និងសេរីភាពក្នុងនោះ រួមមានសិទ្ធិមានកម្មសិទ្ធិឯកជន និងសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។ និងនៅក្នុង មាត្រា៣១នៃច្បាប់ដដែលនេះ ក៏បានដាក់បញ្ចូលបន្ថែមនូវបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ នៅក្នុងច្បាប់កម្ពុជា។ ហេតុនេះតុលាការនៅកម្ពុជា អាចអនុវត្តដោយផ្ទាល់បទប្បញ្ញត្តិអន្តរជាតិនេះ ដូចបាន គូសបញ្ជាក់ក្នុងសេចក្តីសម្រេចដ៏សំខាន់របស់ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ លេខ០៩២ /០០៣ /២០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧)។ អនុលោមតាមមាត្រា៤៤នៃច្បាប់រដ្ឋធម្មនុញ្ញ "ការដកហូត កម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឲ្យធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុន ដោយសមរម្យ និងយុត្តិធម៌"។

ពាក់ព័ន្ធដីធ្លីនៅពេលនៃការអនុម័តច្បាប់ភូមិបាលឆ្នាំ២០០១ ត្រូវបានចាត់ទុកថា ជាច្បាប់ មួយដ៏គួរឲ្យទុកចិត្តបាន។ ច្បាប់នេះ បានកំណត់នូវរបបកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀតនៃកម្មសិទ្ធិ ព្រមទាំង កំណត់បញ្ជាក់នូវប្រភេទកម្មសិទ្ធិទាំងពីរប្រភេទរបស់រដ្ឋ គឺទ្រព្យសម្បត្តិសាធារណៈ និងទ្រព្យ សម្បត្តិឯកជនរបស់រដ្ឋ។ ហើយច្បាប់នះ ក៏បានចង្អុលបង្ហាញនីតិវិធីសម្រាប់ការធ្វើចំណាត់ថ្នាក់ឡើងវិញ[១]។ ច្បាប់នេះក៏បង្កើតផងដែរនូវក្របខណ្ឌគតិយុត្តិមួយសម្រាប់ការចេញប័ណ្ណកម្មសិទ្ធិការប្រើប្រាស់ និងការគ្រប់គ្រង (ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់)។ ហើយច្បាប់នេះ ក៏អនុញ្ញាតឲ្យផ្តល់សម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច និងបានកំណត់អំពីលក្ខខណ្ឌ និងនីតិវិធី ដែលត្រូវបានបង្កើតក្នុងអនុក្រឹត្យជាក់លាក់ ដូចជាអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច (ឆ្នាំ២០០៥) និង ឆ្នាំ២០០៣ អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច។ សម្បទានដីសេដ្ឋកិច្ច ត្រូវបានប្រើប្រាស់សម្រាប់ការធ្វើអាជីវកម្មកសិឧស្សាហកម្មដី និងបានកំណត់ទំហំផ្ទៃដីជាអតិបរមាត្រឹមតែ ១០,០០០ហិកតាសម្រាប់ការចេញលិខិតសម្បទានដីមួយកន្លែងឲ្យបុគ្គលម្នាក់ (ទោះជា បានកំណត់យ៉ាងនេះក្តី គឺមានករណីលើកលែងក្នុងការអនុវត្តជាក់ស្តែង) និងរយៈពេលនៃសម្បទាន បានកំណត់ជាអតិបរិមាត្រឹមតែ ៩៩ឆ្នាំ។ ប៉ុន្តែប្រសិនបើសម្បទានិកខកខានពុំបានធ្វើ អាជីវកម្មតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់ និងកិច្ចសន្យានោះទេ រាជរដ្ឋាភិបាលនឹងចេញលិខិតដកហូត ឬមោឃៈភាពកិច្ចសន្យាសម្បទាននោះ។ អាជ្ញាធរមានសមត្ថកិច្ចក្នុងការផ្តល់សម្បទានសេដ្ឋ កិច្ច គឺក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(MAFF) ប៉ុន្តែក្រសួងនានា និងទីភ្នាក់ងាររដ្ឋផ្សេង ដ៏ទៃទៀត ក៏មានសមត្ថកិច្ចទទួលខុសត្រូវក្នុងកិច្ចការនេះផងដែរ។ នីតិវិធីក្នុងការផ្តល់សម្បទានដី រួមមានពាក់ព័ន្ធនឹង ការធ្វើចំណាត់ថ្នាក់ដីទ្រព្យសម្បត្តិឯកជនរដ្ឋ ការអនុម័តផែនការប្រើប្រាស់ដី ការបំពេញនូវការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម(SEIA) ការប្រឹក្សាយោបល់ជា សាធារណៈជាមួយប្រជាពលរដ្ឋ និងសហគមន៍ ដែលប៉ះពាល់ដោយគម្រោង រួមទាំងការផ្តល់នូវដំណោះស្រាយតាំងលំនៅដ្ឋានថ្មី និងការផ្តល់នូវសំណងគ្រប់គ្រាន់ឲ្យដល់ក្រុមសហគមន៍រងគ្រោះ គម្រោងទាំងឡាយនោះ។ ប៉ុន្តែគោលដៅនៃសម្បទានដីសង្គមកិច្ចវិញ គឺផ្តល់ឲ្យក្រុមគ្រួសារគ្មាន ដីធ្លី និងក្រីក្រ ឬដល់អតីតយុទ្ធជន និងក្រុមគ្រួសាររបស់ពួកគេ ស្របទៅតាមនីតិវិធីជាក់លាក់ដែលបានប្បញ្ញត្តិ ដែលក្នុងនោះរាប់បញ្ចូលទាំង ការប្រឹក្សាយោបល់ជាមួយនឹងសហគមន៍ពាក់ព័ន្ធ ផងដែរ។

រហូតមកទល់នឹងបច្ចុប្បន្ននេះ កម្ពុជា នៅពុំទាន់បានអនុម័តលើគោលនយោបាយលំនៅ ដ្ឋានថ្នាក់ជាតិ ឬច្បាប់ស្តីពីការបណ្តេញចេញពីលំនៅដ្ឋាននៅឡើយ។

១ នីតិវិធីសម្រាប់ការធ្វើចំណាត់ថ្នាក់ឡើងវិញគឺចែងយ៉ាងច្បាស់តាមរយៈច្បាប់ជាក់លាក់មួយដែលពុំទាន់បាន អនុម័តនៅឡើយ។ បច្ចុប្បន្នការអនុវត្តគឺធ្វើឡើងស្របនឹងរាជក្រឹត្យនិងអនុក្រឹត្យ ដែលចែងអំពីលក្ខណវិនិច្ឆ័យ និងលក្ខខណ្ឌសម្រាប់ផ្ទេរដីសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។

សេចក្តីព្រាងស្តីពីគោល នយោបាយនេះ បានដាក់ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងខែវិច្ឆិកា ឆ្នាំ២០១២ ដោយឡែកពុំទាន់ មានសេចក្តីព្រាងច្បាប់ស្តីពីការបណ្តេញចេញពីលំនៅដ្ឋាននៅឡើយទេ ប៉ុន្តែ បញ្ហាពាក់ព័ន្ធនឹងការ បណ្តេញចេញ អាចប្រើប្រាស់ច្បាប់ផ្សេង និងលិខិតបទដ្ឋានគតិយុត្តិដែលបានចែងអំពីដំណើរការ នីតិវិធី និងការការពារផ្នែកច្បាប់។ បន្ថែមលើនេះទៀតឋានៈកម្ពុជា ក្នុងនាមជាភាគីមួយនៃលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ (សូមមើលខាងក្រោម) តម្រូវធ្វើឲ្យកម្ពុជាមានកាតព្វកិច្ចអនុវត្តនូវបទដ្ឋាន និងបទប្បញ្ញត្តិអន្តរជាតិពាក់ព័ន្ធនឹងការបណ្តេញចេញពីលំនៅដ្ឋាន និងការតាំងលំនៅដ្ឋានថ្មី។ ដីសំណើមធនធានធម្មជាតិរបស់កម្ពុជា ត្រូវបានការពារដោយច្បាប់មួយចំនួន។ ច្បាប់ស្តីពីតំបន់ការពារ ឆ្នាំ២០០៨ កំណត់ប្រភេទតំបន់ការពារមួយចំនួនពោលគឺ ឧទ្យានជាតិ ដែនជម្រកសត្វព្រៃ តំបន់ការពារទេសភាព តំបន់រ៉ាមសារ តំបន់ស្នូលនៃឋបនីយជីវមណ្ឌល តំបន់ឧទ្យានជាតិ សមុទ្រ តំបន់បេតិកភណ្ឌធម្មជាតិ និងតំបន់ប្រើប្រាស់ច្រើនយ៉ាងក៏ដូចជា ប្រព័ន្ធបែងចែកតំបន់។ តំបន់ការពារ ត្រូវបានបែងចែកជាបួនតំបន់គ្រង់គ្រង៖ តំបន់ «ស្នូល» តំបន់ «អភិរក្ស» តំបន់ «ប្រើប្រាស់ដោយចីរភាព» និងតំបន់ «សហគមន៍»។ ប្រភេទតំបន់ពីរដំបូង ត្រូវបានការពារទាំងស្រុងពីការទន្ទ្រាន ខណៈដែលប្រភេទតំបន់ពីរផ្សេងទៀត អាចឃើញមានការអភិវឌ្ឍឬការកសាងហេដ្ឋារចនាសម្ព័ន្ធខ្លះៗដោយមានការអនុម័តពីរាជរដ្ឋាភិបាល។ ការកែសម្រួលតំបន់ការពារ ឬព្រំប្រទល់របស់វាចាំបាច់ត្រូវអនុវត្តតាមនីតិវិធីច្បាប់និងអនុក្រឹត្យ។ ច្បាប់ព្រៃឈើ ឆ្នាំ២០០២កំណត់ក្របខណ្ឌសម្រាប់ការគ្រប់គ្រងការវិនិយោគ ការប្រើប្រាស់ ការអភិវឌ្ឍ និងការអភិរក្សព្រៃឈើ[២]។ បទប្បញ្ញត្តិ និងមានច្បាប់ផ្សេងៗទៀតដែលការពារផលផល មធ្យោបាយចិញ្ចឹមជីវិត និងធនធានធម្មជាតិផងដែរ គឺតាមរយៈលក្ខខណ្ឌតម្រូវ ក្នុងការអនុវត្តការសិក្សាវាយតម្លៃហេតុប៉ះ ពាល់បរិស្ថាន មុននឹងចាប់ផ្តើមអនុវត្តន៍គម្រោង ឬសកម្មភាពអភិវឌ្ឍន៍ធំៗ។ ជាសំខាន់កិច្ចខិតខំ ប្រឹងប្រែងទាំងនេះ គឺមានគោលបំណងអភិរក្ស និង/ឬការប្រើប្រាស់ប្រកបដោយចីរភាព។

## ច្បាប់អន្តរជាតិ

ច្បាប់សិទ្ធិមនុស្សអន្តរ ជាតិ ការពារសិទ្ធិទទួលបានលំនៅដ្ឋានគ្រប់គ្រាន់ និងហាមប្រាមការ បណ្តេញចេញពីលំនៅដ្ឋានដោយបង្ខំ ក៏ដូចជា ការទន្ទ្រានលើធនធានចិញ្ចឹមជីវិតដោយគ្មានការ ធានាអំពីដំណើរការនីតិវិធី និងការការពារផ្នែកច្បាប់។ សិទ្ធិទទួលបានលំនៅដ្ឋានគ្រប់គ្រាន់ គឺជា ធាតុផ្សំមួយនៃសិទ្ធិរបស់មនុស្សគ្រប់រូប ក្នុងការទទួលបានជីវភាពគ្រប់គ្រាន់ដែលក្នុងនោះ រួមមាន «ម្ហូបអាហារ, សម្លៀកបំពាក់ និងលំនៅដ្ឋានគ្រប់គ្រាន់ និង [...] ការធ្វើឲ្យស្ថានភាពរស់នៅប្រសើរឡើងជាបន្តបន្ទាប់» (កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ICESCR) មាត្រា១១(១)។ ក្នុងនាមជាភាគីមួយនៃកតិកាសញ្ញា ICESCR កម្ពុជា គឺមានកាតព្វកិច្ចអនុវត្តសិទ្ធិនេះ[៣]។ ដូច្នេះកម្ពុជា មានកាតព្វកិច្ចផ្នែកច្បាប់ ក្នុង «ការផ្តល់នូវសុវត្ថិភាពផ្នែកច្បាប់នៃការកាន់កាប់

២ គោលបំណងរបស់វា គឺដើម្បីធានានូវ "ការគ្រប់គ្រងប្រកបដោយចីរភាព" នៃព្រៃឈើទាំងនេះ "សម្រាប់អត្ថប្រយោជន៍បរិស្ថានសេដ្ឋកិច្ចនិងសង្គមរបស់វា"(មាត្រា១)។ ច្បាប់អនុញ្ញាតឲ្យបង្កើតសម្បទានព្រៃឈើហើយសម្បទានទាំងនេះអាចត្រូវបានដកហូត ឬលុបចោលវិញបានដោយរដ្ឋាភិបាល។ សហគមន៍អាចនឹងទទួលបានចំណែកមួយនៃព្រៃឈើជា "ព្រៃសហគមន៍" ដើម្បីគ្រប់គ្រងនិងប្រើប្រាស់ធនធានព្រៃឈើតាមមធ្យោបាយប្រកបដោយចីរភាព។

៣ សិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ គឺត្រូវបានទទួលស្គាល់ជាដំបូងក្នុង(មាត្រា២៥(១))នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សឆ្នាំ១៩៤៨។ សិទ្ធិទទួលបានលំនៅដ្ឋានគ្រប់គ្រាន់ក៏បង្ហាញច្បាស់លាស់ដែរក្នុងលិខិតុបករណ៍អន្តរជាតិដទៃទៀតដែលធានានូវសិទ្ធិមានជីវិតគ្រួសារឯកជនឬសិទ្ធិកាន់កាប់ប្រកបដោយសន្តិវិធី។ បច្ចុប្បន្នវាក្លាយជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

ដល់អ្នកទាំងនោះនិងគ្រួសារ ដែលកំពុងខ្វះខាតការការពារបែបនេះ"[៤] និងត្រូវអនុម័តយុទ្ធសាស្ត្រលំនៅដ្ឋានថ្នាក់ជាតិមួយ ដែលកំណត់គោលដៅ កំណត់ធនធានដែលមាន និងដាក់ ចេញការទទួលខុសត្រូវ និងក្របខណ្ឌពេលវេលាសម្រាប់ការអនុវត្តយុទ្ធសាស្ត្រនេះ[៥]។ ភាពគ្រប់ គ្រាន់នៃលំនៅដ្ឋានគឺកំណត់ដោយយោងលើលក្ខណវិនិច្ឆ័យប្រាំពីរក្នុងនោះរួមមានសុវត្ថិភាពនៃការកាន់កាប់ អត្ថិភាពនៃសេវាកម្ម សម្ភារៈនិងហេដ្ឋារចនាសម្ព័ន្ធ ភាពអាចរស់នៅបាន ភាពគ្រប់គ្រាន់ផ្នែកវប្បធម៌ និងទីតាំង[៦]។ បន្ថែមលើនេះទៀត កម្ពុជា ចាំបាច់ត្រូវប្រកាន់យកវិធាន ការប្រឆាំងការរើសអើង ដើម្បីលុបបំបាត់ការរើសអើងក្នុងបរិបទនៃលំនៅដ្ឋាន។ គួរកត់សម្គាល់ ដែរថា ខណៈដែល ទិដ្ឋភាពមួយចំនួននៃសិទ្ធិត្រូវបានបំពេញជាបន្តបន្ទាប់ (ខណៈវាពឹងផ្អែកទៅលើអត្ថិភាពនៃធនធានហិរញ្ញវត្ថុ[៧]) កាតព្វកិច្ចទាក់ទិននឹងការមិនរើសអើង គឺជាអានុភាពអនុវត្តភ្លាមៗ។ ភាពស្ថិតក្រោមការអភិវឌ្ឍន៍ ពុំបង្កឲ្យមានការរើសអើងទេទាក់ទិននឹងលំនៅដ្ឋាន។

អនុសាឲ្យនៃសិទ្ធិទទួលបានលំនៅដ្ឋានគ្រប់គ្រាន់ គឺការហាមប្រាមនូវការបណ្តេញចេញពីលំនៅដ្ឋានដោយបង្ខំ។ ពាក្យដែលយើងយកមកប្រើប្រាស់ក្នុងរបាយការណ៍នេះសំដៅទៅលើ "ការដកហូតបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ប្រឆាំងនឹងឆន្ទៈរបស់បុគ្គល គ្រួសារនិង/ឬសហគមន៍ពីផ្ទះសម្បែង និង/ឬដីធ្លីដែលពួកគេកាន់កាប់ដោយគ្មានការផ្តល់ និងការទទួលបានទម្រង់ដ៏សមស្របនៃការការពារផ្លូវច្បាប់ឬការការពារផ្សេងៗទៀត"[៨]។ ដូច្នេះ មិនមែនរាល់ការបណ្តេញចេញពីលំនៅ ដ្ឋាន សុទ្ធតែចាត់ទុកថាជា "ដោយបង្ខំ" (ឧ. ខុសច្បាប់)នោះទេ ទោះបើជា ការបណ្តេញចេញពីលំនៅដ្ឋានទាំងនោះ ត្រូវបានអនុវត្តដោយកម្លាំងកាយក្តី។ មានតែការបណ្តេញចេញពីលំនៅដ្ឋាន ដែលអនុវត្ត *ដោយគ្មាន* ដំណើរការត្រឹមត្រូវប៉ុណ្ណោះដែលខុសច្បាប់។ ដូច្នេះក្រុមអ្នកដែលត្រូវបានបណ្តេញចេញពីផ្ទះចាំបាច់ យ៉ាងហោចណាស់ទទួលបានការប្រឹក្សាយោបល់អំពីគម្រោង មុននឹងអនុវត្តគម្រោងនោះ ទទួលបានការប្រឹក្សាយោបល់អំពីដំណោះស្រាយតាំងលំនៅដ្ឋានថ្មី និង មានសិទ្ធិជំទាស់នឹងសេចក្តីសម្រេចរដ្ឋបាល និងតុលាការ ពាក់ព័ន្ធនឹងការបណ្តេញចេញរបស់ពួកគេ។ ជម្រើសផ្សេងដែលអាចអនុវត្តទៅបាន ត្រូវតែរុករក និងប្រសិនបើ ការបណ្តេញចេញពី លំនៅដ្ឋានទាំងនោះ ត្រូវបានបញ្ជាស្របទៅតាមច្បាប់ ដោយមានការជូនដំណឹងគ្រប់គ្រាន់ចាំបាច់ត្រូវបានផ្តល់ឲ្យ និងស្របតាមគោលការណ៍ជាទូទៅនៃភាពសមហេតុផល និងគោលការណ៍ សមាមាត្រចាំបាច់ត្រូវតែទទួលបាន។ ពាក់ព័ន្ធនឹងបញ្ហានេះ សិទ្ធិទទួលបានការជំនុំជម្រះដោយ យុត្តិធម៌ គឺជារឿងដ៏សំខាន់។

យ៉ាងណាមិញ មធ្យោបាយចិញ្ចឹមជីវិត និងធនធានធម្មជាតិ ត្រូវបានការពារដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិ(ដោយពុំបាច់គិតដល់ច្បាប់បរិស្ថានអន្តរជាតិ) ត្បិតវាសំខាន់ក្នុងការទទួល បានសិទ្ធិដូចជា សិទ្ធិទទួលបានម្ហូបអាហារគ្រប់គ្រាន់ និងសិទ្ធិទទួលបានទឹក ដែលទាំងនេះ

---

៤ គណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកលើសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌, មតិយោបល់ទូទៅលេខ.៤៖ សិទ្ធិទទួលបានលំនៅដ្ឋានគ្រប់គ្រាន់ (មាត្រា១១(១)) ចុះថ្ងៃទី១៣ខែធ្នូឆ្នាំ១៩៩១កថាខណ្ឌ៨(ក)។

៥ ដូចឯកសារខាងលើកថាខណ្ឌ១២។

៦ ដូចឯកសារខាងលើកថាខណ្ឌ៨។

៧ មាត្រា២(១)នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច, សង្គមកិច្ចនិងវប្បធម៌ចែងថារដ្ឋភាគីនីមួយៗនៃកតិកាសញ្ញានេះ "ដោយការប្រឹងប្រែងរបស់ខ្លួនឯងផ្ទាល់និងតាមរយៈជំនួយ និងសហប្រតិបត្តិការអន្តរជាតិ[...] ប្រើប្រាស់ជាអតិបរមានូវធនធានដែលខ្លួនមានសម្រាប់ការធ្វើឲ្យមានការរីកចម្រើនជាលំដាប់នូវការសម្រេចបានដោយពេញលេញនូវសិទ្ធិទាំងអស់ដែលទទួលបានក្នុងកតិកាសញ្ញានេះ"។

៨ គណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកលើសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌, មតិយោបល់ទូទៅលេខ.៧៖ សិទ្ធិទទួលបានលំនៅដ្ឋានគ្រប់គ្រាន់ (មាត្រា១១(១)) ការបណ្តេញចេញដោយបង្ខំ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៧ កថាខណ្ឌ៣។

៩ ដូចឯកសារខាងលើកថាខណ្ឌ១៣-១៥។

គឺជាចំណែកនៃសិទ្ធិទទួលបានជីវភាពគ្រប់គ្រាន់[១០]។ ពង្រឹងការទទួលបាន និងការប្រើប្រាស់ប្រកប ដោយចីរភាពនូវធនធានធម្មជាតិគឺ សំខាន់ដល់អត្ថិភាពនៃម្ហូបអាហារគ្រប់គ្រាន់[១១]។ ដូច្នេះ រដ្ឋចាំបាច់ ត្រូវទប់ស្កាត់ពីសកម្មភាពដែលបង្ការសិទ្ធិទទួលបានម្ហូបអាហារគ្រប់គ្រាន់ ក៏ដូចជាត្រូវការ ពារសិទ្ធិទទួលបាននេះ និងចាត់វិធានការវិជ្ជមាន ដើម្បីពង្រឹងសុវត្ថិភាពស្បៀងអាហារ ((“គោរព, ការពារនិងបំពេញ”)។ ឧទាហរណ៍ រដ្ឋត្រូវទប់ស្កាត់ពីការបំផ្លិតបំផ្លាញដំណាំ ឬធនធានធម្មជាតិ នៅពេលណាដែលការបំផ្លិចបំផ្លាញនេះមានផលប៉ះពាល់នៃការដកហូតសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានអាហារឬទឹកគ្រប់គ្រាន់[១២]។ កម្ពុជា មានកាតព្វកិច្ចគោរព ការពារ និងបំពេញនូវសិទ្ធិដូចបានរៀបរាប់ខាងលើ ត្បិត កម្ពុជា ពុំត្រឹមតែជាភាគីមួយនៃសន្ធិសញ្ញា និងកត្តិកាសញ្ញាសិទ្ធិមនុស្សអន្តរជាតិប៉ុណ្ណោះទេ តែកម្ពុជា ថែមទាំងបានដាក់បញ្ចូលនូវបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិទាំងនេះទៅក្នុងច្បាប់ជាតិរបស់ខ្លួនផងដែរ។

## សិទ្ធិដែលរងផលប៉ះពាល់ពីការរំលោភបំពានសិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាន និង សិទ្ធិធនធានធម្មជាតិ

នៅពេលដែលសិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាន និងសិទ្ធិធនធានធម្មជាតិ ត្រូវបានបដិសេធមិន ប្រគល់ជូនប្រជាពលរដ្ឋនោះ បណ្តុំនៃសេរីភាព និងសិទ្ធិផ្សេងៗទៀតជាច្រើន អាចត្រូវបានប៉ះពាល់ជាអវិជ្ជមាន។ នេះនឹងពិតជាក្លាយជាករណីបែបនេះ ប្រសិនបើក្រុមអ្នកដែលទទួលរងផលប៉ះពាល់ ត្រូវបានគេឲ្យស្ថិតក្នុងស្ថានភាពគ្មានផ្ទះសម្បែង ទទួលបានសំណងតិចតួច ឬប្រសិនបើទីតាំង លំនៅដ្ឋានថ្មីមានលក្ខណៈ ពុំគ្រប់គ្រាន់ ដាច់ស្រយាល ឬខ្វះខាតសេវាកម្មសាធារណៈ ជាមូលដ្ឋាន[១៣]។

ផ្ទុយទៅវិញ ការទទួលបានសិទ្ធិមួយចំនួនអាចធ្វើឲ្យប្រែប្រួលដល់សិទ្ធិដីធ្លី និងសិទ្ធិលំនៅ ដ្ឋាន។ សិទ្ធិបញ្ចេញមតិដោយសេរី សិទ្ធិជួបប្រជុំគ្នា និងសិទ្ធិបង្កើតសមាគម ប្រសិនបើត្រូវបាន បដិសេធ អាចបង្ការប្រជាពលរដ្ឋ និងសហគមន៍ ពីការទទួលបានសិទ្ធិទទួលបានលំនៅដ្ឋានគ្រប់គ្រាន់។ តាមពិតការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពលំនៅដ្ឋាន គោលនយោបាយ និងការអនុវត្ត (រួមទាំង

---

១០ ដូចអ្នករាយការណ៍ពិសេសទទួលបន្ទុកផ្នែកសិទ្ធិទទួលបានស្បៀងអាហាររបស់អង្គការសហប្រជាជាតិថ្លែងថា “ប្រជាពលរដ្ឋក្រីក្រនៅតាមទីជនបទរងគ្រោះពីគ្រោះឥតឃ្លានព្រោះតែពួកគេខ្វះខាតសិទ្ធិទទួលបានធនធានដូចជាដីធ្លី, ពុំមានសន្តិសុខក្នុងការកាន់កាប់និងទទួលរងគ្រោះពីកិច្ចសន្យាបែងចែកដំណាំមិនយុត្តិធម៌ [...]” (របាយការណ៍លើកទី៣របស់អ្នករាយការណ៍ពិសេសJean Zieglerទទួលបន្ទុកផ្នែកសិទ្ធិទទួលបានស្បៀងអាហារ UN Doc. E/CN.៤/២០០៣/៥៤,ចុះថ្ងៃទី១០ខែមករាឆ្នាំ២០០៣កថាខណ្ឌ១៦)។

១១ ស្បៀងអាហារគ្រប់គ្រាន់ត្រូវតែ“ពុំមានសារធាតុមិនល្អ ឌ. មានសុវត្ថិភាព” គណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកលើសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌,មតិយោបល់ទូទៅលេខ.១២៖ សិទ្ធិទទួលបានស្បៀងអាហារគ្រប់គ្រាន់ (មាត្រា១១) ចុះថ្ងៃទី១២ខែឧសភាឆ្នាំ១៩៩៩កថាខណ្ឌ៨។

១២ រដ្ឋចាំបាច់ត្រូវធានាថាសកម្មភាពរបស់សហគ្រាសអាជីវកម្មពុំបង្ការប្រជាពលរដ្ឋពីសិទ្ធិទទួលបានស្បៀងអាហារគ្រប់គ្រាន់ឬទឹក។ សូមមើលឯកសារខាងលើកថាខណ្ឌ២៧និងគណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកលើសិទ្ធិវប្បធម៌, សង្គមនិងសេដ្ឋកិច្ចមតិយោបល់ទូទៅលេខ.១៥៖សិទ្ធិទទួលបានទឹកគ្រប់គ្រាន់ (មាត្រា១១នឹង១២) ចុះថ្ងៃទី២០ខែមករាឆ្នាំ២០០៣។

១៣ ឧទាហរណ៍សិទ្ធិកុមារក្នុងការទទួលបានការអប់រំអាចត្រូវបានបំពារបំពាន ប្រសិនបើពុំមានសាលារៀននៅជិតទីតាំងលំនៅដ្ឋានទេ។ ប្រសិនបើទីតាំងដែលត្រូវផ្លាស់ទីលំនៅវាកខ្វក់អាចនឹងមានថយចុះនៃអាយុកាលមធ្យមនិងកំណើនជំងឺប៉ះពាល់ដល់សិទ្ធិមានសុខភាពល្អ។ ដូចគ្នាដែរសិទ្ធិក្នុងការធ្វើការងារអាចត្រូវបានបដិសេធព្រោះតែភាពគ្មានផ្ទះសម្បែងឬការតាំងលំនៅដ្ឋានថ្មីដែលស្ថិតនៅឆ្ងាយពីកន្លែងមានការងារធ្វើ។ សិទ្ធិទទួលបានឯកជនភាពនិងសន្តិសុខផ្ទាល់ខ្លួនអាចនឹងត្រូវបានប៉ះពាល់ផងដែរ។ ចុងក្រោយសិទ្ធិវប្បធម៌អាចនឹងត្រូវបានបំពារបំពាន ប្រសិនបើលំនៅដ្ឋានគឺជាផ្នែកដ៏សំខាន់នៃអត្តសញ្ញាណនិងប្រពៃណីរបស់ពលរដ្ឋ (នេះជារឿងពិត ពិសេសសម្រាប់ជនជាតិដើមភាគតិច)។

ការអនុវត្ត និងបទប្បញ្ញត្តិប្រឆាំងការរើសអើង) គឺពាក់ព័ន្ធយ៉ាងជិតស្និទ្ធនឹងសកម្មភាពសមូហភាព និងការតស៊ូមតិជាសាធារណៈ។ ដូចគ្នាផងដែរ សេរីភាពនៃការផ្លាស់ទីលំនៅ គឺសំខាន់ណាស់ចំពោះលទ្ធភាព និងការសម្រេចចិត្តពាក់ព័ន្ធនឹងលំនៅដ្ឋាន។ ដូច្នេះសិទ្ធិ គឺមានលក្ខណៈត្របាញ់គ្នា និងមានអន្តរកម្មគ្នាទៅវិញទៅមក។ ការអនុវត្ត និងគោលនយោបាយរបស់កម្ពុជា គឺត្រូវបានកម្រិតផ្នែកច្បាប់ដោយក្របខណ្ឌផ្នែកច្បាប់ដ៏ទូលំទូលាយមួយ។ ជាពិសេសដូចបានលើកឡើងខាងលើ កម្ពុជា មានកាតព្វកិច្ចអភិវឌ្ឍគោលនយោបាយលំនៅដ្ឋានថ្នាក់ជាតិ មួយ និងត្រូវអនុវត្តក្របខណ្ឌផ្នែកច្បាប់សមស្រប ដែលរាប់បញ្ចូលទាំងការធានានូវដំណើរការត្រឹមត្រូវ ការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងឧបាស្រ័យប្រកបដោយប្រសិទ្ធភាព។ កម្ពុជាក៏គួរតែអនុម័តតាមសំណើរបស់ស្ថាប័នអង្គការសហប្រជាជាតិមួយចំនួននូវច្បាប់ស្តីពីការបណ្តេញ ចេញពីលំនៅដ្ឋានស្របទៅតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

## ខ. ស្ថានភាពជាក់ស្តែង៖ ការខកខានជាទូទៅក្នុងការអនុវត្តសិទ្ធិពាក់ព័ន្ធដីធ្លី  សិទ្ធិលំនៅដ្ឋាននិងសិទ្ធិធនធានធម្មជាតិ

### ការទន្ទ្រានយកដី

បើពិចារណាទៅលើការសិក្សាឆ្លងប្រទេស[១៤] និងបរិបទកម្ពុជា យើងកំណត់ «ការទន្ទ្រានយកដី» ជាការដកហូតដីធ្លី ជាលទ្ធផលនៃការដណ្តើមពីសំណាក់តួអង្គដែលមានអំណាច គឺទាំងអ្នកមានអំណាចកម្ពុជា ឬជនបរទេស។ ការទន្ទ្រានយកដី មានន័យថា ការដណ្តើមយកអំណាចក្នុងការគ្រប់គ្រង និងប្រើប្រាស់ដី ដើម្បីទទួលបានអត្ថប្រយោជន៍ពីដីនោះ។ បញ្ហានេះ ពាក់ព័ន្ធ ដ៏សំខាន់នឹងអតុល្យភាពអំណាច(សេដ្ឋកិច្ច នយោបាយ ច្បាប់) ហើយជាលទ្ធផលបណ្តាលឲ្យមាន ការប្រមូលផ្តុំដីធ្លី ភាពគ្មានដីធ្លី អសន្តិសុខស្បៀង ការតាំងលំនៅដ្ឋានថ្មីក្រោមបទដ្ឋាន និងសំណងតិចតួចដល់ជនរងគ្រោះ។ ជាទូទៅ បញ្ហានេះអនុវត្តទៅដោយគ្មានដំណើរការត្រឹមត្រូវ និងជាការបំពារបំពានទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ ជាញឹកញាប់ជនរងគ្រោះ គឺជាកសិករដែលកាន់កាប់លើដីតូចៗ។

នៅកម្ពុជា ការទន្ទ្រានយកដីមានច្រើនរូបភាព។ វាពាក់ព័ន្ធទាំងការជួលដីខ្នាតធំ (សម្បទាន ដីសេដ្ឋកិច្ច) និងសកម្មភាពនៃអាជ្ញាធរមូលដ្ឋាន អង្គភាពយោធា អាជីវករ និងម្ចាស់ដីឯកជន។ ដើម្បីភាពងាយស្រួល និងការអនុវត្តគម្រោងក្នុងការងារប្រចាំថ្ងៃរបស់ខ្លួន សមាគមអាដហុក ប្រើប្រាស់ពាក្យ «ការទន្ទ្រានយកដី» យ៉ាងប្រុងប្រយ័ត្ន ដើម្បីសំដៅទៅលើវិវាទដីឯកជនទាក់ទិននឹងការទន្ទ្រានយកដីពីសំណាក់ភាគីមួយដែលមានអំណាចខ្លាំងជាងទៅលើ ភាគីម្ខាងទៀតនៅទីជនបទ និងតំបន់ចន្លោះទីប្រជុំជន និងទីជនបទ។ សមាគមអាដហុក ស៊ើបអង្កេត និងធ្វើរបាយការណ៍អំពីករណីពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ច សម្បទានដីសង្គមកិច្ច និងការបណ្តេញចេញពីលំនៅ ដ្ឋានដោយបង្ខំ ដាច់ដោយឡែកពីគ្នា។ របាយការណ៍នេះ អនុវត្តតាមការធ្វើចំណាត់ថ្នាក់នេះ។ ទោះជាយ៉ាងនេះក្តី «ការទន្ទ្រានយកដី» ជាបាតុភូតមួយ ដែលអាចពាក់ព័ន្ធនឹងចំណាត់ថ្នាក់ទាំងបួន ព្រោះថាបញ្ហានៃអសន្តិសុខនៃការកាន់កាប់ដី កង្វះខាតនៃការពង្រឹងការអនុវត្តច្បាប់ និងកង្វះខាតនៃឧបាស្រ័យប្រកបដោយប្រសិទ្ធភាព គឺជាដើមហេតុនៃគ្រប់បញ្ហាទាំងអស់។

### សម្បទានដីសេដ្ឋកិច្ច

ត្រឹមចុងខែធ្នូឆ្នាំ២០១២ រាជរដ្ឋាភិបាលបានបម្រុងឬផ្តល់ដីយ៉ាងតិចណាស់២,៦៥៧,៤៧០ហិកតាឲ្យក្រុមហ៊ុន

១៤ សូមមើល Borras, Franco, Gomez, Kay និង Spoor (ឆ្នាំ២០១២) "ការទន្ទ្រានដីនៅអាមេរិកឡាទីននិងសមុទ្រការ៉ាអ៊ីប" Journal of Peasant Studies, ៣៩ (៣-៤): (៨៤៥-៨៧២); Borrasនិង Franco (២០១០), "ឆ្ពោះទៅរកទស្សនៈកាន់តែទូលំទូលាយអំពីនយោបាយនៃការទន្ទ្រានយកដីជាសកលៈពិចារណាឡើងវិញអំពីបញ្ហាដីធ្លី, រៀបចំការតស៊ូឡើងវិញ" ទីក្រុងឡាអេះវិទ្យាស្ថានអន្តរជាតិសម្រាប់ការសិក្សាសង្គម (ISS), ឯកសារស្រាវជ្រាវICAS ស៊េរីលេខ. ១។ Zoomers (២០១០), "Globalisation and the Foreignisation of Space: ដំណើរការប្រាំពីរបណ្តាលឲ្យមានការទន្ទ្រានយកដីបច្ចុប្បន្ន" The Journal of Peasant Studies, ៣៧(២)៖៤២៩-៤៤៧សម្ព័ន្ធដីធ្លីអន្តរជាតិ(http://www.landcoalition.org)

ឯកជនក្រោយគម្រោងសម្បទានដីសេដ្ឋកិច្ច។ នេះតំណាងឲ្យកំណើន១៦.៧% ពីឆ្នាំ២០១១[១៥]។ ផ្ទៃដីសរុបនៃសម្បទានដីអាចនឹងខ្ពស់ជាងនេះត្បិតក្រសួងផ្សេងៗទៀតក៏មានសិទ្ធិផ្តល់ប្រភេទសម្បទានខុសៗគ្នាដែរ( សម្បទានរ៉ែ, តំបន់សេដ្ឋកិច្ចពិសេស ...) និងចុះហត្ថលេខារួមគ្នាលើកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច។ រាជរដ្ឋាភិបាលពុំបង្ហាញព័ត៌មានស្តីពីសម្បទានដីសេដ្ឋកិច្ចទាំងអស់ដែលធ្វើឲ្យលំបាកកត់ត្រាករណីមួយចំនួន និង ចាត់វិធានការ ផ្លូវច្បាប់។ ដូច្នេះ សមាគមអាដហុកបាន ផ្តោតលើ សម្បទាន ដែល ខ្លួន បាន ប្រមូលបាន ព័ត៌មាន ជាមូលដ្ឋាន ពិសេស គឺ អនុក្រឹត្យ។ តែក្នុងឆ្នាំ២០១២ប៉ុណ្ណោះ រាជរដ្ឋាភិបាល បានចេញ អនុក្រឹត្យ ចំនួន៦៦បម្រុង ទុក ដីប្រមាណ៣៨១,១២១ហិកតាសម្រាប់សម្បទានដីសេដ្ឋកិច្ច រាប់បញ្ចូល ទាំង សម្បទាន ដី សេដ្ឋកិច្ច៣៣កន្លែង បន្ទាប់ពីការប្រកាសនូវការផ្អាកបណ្តោះអាសន្នជាផ្លូវការស្តីពីការផ្តល់ សម្បទាន ដី សេដ្ឋកិច្ច( ថ្ងៃទី៧ខែឧសភា ឆ្នាំ២០១២ )។ យ៉ាងហោចណាស់ក្រុមហ៊ុន៤០ទទួលបានសម្បទានដីសេដ្ឋកិច្ច ប៉ុន្តែ ក្នុង អនុក្រឹត្យ ចំនួន២៦ច្បាប់ ពុំបាន បញ្ជាក់ អំពី ឈ្មោះ ក្រុមហ៊ុនឬ គ្រាន់តែដាក់ជាដីដែលត្រូវបានធ្វើចំណាត់ថ្នាក់ថ្មីថាជាដីឯកជនរដ្ឋហើយធ្វើឲ្យការផ្តល់សម្បទានដីសេដ្ឋកិច្ចដំណើរការទៅបាន។ ទន្ទឹមគ្នានោះដែរចំនួនមិនបានកំណត់ច្បាស់លាស់នៃសម្បទានដីសេដ្ឋកិច្ចត្រូវបានលុបចោលឬកាត់បន្ថយទំហំ[១៦]។

សម្បទាន ដែល ត្រូវ បានផ្តល់ ឲ្យថ្មីៗនិង ការធ្វើចំណាត់ថ្នាក់ថ្មីៗភាគច្រើនប៉ះពាល់លើតំបន់ការពារ។ តាមពិតក្នុងចំណោមផ្ទៃដី៣៨១,១២១ហិកតាដែលទើបទទួលរងប៉ះពាល់ថ្មីៗយ៉ាងហោចណាស់២៧២,៥៩៧ហិកតា (ឬ៧១.៥%) ត្រូវបានផ្តល់ឲ្យឬធ្វើចំណាត់ថ្នាក់ឡើងវិញក្នុងតំបន់ការពារ រាប់បញ្ចូលទាំង ឧទ្យានជាតិគីរីរម្យ ដែនជម្រកសត្វព្រៃលំផាត់ ដែនជម្រកសត្វព្រៃ គូលេនព្រហ្មទេពនិងដែនជម្រកសត្វព្រៃភ្នំព្រិច ( សូមមើលឧបសម្ព័ន្ធ )។ នេះធ្វើតាមរយៈរាជក្រឹត្យដោយកាត់ដីចេញពីតំបន់ការពារឬតាមរយៈអនុក្រឹត្យ ដោយផ្តល់សម្បទានក្នុងតំបន់ការពារដែលមានស្រាប់។ បន្ថែមលើនេះទៀតចាប់ពីឆ្នាំ២០០៨-២០១០ រាជរដ្ឋាភិបាលបានធ្វើចំណាត់ថ្នាក់ឡើងវិញដីចំនួន១៨,៩៥១ហិកតាជាទ្រព្យសម្បត្តិឯកជនរដ្ឋលើកោះចំនួន២៨ នៅឆ្ងាយពីឆ្នេរកម្ពុជា (រួមមាន កោះកុង, កោះរុង, កោះរុងសន្លឹម, កោះតាគៀវ, កោះតាង, កោះថ្មី និង កោះទន្សាយ ) និង បានផ្តល់កោះ ទាំងនោះ ឲ្យសម្បទានិកសម្រាប់រយៈពេលរហូតដល់៩៩ឆ្នាំ។ គម្រោងរួមមានរមនីយដ្ឋានទេសចរណ៍ និង កាស៊ីណូ។ អនុក្រឹត្យពាក់ព័ន្ធទើបតែបានបង្ហាញក្នុងឆ្នាំ២០១២នេះ។

ត្រឹមដើមខែមករាឆ្នាំ២០១៣ចំណុច «សម្បទានដីសេដ្ឋកិច្ច» នៅលើគេហទំព័ររបស់ក្រសួងកសិកម្ម, រុក្ខាប្រមាញ់ និងនេសាទ( http://www.elc.maff.gov.kh/en/ ) ពុំមានបង្ហាញឯកសារអ្វីឡើយ។ នៅថ្ងៃទី១៥ខែមករាឆ្នាំ២០១៣គេហទំព័រនេះត្រូវបានវាយលុក។ ទិន្នន័យ ជា ផ្លូវការ ដែល បានបោះពុម្ពក្នុងខែមីនាឆ្នាំ២០១២បង្ហាញថា ត្រឹមពេលនោះ មានតែ៩០ក្រុមហ៊ុនប៉ុណ្ណោះដែល ទទួលបាន សម្បទាន ដីសេដ្ឋកិច្ចគឺគ្របដណ្តប់លើផ្ទៃដី១,០៩៦,០៣៦ហិកតា។ ដូចបានសង្កេតរួចហើយកាលពីឆ្នាំទៅមិញយើងបានជួបប្រទះនូវការលំបាកក្នុងការបម្រូលព័ត៌មាននិងផ្ទៀងផ្ទាត់ព័ត៌មានអំពីសម្បទានដីសេដ្ឋកិច្ចដោយសារពុំមានស្ថាប័នណាមួយទទួលបន្ទុកប្រមូលទុកទិន្នន័យទាំងនេះ ជាទិដ្ឋភាពអន្តរក្រសួងឬបូកផ្សំគ្នាឡើយ។ ទោះជាយ៉ាងនេះក្តីគំហើញរបស់សមាគមអាដហុក គឺ ផ្អែកទៅលើ ព័ត៌មាន ដែល ទទួលបាន តាមរយៈព័ត៌មាន ផ្លូវការ និង ការបោះពុម្ពផ្សាយ( អនុក្រឹត្យ )ដែលអាចនឹងផ្ទៀងផ្ទាត់បាន។ ដូចអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាបានសង្កត់ធ្ងន់ថាទិន្នន័យជាផ្លូវការបង្ហាញនៅលើគេហទំព័រ

១៥ ត្រឹមចុងឆ្នាំ២០១១រដ្ឋាភិបាលបានផ្តល់ដី២,២៧៦,៣៤៩ហិកតាឲ្យក្រុមហ៊ុន២២៥តាមរយៈសម្បទានដីសេដ្ឋកិច្ច។ សូមមើលរបាយការណ៍ស្តីពីសិទ្ធិ ដីធ្លីនិង សិទ្ធិលំនៅដ្ឋានឆ្នាំ២០១១របស់អង្គការអាដហុក(ខែមីនាឆ្នាំ២០១២) ទំព័រ៩។

១៦ វាអាច ទៅរួចដែលថាមួយចំនួន នៅពុំទាន់អនុវត្តនៅឡើយ(ឧ.កិច្ចសន្យា សម្បទានដីសេដ្ឋកិច្ចនៅពុំទាន់ចុះហត្ថលេខា) ហើយសម្បទានដីសេដ្ឋកិច្ចមួយចំនួនត្រូវបានលុបចោលនិងផ្តល់ជាថ្មីឲ្យសម្បទានិកថ្មី។

របស់ក្រសួងកសិកម្ម, រុក្ខាប្រមាញ់និងនេសាទគឺនៅឆ្ងាយពីស្ថានភាពជាក់ស្តែង[១៧]។ អង្គការសង្គមស៊ីវិលផ្សេងៗទៀត[១៨] ថែមទាំងធ្វើរបាយការណ៍អំពីចំនួនសម្បទានខ្ពស់ជាងនេះ។ នៅកម្រិតណាក៏ដោយនេះបង្ហាញអំពីកង្វះខាតតម្លាភាពជុំវិញការអនុវត្តនូវគម្រោងសម្បទានដីសេដ្ឋកិច្ច។ ដោយសារតែគោលនយោបាយសម្បទានដីសេដ្ឋកិច្ចគឺជាយុទ្ធសាស្ត្រដ៏សំខាន់របស់រាជរដ្ឋាភិបាលវាគួរតែមានតម្លាភាពពេញលេញអំពីការអនុវត្តគោលនយោបាយនេះ។ ហើយក៏គួរមានការវាយតម្លៃអំពីប្រសិទ្ធភាពរបស់គម្រោងនេះពាក់ព័ន្ធនឹងកំណើននិងការកាត់បន្ថយភាពក្រីក្រក៏ដូចជាការវាយតម្លៃអំពីផលប៉ះពាល់សង្គមនិងមនុស្សរបស់គម្រោងផងដែរ។ បន្ថែមលើនេះទៀតបញ្ហាមួយចំនួននៅតែបន្តបង្កឲ្យមានការព្រួយបារម្ភទាំងពីទិដ្ឋភាពអភិវឌ្ឍន៍និងទិដ្ឋភាពសិទ្ធិមនុស្ស។

ដំបូងត្រឹមថ្ងៃនេះនៅពុំទាន់មានការចុះបញ្ជីការធ្វើចំណាត់ថ្នាក់ដីជាសាធារណៈនៅឡើយ ឧ. ព័ត៌មានអំពីការកំណត់ព្រំប្រទល់រវាងដីរដ្ឋសាធារណៈនិងដីឯកជនរដ្ឋនិងតំបន់ជាក់ស្តែង។ នេះគឺជាករណី បើទោះជាមានសំណើច្រំដែលៗពីដៃគូអភិវឌ្ឍន៍ផ្តល់ជំនួយផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុក្នុងវិស័យដីធ្លីរបស់កម្ពុជាក្តី។ ជាលទ្ធផលរាជរដ្ឋាភិបាលអាចនឹងងាយស្រួលក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ចទៅឲ្យក្រុមហ៊ុនឯកជននៅលើដីរដ្ឋសាធារណៈ និងធ្វើចំណាត់ថ្នាក់ឡើងវិញជា ដីរដ្ឋឯកជនក្នុងពេលតែមួយដោយបំពានទៅលើលក្ខណវិនិច្ឆ័យ និងនីតិវិធីនៃការធ្វើចំណាត់ថ្នាក់ឡើងវិញ[១៩]។ សមាគមអាដហុកបានរកឃើញថាក្នុងឆ្នាំ២០១២ រាជរដ្ឋាភិបាលបានអនុម័តអនុក្រឹត្យចំនួន១៩ដោយផ្ទេរផ្ទៃដី១០៨,៥២៤ហិកតាពីទ្រព្យសម្បត្តិរដ្ឋសាធារណៈទៅជាទ្រព្យសម្បត្តិរដ្ឋឯកជន។ អាជ្ញាធរខកខានពុំបានពន្យល់អំពីករណីនេះឡើយនិងគោលបំណងនៃការប្រើប្រាស់ដី។ ទោះជាយ៉ាងនេះក្តីការធ្វើចំណាត់ថ្នាក់ដីឡើងវិញគឺជាជំហានចុងក្រោយ មុននឹងផ្តល់សម្បទានដីសេដ្ឋកិច្ចទៅឲ្យក្រុមហ៊ុនឯកជន។ ដីនេះគឺទំនងជាបម្រុងទុកសម្រាប់សម្បទានដីសេដ្ឋកិច្ច។

ទីពីរ បទប្បញ្ញត្តិពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ចអាចមិនត្រូវបានអនុវត្ត។ សម្បទានជាច្រើនត្រូវបានអនុម័តបើទោះជាមានការបំពានធ្ងន់ធ្ងរលើលក្ខខណ្ឌតម្រូវផ្នែកច្បាប់និងក្នុងអនុក្រឹត្យក្តី។ ពាក់ព័ន្ធនឹងទំហំនិងកម្មសិទ្ធិសម្បទានដីសេដ្ឋកិច្ចមួយចំនួនមានទំហំលើស១០,០០០-ហិកតាសម្រាប់មួយម្ចាស់។ អាជីវករនិងមន្ត្រីមានអំណាចបានទទួលអត្ថប្រយោជន៍ពីសម្បទានច្រើនតាមរយៈក្រុមហ៊ុនដែលពួកគេ (ឬសាច់ញាតិគេ) មានចំណែកឬមានមុខតំណែងក្នុងថ្នាក់ដឹកនាំក្រុមហ៊ុន។ នេះគឺជាការបំពានលើមាត្រា៥៩នៃច្បាប់ភូមិបាល។ បន្ថែមលើនេះទៀតវាក៏ពិបាកនឹងជឿថាករណីលើកលែងពាក់ព័ន្ធនឹងទំហំដូចកម្រិតក្នុងច្បាប់[២០] គួសបញ្ជាក់អំពីអត្ថិភាពនៃសម្បទាន ដែលមានទំហំរាប់ម៉ឺន

---

១៧ របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានការណ៍សិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា Surya P. Subediច្បាប់បន្ថែមះការវិភាគសិទ្ធិមនុស្សលើវិស័យសេដ្ឋកិច្ចនិងសម្បទានដីផ្សេងៗទៀតនៅកម្ពុជា(UN Doc. A/HRC/២១/៦៣/Add.១/Rev.១,កថាខណ្ឌ៨២និង៨៣: "ព័ត៌មាន ដែលផ្តល់ជូន[នៅលើគេហទំព័ររបស់ក្រសួងកសិកម្ម], រាប់បញ្ចូលទាំងប្រវត្តិក្រុមហ៊ុនមិនត្រូវបានធ្វើបច្ចុប្បន្នភាពទៀងទាត់ទេហើយទិន្នន័យពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ចមិនពេញលេញ. [...] បញ្ជីនោះពុំរាប់បញ្ចូលចំនួនដ៏ត្រឹមត្រូវនៃសម្បទានកសិកម្ម ដែលមានឡើយក្នុងករណីខ្លះគឺសម្រាប់ច្រើនឆ្នាំ")។

១៨ ការអភិវឌ្ឍបើកចំហរកម្ពុជានិងអង្គការលីកាដូដោះស្រាយជាមួយសម្បទានរ៉ែបន្ថែមលើសម្បទានដីសេដ្ឋកិច្ច។

១៩ សំខាន់ជាងនេះទៀតនោះដើម្បីត្រូវផ្ទេរទៅជាទ្រព្យសម្បត្តិរដ្ឋឯកជនដីរដ្ឋសាធារណៈមួយប្លង់ត្រូវតែបាត់បង់តម្លៃផលប្រយោជន៍សាធារណៈរបស់វាសិន។

២០ មាត្រា៥៩នៃច្បាប់ភូមិបាលចែងថា "សម្បទានដីដែលសម្រេចហើយហើយមានទំហំលើសពីទំហំកំណត់ខាងលើជាកម្មវត្ថុនៃការកាត់បន្ថយ។ ប៉ុន្តែប្រសិនបើ ការកាត់បន្ថយនេះមានឥទ្ធិពលធ្វើឲ្យខូចប្រយោជន៍អាជីវកម្មដែលកំពុងមានដំណើរការសម្បទានិកអាចនឹងទទួលបានការលើកលែងជាពិសេស។ នីតិវិធីនៃការកាត់បន្ថយនិងការលើកលែងជាពិសេស..."

ហិកតា[២១]។ ប្រសិនបើ រាជរដ្ឋាភិបាលផ្តល់ការលើកលែងជាប្រចាំបែបនេះការលើកលែងនេះនឹងក្លាយជាបទប្បញ្ញត្តិ ហើយស្មារតីនៃច្បាប់គឺបាត់បង់តែម្តង។



ដីសម្បទានរបស់ក្រុមហ៊ុន PPSC (នៅខាងស្តាំង)
ដីសម្បទានរបស់ក្រុមហ៊ុន KSSC នៅខាងឆ្វេង តែព្រំប្រទល់នៅពុំទាន់ច្បាស់លាស់នៅឡើយ។

## ករណីសិក្សា៖ សម្បទានចំការអំពៅ ខេត្តកំពង់ស្ពឺ

ប្រជាពលរដ្ឋមកពីភូមិចំនួនបី (ផ្លូច, អូរប្រូទ្បេន និង ជ្រូកបុស្សី) នៃឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ មានវិវាទជាមួយនឹង ក្រុមហ៊ុនស្ករសភ្នំពេញ(PPSC) របស់ព្រឹទ្ធសមាជិកមកពីគណបក្សប្រជាជនកម្ពុជា លីយ៉ុងផាត់។ ក្រុមហ៊ុននេះទទួលបានសម្បទានលើផ្ទៃដី ១០,០០០ហិកតា ហើយបានទន្ទ្រានលើដីធ្លីរបស់អ្នកភូមិ។

ចាប់ពីឆ្នាំ២០១០ និងឆ្នាំ២០១២ ប្រជាពលរដ្ឋ ២៨នាក់ ត្រូវបានតុលាការចោទប្រកាន់ ពាក់ព័ន្ធនឹងវិវាទនេះ ហើយបទចោទភាគច្រើន គឺបទទន្ទ្រានលើទ្រព្យសម្បត្តិឯកជន។ ត្រឹមដើមឆ្នាំ២០១៣ ប្រជាពលរដ្ឋ ២៧នាក់នៅកំពុងប្រឈមនឹងបទចោទនេះនៅឡើយ។ តំណាងសហគមន៍ម្នាក់បានកោះហៅមកសាកសួរ ចំនួន ៨ដង ដោយតុលាការខេត្តកំពង់ស្ពឺ ។ នៅថ្ងៃទី៩ ខែកុម្ភៈ កងកម្លាំងយោធា ៤០នាក់មកពីអង្គភាពមិនស្គាល់អត្តសញ្ញាណ បានដាក់ឲ្យឈរជើងដើម្បីបង្ក្រាបការតវ៉ារបស់អ្នកភូមិនៅក្រៅតុលាការ។ អ្នកភូមិមានចេតនាដាក់ញត្តិមួយទាមទារឲ្យដោះលែងសកម្មជនសហគមន៍ម្នាក់ និងទាមទារឲ្យអាជ្ញាធរ ឈប់ធ្វើការ បំផិតបំភ័យអ្នកភូមិ។ ខណៈដែលតំណាងសហគមន៍ ព្យាយាមចូលក្នុងបរិវេណតុលាការ ដើម្បីដាក់ញត្តិនេះ ស្រាប់តែ មេបញ្ជាការនៃកម្លាំងយោធា បានគំរាមបាញ់។ ជាលទ្ធផល គឺអ្នកភូមិពុំបានដាក់ញត្តិរបស់ពួកគាត់ ជូនតុលាការបានឡើយ។

នៅភូមិផ្លូច ប្រជាពលរដ្ឋប្រមាណជា ៩០គ្រួសារកំពុងធ្វើការ គំរាមកំហែង ដោយ ការបណ្តេញ ចេញពីលំនៅដ្ឋាន។ ពួកគាត់ រស់នៅលើផ្ទៃដីទទឹង ២០០ម៉ែត្រនៅជាប់នឹងផ្លូវ។ ពួកគាត់ ពុំអាចដាំដុះលើដីរបស់ខ្លួន នៅតំបន់ដែលផ្តល់សម្បទានឲ្យក្រុមហ៊ុន PPSC បានទេ។ ជាលទ្ធផល មនុស្សពេញវ័យជាច្រើនបានចាក ចេញពីភូមិ ដើម្បីទៅរកការងារធ្វើ។ អ្នកខ្លះ ធ្វើការនៅលើដីសម្បទាននោះ។ ដីសម្បទានរបស់ក្រុមហ៊ុន PPSC គឺជាប់គ្នានឹងដីសម្បទានចំការអំពៅមួយទៀតដែលបានផ្តល់ឲ្យក្រុមហ៊ុនស្ករសកំពង់ស្ពឺ (ក្រុមហ៊ុន KSSC) ជាកម្មសិទ្ធិប្រពន្ធរបស់លោកលីយ៉ុងផាត់។ តាមជាក់ស្តែង សម្បទានដីសេដ្ឋកិច្ចទាំងពីរបង្កើតជាដីសម្បទានដូចគ្នាតែមួយ គ្របដណ្តប់លើផ្ទៃដីជាង ២០,០០០ហិកតា។

យ៉ាងណាមិញមាត្រា៤នៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ចបញ្ជាក់អំពីលក្ខណវិនិច្ឆ័យត្រួតគ្នាចំនួន៥ ពោលគឺទាក់ទងនឹងការធ្វើចំណាត់ថ្នាក់ដី, ការធ្វើផែនការប្រើប្រាស់ដី, ការវាយតម្លៃហេតុប៉ះពាល់, ការតាំងទីលំនៅថ្មីនិងសំណងដែលត្រូវតែបំពេញគ្រប់ទាំងអស់មុននឹងផ្តល់ សម្បទានដីសេដ្ឋកិច្ច តែជាក់ស្តែងលក្ខណវិនិច្ឆ័យទាំងនេះពុំត្រូវបាន

២១ ដីសម្បទានរបស់ក្រុមហ៊ុនភាពអ៊ីម៉ិចនៅខេត្តពោធិ៍សាត់និងកំពង់ឆ្នាំងគ្របដណ្តបលើផ្ទៃដីជាង ៣០០,០០០ហិកតា។

អនុវត្តឡើយ។ ផែនការប្រើប្រាស់ដីមួយចំនួនត្រូវបានអនុម័តដោយគណៈកម្មាធិការគ្រប់គ្រងដីធ្លី និងការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម តិចតួចបំផុត ត្រូវបានអនុវត្តមុននឹងការផ្តល់ដីសម្បទាន[២២] ហើយការប្រឹក្សាយោបល់ប្រកបដោយអត្ថន័យកម្រនឹងអនុវត្តជាមួយនឹងប្រជាពលរដ្ឋ និងសហគមន៍ដែល ទទួលរងផលប៉ះពាល់។ ក្នុងករណីមួយចំនួន ប្រជាពលរដ្ឋបានដឹងថា ដីសម្បទានត្រូវបានផ្តល់ឲ្យក្រុមហ៊ុននៅថ្ងៃ ដែលក្រុមហ៊ុនយកគ្រឿងចក្រមកឈូសឆាយដីរបស់ពួកគេ។

ជាទូទៅប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងតំបន់ដីសម្បទានពុំដឹងព័ត៌មានជាមូលដ្ឋានអំពីដីសម្បទានទេ ពោលគឺព្រំប្រទល់ជាក់លាក់ ទំហំ រយៈពេល ក្រុមហ៊ុនដែលពាក់ព័ន្ធ គោលបំណងនៃការប្រើប្រាស់ដី..។ ល។ បុគ្គលិកស៊ើបអង្កេតរបស់សមាគមអាដហុកនៅទូទាំងប្រទេសបង្ហាញអំពីការខកខានជាប្រព័ន្ធរបស់ស្ថាប័នពាក់ព័ន្ធក្នុងការជូនដំណឹងដល់សាធារណជនអំពីគម្រោងអភិវឌ្ឍន៍។ ដោយគ្មានព័ត៌មានច្បាប់លាស់ គឺមិនអាចនឹងធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមបានទេ។ ជាញឹកញាប់ក្រុមហ៊ុនចាប់ផ្តើមឈូសឆាយដី តាំងពីមុនពេលចេញអនុក្រឹត្យ និងចុះហត្ថលេខាលើកិច្ចសន្យាទៅទៀត (ពួកគេចាប់ផ្តើមឈូសឆាយភ្លាមៗ ដែលពួកគេទទួលដំណឹងជាផ្លូវការពីរាជរដ្ឋាភិបាលថា ពួកនឹងទទួលបានដីសម្បទាននោះ)។



សន្តិសុខក្រុមហ៊ុន TTY ហៀបនឹងបាញ់អ្នកភូមិគ្មានអាវុធ (រូបថតផ្តល់ដោយអ្នកភូមិ)

## ករណីសិក្សា៖ អំពើហិង្សាប្រព្រឹត្តដោយក្រុមហ៊ុន TTY នៅខេត្តក្រចេះ

ក្រុមហ៊ុន TTY ដែលគ្រប់គ្រងដោយលោកឧកញ៉ា ណា ម៉ារ៉ាឌី ទទួលបានសម្បទានដីសេដ្ឋកិច្ចទំហំ ៩,៧៨០ហិកតា ដើម្បីដាំដំឡូងមី ក្នុងស្រុកស្នួល ខេត្តក្រចេះ។ ពុំមានការប្រឹក្សាយោបល់ទេ ជាមួយនឹងប្រជាពលរដ្ឋទទួលរងផលប៉ះពាល់ មុននឹងផ្តល់ដីសម្បទាននេះ។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១២ ក្រុមហ៊ុនបានបន្តឈូសឆាយដីកសិកម្ម ក្នុងភូមិវាលបី ឃុំពីរធ្នូ។ ក្រុមហ៊ុន TTY បានពង្រាយអ្នកយាមប្រដាប់ដោយអាវុធ ដើម្បីបង្ការអ្នកភូមិចូលមកក្នុងដីសម្បទានរបស់ពួកគេ ខណៈដែលគ្រឿងចក្ររបស់ក្រុមហ៊ុនកំពុងបំផ្លិតបំផ្លាញចំការដំឡូងមីរបស់អ្នកភូមិ។

ខណៈដែលអ្នកភូមិធ្វើការតវ៉ា បុគ្គលិកសន្តិសុខរបស់ក្រុមហ៊ុន TTY ឈរពីលើត្រាក់ទ័រ ហើយបានបាញ់កាំភ្លើង AK-៤។ ប្រជាពលរដ្ឋ ៤នាក់ រងរបួសដោយសារការបាញ់ប្រហារ ក្នុងនោះមាន ២នាក់របួសធ្ងន់។ នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១២ កែសុវណ្ណានិង ពិនគឹមឡេង ត្រូវបានចាប់ខ្លួនហើយបញ្ជូនទៅតុលាការខេត្តក្រចេះ។ នៅថ្ងៃទី២១ ខែកុម្ភៈ អ៊ុន ពិសិដ្ឋ អតីតអគ្គនាយកក្រុមហ៊ុន TTY ក៏ត្រូវបានចាប់ខ្លួន។

---

២២ ការវាយតម្លៃមួយចំនួនត្រូវបានអនុវត្តក្រោយពីសម្បទានដីសេដ្ឋកិច្ចត្រូវបានផ្តល់ឲ្យ និងបានកំណត់ដោយកង្វះខាតការរាប់បញ្ចូលនិងរយៈពេលខ្លី។ សេចក្តីពង្រាងច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានកំពុងត្រូវបានត្រួតពិនិត្យ។

ការជំនុំជម្រះរបស់ពួកគេប្រព្រឹត្តទៅក្នុងខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០១២ ជាមួយនឹងវត្តមានជនរងគ្រោះតែម្នាក់ប៉ុណ្ណោះ ក្នុង សវនាការ(អង្គការមិនមែនរដ្ឋាភិបាល និងអ្នកកាសែត ពុំទទួលបានព័ត៌មានអំពីការជំនុំជម្រះនោះឡើយ)។ នៅថ្ងៃទី១៣ ខែធ្នូ ជនជាប់ចោទត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ ចាប់ពីពីរទៅបីឆ្នាំ ហើយទាំងអស់គ្នាសុទ្ធតែព្យួរទោស។ កែសុវណ្ណា បានប្រកាសថាគ្មាននរណាម្នាក់បញ្ជាឲ្យគាត់បាញ់ទេ និងបញ្ជាក់ថា កាំភ្លើងពុំមែនជាកម្មសិទ្ធិរបស់ក្រុមហ៊ុន TTYទេ។ ផ្ទុយនឹងភស្តុតាងជាខ្សែវីដេអូដែលអះអាងកាលពីពេលមុនថា ខ្លួនបានបាញ់ «ទៅដី» និង «ទៅលើមេឃ» ដើម្បីតែការពារខ្លួនប៉ុណ្ណោះ។

នេះបង្ហាញថា អាជ្ញាធរ ពុំបានស៊ើបអង្កេតឲ្យបានស៊ីជម្រៅអំពីកាលៈទេសៈនៃការបាញ់ប្រហារនេះទេ ពិសេសខ្សែសង្វាក់នៃការបញ្ជាពោល គឺអ្នកផ្តល់កាំភ្លើង AK-៤៧ ឲ្យសន្តិសុខ និងអ្នកដែលចេញបញ្ជាឲ្យបាញ់អ្នកតវ៉ាគ្មានអាវុធ។ ការពិតដ៏គួរឲ្យរំខានចិត្តមួយ គឺថាការចាប់ខ្លួនក្នុងខែកុម្ភៈ នោះគឺធ្វើបន្ទាប់ពីនាយក រដ្ឋមន្ត្រីហ៊ុនសែន ប្រកាសជាសាធារណៈ "បញ្ជា" ឲ្យមន្ត្រីក្រុមហ៊ុន TTY កំណត់អត្តសញ្ញាណ និងប្រគល់ជនសង្ស័យប៉ុណ្ណោះ។ ឧកញ៉ាណាម៉ារ៉ាឌី មិនដែលត្រូវបាននាំមកសាកសួរ ពាក់ព័ន្ធនឹងករណីនេះ និងសកម្មភាពរបស់ក្រុមហ៊ុន TTY ទេ។


ប្រជាពលរដ្ឋនៅស្នួល ទទួលរងផលប៉ះពាល់ដោយសកម្មភាពក្រុមហ៊ុន TTY

ថ្វីត្បិតតែច្បាប់ចែងថា «វិធីសាស្ត្រអាទិភាពសម្រាប់ការផ្តល់សម្បទានដីសេដ្ឋកិច្ច គឺវិធីសាស្ត្រអំពាវនាវឲ្យដាក់សំណើក្នុងលក្ខណៈប្រកួតប្រជែង»[២៣]។ តែតាមការអនុវត្តជាក់ស្តែង ចំនួនដ៏ច្រើននៃសម្បទានដីសេដ្ឋកិច្ចត្រូវបានផ្តល់ឲ្យ តាមរយៈវិធីសាស្ត្រមិនអំពាវនាវឲ្យដាក់សំណើ។ ភាគច្រើនគឺមិនបំពេញទៅតាមលក្ខណវិនិច្ឆ័យ ដែលមានចែងក្នុងអនុក្រឹត្យសម្រាប់ការផ្តល់សម្បទានដីសេដ្ឋកិច្ច តាមរយៈវិធីសាស្ត្រមិនអំពាវនាវឲ្យដាក់សំណើដែលម្ចាស់សំណើ «សន្យាផ្តល់អត្ថប្រយោជន៍ក្នុងលក្ខណៈពិសេស ដើម្បីសម្រេចនូវគោលបំណងនៃសម្បទានដីសេដ្ឋកិច្ច មានជាអាទិ៍ [...]: ការនាំមកនូវបច្ចេកវិទ្យាថ្មី, ការផ្សារភ្ជាប់ជាពិសេសរវាងសម្បទានដីសេដ្ឋកិច្ច ទៅនឹងសម្បទានដីសង្គមកិច្ច និង [ឬ] លទ្ធភាពពិសេសក្នុងការរកទីផ្សារកែច្នៃ ឬទីផ្សារនាំចេញ» [២៤]។ ដូច្នេះ ការលើកលែងក្លាយទៅជាច្បាប់ និងកាត់ផ្តាច់កោសិកាច្បាប់។

នេះគឺជាការព្រួយបារម្ភ ត្បិតក្រុមហ៊ុនឯកជនចង់បានដី ដែលគួរត្រូវបានការពារជាអាទិភាព។ ម្យ៉ាង ជនជាតិដើមភាគតិចជួបប្រទះនឹងបញ្ហាប្រឈមដ៏ច្រើន ក្នុងការចុះបញ្ជីដីធ្លីរបស់ពួកគេ ជាដីជនជាតិដើមភាគតិច។ ក្នុងច្បាប់ភូមិបាល ក្នុងនាមជានីតិបុគ្គល ពួកគេមានសិទ្ធិកាន់កាប់ដីជាសមូហភាព តែតាមការអនុវត្តជាក់ស្តែង ជាងមួយទសវត្សរ៍បន្ទាប់ពីការអនុម័តច្បាប់នេះ សហគមន៍បែបនេះតែបីប៉ុណ្ណោះ ដែលទទួលបានប័ណ្ណកម្មសិទ្ធិកាន់កាប់ដីសមូហភាព។ អាជ្ញាធរបដិសេធសិទ្ធិទទួលបានដីធ្លីរបស់ជនជាតិដើមភាគតិច ដោយប្រកែកពុំព្រមទទួលស្គាល់ពួកគេជានីតិបុគ្គល (ដោយផ្អែកលើការកំណត់អត្តសញ្ញាណដោយខ្លួនឯង) ហើយអនុវត្តវិធានការ ដើម្បីការពារដី ដែលពួកគេទាមទារពីការទន្ទ្រាន មុននឹងធ្វើការកំណត់ឲ្យជាក់លាក់មួយ។

២៣ មាត្រា១៨ក្នុងអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច
២៤ ដូចឯកសារខាងលើ


ក្អម/ផ្តាំងជនជាតិចារ៉ាយនៅផ្នូរខ្មោច ដែលបានបំផ្លាញ

## ករណីសិក្សា៖ ការគំរាបកំហែងចំពោះដីសហគមន៍ជនជាតិដើមភាគតិច ខេត្តរតនគិរី

ក្នុងខែធ្នូ ឆ្នាំ២០១២ សមាគមអាដហុកទទួលបានព័ត៌មានថា ក្រុមហ៊ុនវៀតណាមពីរ (ក្រុមហ៊ុនDai Dong Yoeun និងក្រុមហ៊ុន ៧២) ដែលទទួលបានសម្បទានដីសេដ្ឋកិច្ច ក្នុងឃុំប៉ក់ញ៉ៃ ស្រុកអូរយ៉ាដាវ ខេត្តរតនគិរី បានចូលរួមក្នុងការកាប់ឈើដោយខុសច្បាប់ក្នុងដីជនជាតិដើមភាគតិច។ សមាជិកនៃសហគមន៍ជនជាតិដើមភាគតិចចារ៉ាយភូមិឡំ បានរាយការណ៍ផងដែរថា បើសិនជាពួកគាត់ពុំព្រមផ្លាស់ប្តូរការទាមទារពីកម្មសិទ្ធិដីសមូហភាព ទៅជាកម្មសិទ្ធិដីឯកជន នោះទេ ពួកគាត់នឹងត្រូវឲ្យបង់ប្រាក់ ៧០០$ - ៨០០$ ឲ្យអាជ្ញាធរ ធ្វើជា «ការពិន័យ។

ក្នុងខែមេសា ឆ្នាំ២០១២ មន្ត្រីអាជ្ញាធរមូលដ្ឋានជាមួយនឹងតំនាងក្រុមហ៊ុន Dai Dong Yoeun បានវាស់វែងដីដោយប្រើប្រាស់ GPS ហើយបានដឹងថា ការឈូសឆាយដីនឹងប៉ះពាល់លើសហគមន៍។ ទោះជា យ៉ាងនេះក្តី ដល់ខែធ្នូផ្ទៃដីរបស់សហគមន៍ទំហំ ២០០ គុណនឹង ៣,០០០ម៉ែត្របានឈូសឆាយដោយក្រុមហ៊ុនទាំងពីរ។ ឈើមានតម្លៃថ្លៃ បាននាំចេញទៅកាន់ប្រទេសវៀតណាម តាមរយៈចក្រព្រំដែននៅជិតខាង។ អាជ្ញាធរមូលដ្ឋាន បានបំភិតបំភ័យសមាជិកសហគមន៍ជនជាតិដើមភាគតិច។ សហគមន៍ជនជាតិ ដើមភាគតិច ត្រូវបានគេប្រាប់ថា ពួកគាត់នឹងត្រូវបង់ប្រាក់ ៧០០$ - ៨០០$ក្នុងមួយហិកតា ដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិកាន់កាប់ដីរបស់ពួកគាត់ ប្រសិនបើពួកគាត់ពុំព្រមផ្លាស់ប្តូរការទាមទារពីកម្មសិទ្ធិសមូហភាព ទៅជាកម្មសិទ្ធិឯកជន នោះទេ (ប្លង់មួយមានទំហំដីមិនលើស ៥ហិកតា)។ ពួកគាត់ក៏បានប្រាប់ទៀតថា ដីធ្លីរបស់ពួកគាត់នឹងគ្មានតម្លៃទេ ព្រោះថាពួកគាត់មិនអាចលក់ដូរឲ្យនរណាម្នាក់បាន ឬក៏ប្រើប្រាស់ ដើម្បី ទទួលបានប្រាក់កម្ចីពីធនាគារ បានទេ។

ក្រោយពីអន្តរាគមន៍របស់សមាគមអាដហុក ឈើរាប់ពាន់ដើមត្រូវបានគេប្រទះឃើញនៅលើដីសម្បទាននោះ ហើយ មនុស្សប្រាំពីរនាក់ ត្រូវបានចាប់ខ្លួនចំពោះការកាប់ឈើ។ ពួកគេជាប់ពាក់ព័ន្ធនឹងក្រុមហ៊ុន ៧២ ។ ចាប់ពីពេលនោះមកមនុស្សប៉ុន្មាននាក់ទៀត ត្រូវបានចាប់ខ្លួនចំពោះការកាប់ឈើដោយ ខុសច្បាប់ក្នុងតំបន់នោះ។ ក្រៅពីនេះនៅថ្ងៃទី៣ ខែមករា ឆ្នាំ២០១៣ សមាជិកនៃសហគមន៍ចារ៉ាយបានរកឃើញថា ផ្នូរបុរាណរបស់ដូនតា បានឈូសឆាយក្នុងដីសម្បទានរបស់ក្រុមហ៊ុន Dai Dong Yoeun។ ផ្នូរខ្មោចប្រមាណ ១,៥០០ បានបំផ្លាញ និងខ្លះទៀតត្រូវបានគាស់កកាយដោយគ្រឿងចក្រ។ បន្ទាប់ពីការចរ ចារដោះស្រាយការបំផ្លិចបំផ្លាញនេះ ក្រុមហ៊ុនយល់ព្រមបង់ប្រាក់ចំនួន ៤០០០$ ជាសំណងឲ្យសហគមន៍។

---

ម្យ៉ាងវិញទៀត តំបន់ការពារនៅតែទទួលរងការទន្ទ្រានជារៀងរាល់ថ្ងៃ។ ដោយសារថាពុំមានការកំណត់ព្រំដែនច្បាស់លាស់រវាងតំបន់ផ្ទៃក្នុងរបស់តំបន់ការពារក្នុងការអនុវត្តជាក់ស្តែង រាជរដ្ឋាភិបាលអាចផ្តល់យ៉ាងស្រួលនូវសម្បទានដីសេដ្ឋកិច្ចទៅឲ្យក្រុមហ៊ុនឯកជនក្នុងតំបន់«អភិរក្ស» ឬតំបន់«ស្នូល» ក្នុង«តំបន់ការពារ(ឬក្នុងតំបន់ដែលត្រូវបានធ្វើចំណាត់ថ្នាក់បែបនោះ) និងធ្វើចំណាត់ថ្នាក់ឡើងវិញ ជាតំបន់«ប្រើប្រាស់ប្រកបដោយចីរភាព» *នៅក្នុងពេលតែមួយ*។ ភាគច្រើននៃសម្បទានដីសេដ្ឋកិច្ចថ្មីៗប៉ះពាល់លើតំបន់ការពារ ដែលទំហំរបស់តំបន់ការពារទាំងនោះកាន់តែរួញទៅៗយ៉ាងឆាប់រហ័ស (សូមមើលឧបសម្ព័ន្ធ)។ បែបផែននេះគឺស្រដៀងគ្នានឹងកង្វះខាតតម្លាភាពជុំវិញឋានៈដីសាធារណៈនោះ គឺអវត្តមាននៃការកំណត់ព្រំដែនដ៏ច្បាស់លាស់រវាងដីរដ្ឋសាធារណៈ និងដីរដ្ឋឯកជន។ យុទ្ធសាស្ត្រមួយ ដែល

ត្រូវបានប្រើប្រាស់យ៉ាងញឹកញាប់ដោយក្រុមហ៊ុនឯកជនគឺឈូសឆាយដីព្រៃក្នុងតំបន់ការពារ ហើយក្រោយមក ធ្វើឲ្យរាជរដ្ឋាភិបាលដឹងឮអំពីការបំផ្លិតបំផ្លាញព្រៃឈើនេះ ហើយរាជរដ្ឋាភិបាលធ្វើចំណាត់ថ្នាក់ដីឡើងវិញ ឬកាត់ដីនោះចេញពីតំបន់ការពារ។ ដូច្នេះ ផ្ទុយពីការចាត់វិធានការដើម្បីបង្ការពីការហិចហោចបន្ថែមទៀត រាជរដ្ឋាភិបាលគាំទ្រសកម្មភាពរបស់ពួកទន្ទ្រានយកដី និងជូនរង្វាន់ដល់ពួកគេថែមទៀត។

ការត្រួតពិនិត្យលើសម្បទានមានលក្ខណៈទន់ខ្សោយ។ សម្បទានដីសេដ្ឋកិច្ចមួយចំនួនត្រូវបានលុបចោលក្នុងឆ្នាំ២០១២។ ទោះជាយ៉ាងនេះក្តី ដីសម្បទានផ្សេងទៀតនៅទំនេរចោលជាច្រើនឆ្នាំ ក្រោយពីផ្តល់ឲ្យសម្បទានិក ដែលនេះគឺជាការបំពារបំពានលើច្បាប់[២៥]។ ដីសម្បទានដែលទុកឲ្យនៅទំនេរចោល ក៏ដូចជា ដីសម្បទានដែលត្រូវបានប្រើប្រាស់តិចតួច ឬប្រើប្រាស់ដោយបំពានលើបទប្បញ្ញត្តិច្បាប់ និងកិច្ចសន្យា ដែលរាជរដ្ឋាភិបាលចាំបាច់ត្រូវតែលុបចោលដើម្បីប្រគល់ដីឲ្យប្រជាពលរដ្ឋប្រើប្រាស់ប្រកបដោយប្រសិទ្ធផលវិញ។ គេសង្ឃឹមថា បទបញ្ជាលេខ០០១នឹងដោះស្រាយបញ្ហានេះ (សូមមើលជំពូក៤ ខាងក្រោម)។

ទីបី ដូចបានលើកឡើងខាងលើ កង្វះខាតទិន្នន័យ និងការចងក្រងឯកសារអំពីសម្បទានដីសេដ្ឋកិច្ច គឺជាបញ្ហាកើតឡើងក្នុងគ្រប់ក្រសួង/ស្ថាប័ន។ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ គឺលោក Surya Subedi បានសង្កត់ធ្ងន់ថា "មានការព្រួយបារម្ភគួរឲ្យកត់សម្គាល់ដែលថា[សម្បទាន] ពុំត្រូវបានចងក្រងជាឯកសារឲ្យបានប្រទាក់ប្រឡាគ្នាឡើយ"[២៦]។ តាមពិត ប្រសិនបើ រាជរដ្ឋាភិបាលមានភាពច្បាស់លាស់ជាមួយនឹងអត្ថប្រយោជន៍នៃការធ្វើអាជីវកម្មកសិឧស្សាហកម្មនោះ រាជរដ្ឋាភិបាលត្រូវបើកបង្ហាញរាល់ព័ត៌មានពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ចទាំងអស់។ បន្ថែមលើនេះទៀត វាចាំបាច់ដែលរាជរដ្ឋាភិបាលបង្ហាញព័ត៌មានអំពីឋានៈដីក្នុងគ្រប់ខេត្តក្រុងទាំងអស់ (ដីរដ្ឋសាធារណៈ/ដីរដ្ឋឯកជន, ការទាមទាររបស់ជនជាតិដើមភាគតិចដែលកំពុងរង់ចាំសេចក្តីសម្រេច, តំបន់ការពារ)។

## សម្បទានដីសង្គមកិច្ច

ជាផ្លូវការ គោលនយោបាយសម្បទានដីសង្គមកិច្ចមានបំណងជួយសម្រាលភាពក្រីក្រ ដោយផ្តល់ដីឲ្យគ្រួសារឥតដីធ្លី និងក្រីក្រ (រួមទាំងអ្នកដែលត្រូវបានផ្លាស់ប្តូរទីកន្លែងដោយសារតែសម្បទានដីសេដ្ឋកិច្ច) និងអតីតយុទ្ធជន។ ដីអាចត្រូវបានប្រើប្រាស់សម្រាប់តាំងលំនៅដ្ឋាន និងដាំដុះ។ ក្នុងឆ្នាំ២០១២ រាជរដ្ឋាភិបាលបានផ្តល់សម្បទានដីសង្គមកិច្ច៣៨កន្លែង គ្របដណ្តប់លើផ្ទៃដី១០០,៧៩០ហិកតា ក្នុងខេត្ត-ក្រុងចំនួន១៦ ដោយរាប់បញ្ចូល ប្រាំពីរក្នុងខេត្តកំពង់ចាម ប្រាំពីរក្នុងខេត្តកំពត និងប្រាំក្នុងខេត្តសៀមរាប។ ក្នុងរបាយការណ៍ឆ្នាំ២០១១របស់ខ្លួនស្តីពីសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាន សមាគមអាដហុកកត់សម្គាល់ឃើញថាតួលេខរបស់សម្បទានដីសង្គមកិច្ច គឺមានលក្ខណៈស្តួចស្តើង បើធៀបនឹងទំហំផ្ទៃដី ដែលផ្តល់ឲ្យក្រុមហ៊ុនឯកជន ក្រោមគម្រោងសម្បទានផ្សេងៗទៀត។ ករណីនេះហាក់ដូចពុំកើតមានទេ ក្នុងឆ្នាំ២០១២ ខណៈដែលផ្ទៃដីសរុបដែលត្រូវបានផ្តល់ឲ្យក្នុងនាមជាសម្បទានដីសង្គមកិច្ច តំណាងឲ្យច្រើនជាងពីរដងនៃផ្ទៃដី ដែលត្រូវបានផ្តល់ឲ្យ ក្រោមគម្រោងសម្បទានដីសង្គមកិច្ចក្នុងឆ្នាំ២០១១[២៧] និង២៦%នៃផ្ទៃដី ដែលបានផ្តល់ឲ្យក្រោមគម្រោងសម្បទានដីសេដ្ឋកិច្ចក្នុងឆ្នាំ២០១២។ នេះអាចតំណាងឲ្យការផ្លាស់ប្តូរមួយក្នុងគោលនយោបាយបែងចែកដីធ្លី។ ទោះជាយ៉ាងនេះក្តី យើងពុំអាចធ្វើសេចក្តីសន្និដ្ឋានបាន ក្នុងគ្រាសរសេររបាយការណ៍នេះឡើយ ត្បិតយើងត្រូវការជាចាំបាច់នូវការស៊ើបអង្កេត និងការយល់ដឹងតាមក្រោយបន្ថែមទៀត។

គេរាយការណ៍ថា អំពើពុករលួយ ការគ្រប់គ្រងខុស និងបក្សពួកនិយម គឺពាក់ព័ន្ធនឹងសម្បទានដីសង្គមកិច្ចជាក់ស្តែងនៅភ្នំពេញ (សហគមន៍បុរីកីឡានិងសហគមន៍បឹងកក់)។ នីតិវិធី ដូចមានចែងក្នុងអនុក្រឹត្យស្តីពីសម្បទាន

២៥ មាត្រា៦២នៃច្បាប់ភូមិបាល។
២៦ របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជាកថាខណ្ឌ៨៣។
២៧ ក្នុងឆ្នាំ២០១១រដ្ឋាភិបាលបានអនុម័តការផ្តល់សម្បទានប្រមាណ៤៩,៨៩៧ហិកតាក្រោមគម្រោងសម្បទានដីសង្គមកិច្ច។

ដីសង្គមកិច្ចពុំត្រូវបានយកមកអនុវត្តឡើយ។ ពិសេសការពិគ្រោះយោបល់ជាមួយសហគមន៍កម្រនឹងអនុវត្តណាស់។ បន្ថែមលើនេះទៀត មានកើតឡើងនូវការរំលោភបំពាន ក្នុងតំបន់សម្បទានដីសង្គមកិច្ច ដែលអាជ្ញាធររដ្ឋខកខានពុំបានស៊ើបអង្កេតឲ្យបានត្រឹមត្រូវ។ ក្នុងករណីខ្លះ ដីដែលបានផ្តល់ឲ្យអង្គការមិនមែនរដ្ឋាភិបាលក្លែងក្លាយត្រូវបានលក់, ដកហូតពីអ្នករស់នៅស្របច្បាប់ ឬប្រគល់ជូនឲ្យសមាជិកនៃសមាគមអតីតយោធិន។ អ្នករស់នៅមុនៗត្រូវបានបណ្តេញចេញពីតំបន់សម្បទានដីសង្គមកិច្ច ឬទទួលរងសម្ពាធឲ្យក្លាយជាសមាជិកសមាគមអតីតយោធិន។ ចុងក្រោយ អំពើព្រហ្មទណ្ឌធ្ងន់ធ្ងរបំផុត ត្រូវគេរាយការណ៍ថាបានកើតឡើងក្នុងតំបន់សម្បទានដីសង្គមកិច្ច ដែលក្នុងនោះរួមមាន ការរំលោភសេពសន្ថវៈ និងអំពើទារុណកម្ម ( សូមមើលករណីសិក្សា )។ កន្លងមក អាជ្ញាធរខកខានពុំបានដោះស្រាយបញ្ហាទាំងនេះទេ។



អ្នកភូមិកន្ទួតឡើងមកតវ៉ានៅភ្នំពេញ ( ២៦ខែមិថុនាឆ្នាំ២០១២ )

**ករណីសិក្សា៖ ការរំលោភបំពានដែលបានប្រព្រឹត្ត ពាក់ព័ន្ធនឹងសម្បទានដីសង្គមកិច្ចរបស់អង្គការ DARPO ខេត្តព្រះវិហារ**

ក្នុងឆ្នាំ២០០៧ ក្នុងឃុំកន្ទួត ស្រុកជាំខ្សាន្ត ខេត្តព្រះវិហារ រដ្ឋាភិបាល បានផ្តល់សម្បទានដីសង្គមកិច្ច ប្រមាណជា ៥៥៦ហិកតា ឲ្យទៅអង្គការបង្ការ និងស្រាវជ្រាវអំពីជំងឺ/មេរោគអេដស៍ និងគ្រឿងញៀន ( ហៅកាត់ DARPO ) ដែលជាអង្គការមិនមែនរដ្ឋាភិបាលថ្មីមួយ ដឹកនាំដោយឧត្តមសេនីយ៍ផ្កាយ១ម្នាក់ឈ្មោះ ប៉ែនលឹម បើទោះជា មានប្រជាជនរស់នៅលើដីនោះក្តី។ ដីដែលនឹងត្រូវបែងចែកឲ្យប្រជាពលរដ្ឋក្រីក្រដែលញៀនថ្នាំ និង/ឬ អ្នកផ្ទុកមេរោគអេដស៍ ត្រូវបានលក់ដូរយកប្រាក់ចំណេញទៅវិញ។

អ្នកភូមិ បានរស់នៅដោយ ពុំបានផ្តល់ឲ្យសមរម្យនូវអនាម័យ ទឹកស្អាត និងសេវាសុខភាពទេ។ ជាប្រចាំមនុស្សដែលជាប់ពាក់ព័ន្ធនឹងអង្គការ DARPO បានទារលុយគំរាមកំហែង និងវាយប្រហារអ្នកភូមិ។ អ្នកខ្លះ ចាកចេញពីដីរបស់ខ្លួនដើម្បីជៀសឲ្យផុតពីស្ថានភាពទាំងនេះ ហើយក្នុងករណីបែបនេះដីនោះនឹងលក់ឲ្យអ្នកទិញផ្សេងទៀត។ អ្នកភូមិម្នាក់ គឺអ្នកស្រី ខឹមខាន់ បានវាយដំដោយមនុស្សរបស់ប៉ែនលឹម ធ្វើឲ្យគាត់ពិការ។ គាត់ក៏បានអះអាងថាពួកគេបានរំលោភគាត់ និងកូនស្រីអាយុ ១៣ឆ្នាំ របស់គាត់ និងលួចលុយគាត់ប្រមាណ ១,៧០០$ មុននឹងដុតផ្ទះគាត់ចោល និងលក់ឲ្យអ្នកផ្សេង។

ក្នុងឆ្នាំ២០១០ ប្រជាពលរដ្ឋ ៣១៩គ្រួសារ បានដាក់បណ្តឹងប្រឆាំងនឹង ប៉ែនលឹម។ ពួកគាត់ ស្នើសុំឲ្យអាជ្ញាធរមូលដ្ឋានចាត់វិធានការប្រឆាំងនឹងអង្គការDARPO និងទាមទារឲ្យចុះបញ្ជីដីស្របច្បាប់ ដើម្បីឲ្យពួកគេអាចរៀបចំពិធី រកការងារធ្វើ និងបោះឆ្នោត។ គេប្រាប់ប្រជាពលរដ្ឋទាំងនោះថា ពួកគេចាំបាច់ត្រូវសុំការ អនុញ្ញាតពីអង្គការ DARPO សម្រាប់អនុវត្តសកម្មភាពខាងលើ និងមិនឲ្យចុះបញ្ជីដីឡើយ។ ក្រោយពីការវិវឌ្ឍទាំងនេះ ប៉ែនលឹម បានដឹកនាំការប្រជុំមួយក្នុងទីធ្លាអង្គការរបស់គាត់។ គាត់បានបំភិតបំភ័យអ្នកភូមិ ដោយបង្ខំពួកគាត់ឲ្យប្រកាសថា ពួកគាត់បានប្រើប្រាស់ដោយតំណាងសហគមន៍ ដែលបានប្រើប្រាស់ស្នាមម្រាមដៃពួកគេដោយខុសច្បាប់។ អ្នកភូមិ៤៨ ត្រូវបានគេបង្ខំឲ្យដាក់ពាក្យបណ្តឹងប្រឆាំងនឹងលោកស្រី សាតសារឿន( អាយុ៤៤ ), លោកគីមសុផល( អាយុ៤៤ ) និងលោកស្រីសោភ័ណ្ឌ( អាយុ៧៤ )។ ទាំងបីនាក់នេះ ត្រូវបានចាប់ខ្លួន និងជាប់ឃុំបណ្តោះអាសន្នមុនការជំនុំជម្រះ។ រូបថតពួកគេជាប់ខ្នោះ ត្រូវបានបិទនៅផ្លូវចូលរបស់អគារអង្គការ DARPO ដើម្បីបន្លាចស្មារតីដល់អ្នកភូមិដទៃទៀត។ ក្នុងខែមីនា ឆ្នាំ២០១២តុលាការខេត្តព្រះវិហារ បានដោះលែងពួកគាត់ដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដាន។ ទោះជាយ៉ាងនេះក្តី ពួកគាត់នៅតែ

ប្រឈមមុខនឹងការចោទប្រកាន់ពីបទក្លែងបន្លំឯកសារ ការញុះញង់ និងការផ្សព្វផ្សាយព័ត៌មានមិនពិត។

នៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០១២ អ្នកភូមិកន្ទួតបានដាក់ញត្តិមួយទៅខុទ្ទកាល័យរបស់នាយករដ្ឋមន្ត្រី។នៅថ្ងៃបន្ទាប់នាយករដ្ឋមន្ត្រីហ៊ុនសែន បានប្រកាសជាសាធារណៈឲ្យចាប់ខ្លួន ប៉ែនលឹម នៅក្នុងពិធីប្រគល់ប័ណ្ណកម្មសិទ្ធិកាន់កាប់ដី។ ទោះជាយ៉ាងនេះក្តី ត្រឹមដើមខែមករា ឆ្នាំ២០១៣ ប៉ែនលឹម ពុំទាន់ត្រូវបានចាប់ខ្លួននៅឡើយទេ។

---

ប្រសិនបើវិធានការដែលអនុវត្តគោលនយោបាយសម្បទានដីសង្គមកិច្ច ពុំស្របទៅនឹងលក្ខខណ្ឌតម្រូវផ្នែកច្បាប់ទេនោះ វិធានការទាំងនេះពិតជាធ្វើឲ្យស្ថានភាពរបស់គ្រួសារដែលងាយរងគ្រោះកាន់តែអាក្រក់ទៅ ដោយបង្កើនភាពឥតដីធ្លី និងបញ្ឆេះឲ្យមានវិវាទដីធ្លីកាន់តែច្រើន។ តាមពិតក្នុងចំណោមសម្បទានដីសង្គមកិច្ចទាំង៣៨ ដែលបានផ្តល់ឲ្យក្នុងឆ្នាំ២០១២ សម្បទានដីចំនួន១៣កន្លែង បង្កឲ្យមានវិវាទ។ (សមាគមអាដហុកក៏តាមដានវិវាទ ដែលជាប់ពាក់ព័ន្ធនឹងសម្បទានដីសង្គមកិច្ចទាំង១៣ ដែលនៅសេសសល់ពីឆ្នាំមុនៗផងដែរ)។ នេះគឺជាចំនួនដ៏ច្រើន បើពិចារណាថាគម្រោងសម្បទានដីសង្គមកិច្ច គួរតែដោះស្រាយបញ្ហាពាក់ព័ន្ធនឹងភាពឥតដីធ្លី។ ប្រជាពលរដ្ឋដែលត្រូវបណ្តេញចេញ ឬរំលោភបំពាន ដោយសារតែសម្បទានដីសង្គមកិច្ចចាញ់ក្នុងគ្រប់ករណីទាំងអស់ ត្បិតពួកគេត្រូវបានផាត់ចេញពីកម្មវិធីដែលគួរតែដោះស្រាយការកើតទុក្ខមិនសុខចិត្តរបស់ពួកគេ។

## វិវាទដីធ្លី

ភាគច្រើននៃករណីដែលសមាគមអាដហុកកាន់តាមរយៈការស៊ើបអង្កេត សម្រុះសម្រួលឬការជួយគាំទ្រដល់ជនរងគ្រោះ គឺជាករណីវិវាទដីធ្លី រវាងភាគីឯកជនឬ/រវាងប្រជាពលរដ្ឋឯកជន និងអាជ្ញាធរសាធារណៈផ្សេងៗ ដែលមិនពាក់ព័ន្ធនឹងសម្បទានដី។ ក្នុងឆ្នាំថ្មីៗនេះ សមាគមអាដហុកមានជោគជ័យជាងក្នុងការដោះស្រាយវិវាទដីធ្លីទាំងនេះ ឬសម្របសម្រួលលទ្ធផលពេញចិត្ត ជាជាងក្នុងការដោះស្រាយករណីសម្បទានដីសេដ្ឋកិច្ច ឬសម្បទានដីសង្គមកិច្ច។ ក្នុងឆ្នាំ២០១២សមាគមអាដហុកកាន់វិវាទដីធ្លីចំនួន៧០ករណី ប៉ះពាល់លើផ្ទៃដី១០១,៤០៨ ហិកតា និងប្រជាពលរដ្ឋ១០,៦៨៩គ្រួសារ។ បន្ថែមលើនេះទៀត សមាគមអាដហុកបានតាមដានវិវាទដីធ្លីមិនទាន់ដោះស្រាយចំនួន៦២ករណី ដែលនៅសេសសល់ពីឆ្នាំមុនៗ។ ខេត្តដែលទទួលរងការប៉ះពាល់ខ្លាំងជាងគេបើគិតពីចំនួននិងភាពស្រួចស្រាវនៃវិវាទដីធ្លីគឺខេត្តបាត់ដំបង កំពង់ចាម កំពង់ធំ កោះកុង ក្រចេះ មណ្ឌលគិរី រតនគិរី និងសៀមរាប។ មិនដូចករណីសម្បទានដីសេដ្ឋកិច្ច ឬសម្បទានដីសង្គមកិច្ចនោះទេ ទាំងនេះពុំមែនជាទិន្នន័យជិតដល់ប៉ុន្មាននោះទេ។ សមាគមអាដហុកនៅរក្សាទីស្នាក់ការតាមមូលដ្ឋានក្នុងខេត្តទាំងនោះ (លើកលែងតែក្រុងកែប) និងកាន់ករណីវិវាទដីធ្លីជារៀងរាល់ថ្ងៃ ប៉ុន្តែមិនអាចទាមទារប្រមូលព័ត៌មានអំពីគ្រប់វិវាទដីធ្លីនៅកម្ពុជានោះដែរ។ គំហើញរបស់ពួកយើង គឺផ្អែកទៅលើករណីដែលពួកយើងកាន់ និន្នាការតាមការអង្កេត និងជំនាញរបស់យើងខ្ញុំ។

សមាគមអាដហុកបានកត់សម្គាល់ឃើញកម្រិតខ្ពស់នៃកិច្ចសហប្រតិបត្តិការពីជនរងគ្រោះនិងសមាជិកសហគមន៍ដែលកាន់តែមានទឹកចិត្តចូលរួមក្នុងសិក្ខាសាលាការបណ្តុះបណ្តាលនិងសកម្មភាពកសាងដៃគូ។ ការពង្រឹងអំណាចសហគមន៍ គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយក្នុងដោះស្រាយបញ្ហា ពាក់ព័ន្ធនឹងការទន្ទ្រានយកដី និងធនធានធម្មជាតិ ហើយសមាគមអាដហុកលើកទឹកចិត្តឲ្យសហគមន៍តវ៉ា *ដោយសន្តិវិធីប្រឆាំងនឹងការរំលោភបំពាន* និងធ្វើសកម្មភាព *រួមគ្នាដើម្បីការពារសិទ្ធិពួកគេ*។ នេះគឺពិតជាសំខាន់ខ្លាំងណាស់ ត្បិតអាជ្ញាធរហាក់ដូចជាខ្លាចរអានឹងសាមគ្គីភាព តាមរយៈសកម្មភាពរួមគ្នា និងការកសាងបណ្តាញ។ ការរីកចម្រើនរាយការណ៍ដោយបុគ្គលិកនៅទីស្នាក់ការកណ្តាល និងទីស្នាក់ការតាមខេត្តរបស់សមាគមអាដហុក បង្ហុលបង្ហាញអំពីសុឆន្ទៈនៅខាងផ្នែកជនរងគ្រោះនៃវិវាទដីធ្លីក្នុងការដាក់ពាក្យបណ្តឹង និងទាមទារសិទ្ធិរបស់ពួកគេ។ ទោះជាយ៉ាងនេះក្តី ការឈានទៅដល់ដំណោះស្រាយគឺប្រើប្រាស់ពេលវេលាយូរ។ ភាគច្រើនអ្នកទន្ទ្រានយកដីធ្លីគឺជាក្រុមហ៊ុនឬ អ្នកមានទ្រព្យសម្បត្តិ និងមានខ្សែស្រឡាយធំដែលអាចមានលទ្ធភាពបំភិតបំភ័យជនរងគ្រោះ ដាក់សម្ពាធ

លើអាជ្ញាធរសាធារណៈ និងមានឥទ្ធិពលលើតុលាការ។

---

### ករណីសិក្សា៖ វិវាទដីធ្លីនៅភូមិអូរវល្លិព្រេង ខេត្តបាត់ដំបង

អ្នកភូមិអូរវល្លិព្រេង ឃុំខ្នាចរមាស ស្រុកបវេល ខេត្តបាត់ដំបង បានជាប់ពាក់ព័ន្ធនឹងវិវាទដីធ្លីមួយ អស់រយៈពេលជិត ១៥ឆ្នាំ។ ក្នុងឆ្នាំ១៩៩៨ លោកអៀងអឿន ដែលជាអាជីវករ បានដាក់ពាក្យបណ្តឹងមួយ ប្រឆាំងនឹងអ្នកភូមិពីបទកាន់កាប់ដី ១៩ហិកតា ដោយខុសច្បាប់ ដែលគាត់បានអះអាងថាជា កម្មសិទ្ធិរបស់គាត់។ ក្នុងឆ្នាំ១៩៩៩ តុលាការខេត្ត បានសម្រេចឲ្យគាត់ឈ្នះ និងប្រគល់ដីប្រមាណ ១១០ហិកតា (២២ប្លង់)ឲ្យគាត់។ ក្នុងឆ្នាំ២០០២ គាត់បានដាក់ពាក្យបណ្តឹងមួយទៀតប្រឆាំងនឹង ៧គ្រួសារថែមទៀត ពីបទទន្ទ្រានកាន់កាប់ដីរបស់គាត់ ហើយតុលាការ ក៏ប្រើប្រាស់សាលក្រមដំបូង ដើម្បីតម្កល់ការទាមទាររបស់គាត់។

ក្នុងឆ្នាំ២០០៥ អៀងអឿន បានដាក់ពាក្យបណ្តឹងមួយទៀតប្រឆាំងនឹងមនុស្ស ៤នាក់។ អ្នកទាំង ៤នាក់នេះត្រូវបានឃុំខ្លួនមុនការជំនុំជម្រះ ប៉ុន្តែត្រូវបានដោះលែងវិញ បន្ទាប់ពីអន្តរាគមន៍របស់សមាគម អាដហុក និងគណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)។ ក្នុងឆ្នាំ ២០០៧ អ្នកភូមិបាននាំគ្នាមកតវ៉ានៅភ្នំពេញ។ ក្រសួងយុត្តិធម៌ បានបញ្ជាឲ្យមានការសើបអង្កេតដ៏ល្អិតល្អន់ក្នុងករណីនេះ។ អធិការកិច្ចរបស់ក្រសួងបានធ្វើសេចក្តីសន្និដ្ឋានថា អ្នកភូមិមានសិទ្ធិកាន់កាប់លើដីធ្លីនោះ ដែល អៀងអឿន ពុំមានសិទ្ធិតាមផ្លូវច្បាប់បានក្នុងឆ្នាំ១៩៩៤ (ព្រោះតំបន់នេះគ្រប់គ្រងដោយពួកខ្មែរក្រហម) ហើយថាគ្មានមូលដ្ឋាន ក្នុងការឃុំខ្លួនអ្នកភូមិទេ។ ទោះបីមានគំហើញនេះក៏ដោយ អាជ្ញាធរមូលដ្ឋានឃុំអន្លង់រុន ស្រុកថ្មគោល បានធ្វើការបណ្តេញប្រជាពលរដ្ឋ ៣៨គ្រួសារ ដែលរស់នៅក្បែរប្លង់ដី១១០ហិកតារបស់ អៀងអឿន (ពួកគេអះអាងថាគ្រួសារទាំងនោះរស់នៅលើទឹកដីឃុំអន្លង់រុន ពុំមែននៅលើទឹកដីឃុំខ្នាចរមាសទេ)។

ក្នុងខែវិច្ឆិកា ឆ្នាំ២០១២ តុលាការសម្រេចចាប់ខ្លួនប្រជាជន ៩នាក់ ពាក់ព័ន្ធនឹងករណីនេះ។ ប្រជា ពលរដ្ឋ ៧នាក់ទៀត ទទួលបានដីកាឲ្យបង្ហាញនៅមុខសាលាឧទ្ធរណ៍។ សមាគមអាដហុកបានស្នើសុំ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (CHRC) ឲ្យជួយធ្វើអន្តរាគមន៍ ដោយអនុវត្តនូវការសើបអង្កេតរួមគ្នាមួយក្នុងករណីនេះ (សូមមើល៤.គខាងក្រោម)។ ក្នុងខែមករា ឆ្នាំ២០១៣ CHRC សមាគមអាដហុក និងបុគ្គលិកមេធាវី សំរិទ្ធិគ្រុប បានធ្វើដំណើរការជាមួយគ្នាទៅភូមិអូរវល្លិព្រេង ដើម្បីជួបនឹងអាជ្ញាធរមូលដ្ឋាន។ កិច្ចសន្ទនានៅតែបន្តហើយដីនោះនឹងត្រូវបានកំណត់ព្រំប្រទល់ច្បាស់លាស់។ យ៉ាងណាមិញ ផ្ទុយនឹងការប្តេជ្ញាចិត្តរបស់ព្រះរាជអាជ្ញា អ្នកភូមិម្នាក់ក្នុងចំណោមជនចាប់ចោទ ៩នាក់ខាងលើ បានចាប់ខ្លួនបញ្ជូន មកតុលាការខេត្ត នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៣។

---

ក្នុងខែមិថុនា ឆ្នាំ២០១២ រាជរដ្ឋាភិបាលព្យាយាមដោះស្រាយបញ្ហាដីធ្លី ដោយបង្កើតនូវគម្រោងប្រគល់ប័ណ្ណកម្មសិទ្ធិដីធ្លីថ្មីមួយ តាមរយៈការកំណត់ព្រំប្រទល់ដីដោយក្រុមយុវជនស្ម័គ្រចិត្ត។ ការវាយតម្លៃបឋមនៃគម្រោងថ្មីនេះត្រូវបានពន្យល់លម្អិតក្នុងផ្នែក៤ខាងក្រោម។

## ការបណ្តេញចេញដោយបង្ខំ

សហគមន៍ជនជាតិដើមភាគតិច និង សហគមន៍មិនមែនជនជាតិដើមភាគតិចរាប់រយនៅទូទាំងប្រទេសកម្ពុជាបានបង្ហាញអំពីក្តីបារម្ភរបស់ពួកគេអំពីការពិតដែលថាពួកគេត្រូវបានបដិសេធសិទ្ធិចុះបញ្ជីដីធ្លី ដែលពួកគេកាន់កាប់ដោយស្របច្បាប់។ ជាលទ្ធផល ពួកគេកំពុងប្រឈមមុខនឹងការបណ្តេញចេញពីលំនៅដ្ឋាន។

ក្នុងច្បាប់ភូមិបាល ការកាន់កាប់ដីអាចទៅជាម្ចាស់កម្មសិទ្ធិ។ តាមពិតមាត្រា៣០ចែងថា៖បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈដោយសន្តិវិធីនិងមិនមានការជំទាស់ចាប់ពី៥ឆ្នាំ យ៉ាងតិចគិតមកដល់កាលបរិច្ឆេទនៃការប្រកាសឲ្យប្រើច្បាប់នេះលើអចលនវត្ថុ ដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ក្នុងការកាន់កាប់ជាឯកជន មាន

សិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ"[២៨]។ យោងតាមមាត្រា៣៨ ដើម្បីក្លាយទៅជាកម្មសិទ្ធិលើអចលនវត្ថុបាន លុះត្រាតែភោគៈនោះត្រូវបានកាន់កាប់ដោយពិតប្រាកដ គ្មានហិង្សា ដឹងឮជាសាធារណៈ គ្មានអាក់ខាន និងដោយសុចរិត។

សហគមន៍ជាច្រើន ដែលបានតាំងលំនៅដ្ឋាននៅទីតាំងរស់នៅបច្ចុប្បន្ន បន្ទាប់ពីការដួលរលំរបស់របបខ្មែរក្រហម បំពេញនូវលក្ខណវិនិច្ឆ័យទាំងនេះ។ ពួកគេភាគច្រើនពុំមានប័ណ្ណរឹង និងឯកសារផ្តល់ជូនដោយអាជ្ញាធរមូលដ្ឋានទេ ហើយអាចផ្តល់ភស្តុតាងនៃការរស់នៅយូរ។ ទោះជាយ៉ាងនេះក្តី ជាលក្ខណៈប្រព័ន្ធ អាជ្ញាធរខកខានមិនទទួលស្គាល់ភស្តុតាងបែបនេះ និងតម្កល់សិទ្ធិកាន់កាប់របស់ប្រជាពលរដ្ឋ និងសហគមន៍ ដែលរស់នៅលើដីក្នុងក្រុងដែលមានតម្លៃខ្ពស់ ឬនៅលើដីដែលវិនិយោគិនចង់បាន។ ជាប្រព័ន្ធ អាជ្ញាធរនៅគ្រប់ថ្នាក់លំអៀងទៅផលប្រយោជន៍អាជីវកម្មជាជាងការទទួលស្គាល់សិទ្ធិស្របច្បាប់របស់ប្រជាជន ដោយសំដៅប្រជាពលរដ្ឋ និងសហគមន៍ខាងលើ ថាជា "អ្នកមករស់នៅឥតច្បាប់" ហើយចេញសារាចរណែនាំស្តីពីដំណោះស្រាយនៃការតាំងលំនៅដ្ឋានជាបណ្តោះអាសន្ននៅលើដី ដែលកាន់កាប់ដោយខុសច្បាប់។ ដូចគ្នាដែរ នៅទីជនបទ កសិករដែលបានកាន់កាប់ដីរបស់ខ្លួនអស់ជាច្រើនឆ្នាំជួនកាលត្រូវបានហៅថាជា "អ្នកមកថ្មី" ឬ "អ្នកមករស់នៅខុសច្បាប់" ដោយអាជ្ញាធរដែនដី។ បន្ទាប់មករូបភាពអភិវឌ្ឍន៍[២៩]ត្រូវបានប្រើប្រាស់ដើម្បីបណ្តេញប្រជាពលរដ្ឋចេញដោយគ្មានសំណង។

ត្រឹមខែឧសភា ឆ្នាំ២០១១ សហគមន៍ចំនួន៨១ត្រូវបានបណ្តេញចេញពីលំនៅដ្ឋានរបស់ពួកគេនៅទីក្រុងភ្នំពេញ គឺប៉ះពាល់យ៉ាងតិចណាស់៣០,០០៩គ្រួសារ[៣០]។ ចាប់ពីពេលនោះមកមានការបណ្តេញចេញពីលំនៅដ្ឋានបន្ថែមទៀត រាប់បញ្ចូលទាំង សហគមន៍បុរីកីឡាផង។ ក្នុងករណីភាគច្រើន អាជ្ញាធរខកខានមិនបានអនុម័តតាមលក្ខខណ្ឌតម្រូវផ្នែកច្បាប់ជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងការបណ្តេញចេញ និងការតាំងលំនៅដ្ឋានថ្មី។ នេះធ្វើឲ្យការបណ្តេញចេញភាគច្រើនដែលអនុវត្តនៅកម្ពុជាទៅជាអំពើខុសច្បាប់។ ក្រៅពីនេះ អាជ្ញាធរពុំដែលអើពើនឹងមាត្រា៣៦នៃច្បាប់ភូមិបាលឡើយ ដែលក្នុងនោះមានចែងថា បើវិធានការបណ្តេញចេញអាចបណ្តាលឲ្យមានភាពវឹកវរ អាជ្ញាមានសមត្ថកិច្ចអាចសុំព្យួរការអនុវត្តជាបណ្តោះអាសន្នបាន។ នេះគឺផ្ទុយគ្នាស្រឡះទៅនឹងនិន្នាការរបស់អាជ្ញា ក្នុងការបដិសេធការធានាដល់អ្នកដែលត្រូវបានចោទប្រកាន់អំពីបទល្មើសព្រហ្មទណ្ឌ ដោយសំអាងលើមូលដ្ឋានថា ការដោះលែងនឹងគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈ។

បញ្ហាមួយចំនួន គឺពិតជាការព្រួយបារម្ភ។ ជាដំបូង អាជ្ញាធរសាធារណៈអាចប្រើប្រាស់កងកម្លាំងច្រើនហួសហេតុ និងភាគីឯកជនមានសិទ្ធិ (ភ្នាក់ងារសន្តិសុខ) ក្នុងការអនុវត្តការបណ្តេញចេញ។ ក្នុងករណីមួយចំនួន សមាជិកនៃកងកម្លាំងប្រដាប់អាវុធ នគរបាល ឬភ្នាក់ងារសន្តិសុខឯកជន បានប្រើប្រាស់អំពើហិង្សាប្រឆាំងនឹងពលរដ្ឋដែលត្រូវគេបណ្តេញចេញ និង លួច ឬបំផ្លាញទ្រព្យសម្បត្តិរបស់ពួកគេ។ ការរំលោភបំពានធ្ងន់ធ្ងរត្រូវបានរាយការណ៍មកសមាគមអាដហុក ដោយពលរដ្ឋ ដែលត្រូវគេបណ្តេញចេញ និងក្រុមគ្រួសាររបស់ពួកគេ។

---

២៨ កថាខណ្ឌទីពីរចែងដូចតទៅ "ក្នុងករណីមានការជំទាស់ដល់ការផ្តល់ប័ណ្ណកម្មសិទ្ធិស្ថាពរនេះអ្នកតវ៉ាត្រូវយកភស្តុតាងមកបញ្ជាក់ថាខ្លួនឯងផ្ទាល់បានបំពេញលក្ខខណ្ឌនៃភោគៈដោយសន្តិវិធីនិងមិនមានការជំទាស់ចាប់ពី៥(ប្រាំ)ឆ្នាំនៅលើអចលនវត្ថុ ដែលមានទំនាស់ ឬយកភស្តុតាង ដែលថាខ្លួនបានទិញអចលនវត្ថុនោះពីភោគីដើមឬពីសិទ្ធិវន្តស្របច្បាប់ ឬអ្នកទទួលផ្ទេរកម្មសិទ្ធិ ឬពីសន្តតិជនរបស់ខ្លួន"។

២៩ សូមមើលអង្គការលីកាដូ(LICADHO)ការទន្ទ្រានយកដី និងភាពក្រីក្រនៅកម្ពុជា៖ជំនឿនៃការអភិវឌ្ឍន៍ (ឆ្នាំ២០០៩)។

៣០ សមាគមធាងត្នោត(STT), គ្រួសារដែលត្រូវបណ្តេញចេញ៖ភ្នំពេញឆ្នាំ១៩៩០-ឆ្នាំ២០១១, "អង្គហេតុនិងតួលេខ" ១៩ (ខែឧសភាឆ្នាំ២០១១).


ប្រជាជនកំពុងចេញពីភូមិប្រម៉ា (ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១២)

## ករណីសិក្សា៖ ភូមិប្រម៉ា និងការសម្លាប់កុមារី ហេងចន្ថា

នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២ កងកម្លាំងប្រដាប់ដោយអាវុធ AK-៤៧ បានឡោមព័ទ្ធ ភូមិប្រម៉ា ឃុំកំពង់ដំរី ស្រុកឆ្លូង ខេត្តក្រចេះ ដើម្បីបណ្ដេញប្រជាជនប្រមាណ១,០០០នាក់ចេញពីភូមិ។ រដ្ឋាភិបាលបានអះអាងថា ប្រជាពលរដ្ឋកំពុងរស់នៅលើដីនោះដោយខុសច្បាប់។ ទោះជាយ៉ាងនេះក្ដី ករណីនេះអាចជាប់ពាក់ព័ន្ធនឹងសម្បទានដីដាំកៅស៊ូដែលមានផ្ទៃដី ១៥,០០០ហិកតា នៅក្បែរខាងនោះ ដែលត្រូវបានផ្ដល់ឲ្យក្រុមហ៊ុន Casotim។ ក្នុងអំឡុងពេលបណ្ដេញចេញនោះ កុមារីម្នាក់ឈ្មោះ ហេងចន្ថា ត្រូវបានសម្លាប់ដោយទាហានម្នាក់ដែលអះអាងថា បានបាញ់ទៅលើមេឃ។ អាជ្ញាធរអះអាងថា អ្នកភូមិព្យាយាមធ្វើអបគមន៍ចេញពីកម្ពុជាដោយបង្កើតតំបន់គ្រប់គ្រងដោយខ្លួនឯង។ ទោះជាយ៉ាងក្ដី "ក្រុមអ្នកបង្កើតតំបន់អបគមន៍"ទាំងនោះ ពុំមានរចនាសម្ព័ន្ធ យោធា ឬរចនាសម្ព័ន្ធរដ្ឋបាល ដើម្បីគ្រប់គ្រងតំបន់នោះឡើយ។ អាវុធធុនស្រាល (ស្នានិងព្រួញ ដំបងនិងកាំបិត) ត្រូវបានគេរកឃើញក្នុងភូមិ ដែលតាមពិតឧបករណ៍ទាំងនេះ អ្នកភូមិប្រើប្រាស់សម្រាប់ប្រមាញ់សត្វ។ អ្នកអង្កេតការណ៍ឯករាជ្យជាតិ និងអន្តរជាតិ បានទាត់ចោលការចោទប្រកាន់ដែលថាមានចលនាអបគមន៍ក្នុងស្រុកឆ្លូង គឺមិនទំនងនិងជាកិច្ចខិតខំប្រឹងប្រែងមួយដើម្បីបង្វែរចំណាប់អារម្មណ៍ពីការទទួលខុសត្រូវរបស់អាជ្ញាធរ និងពីស្ថានភាពដីធ្លីទូទៅ។

ប្រជាពលរដ្ឋត្រូវបានអះអាងថា ធ្វើការជួសមុខឲ្យសមាគមអ្នកប្រជាធិបតេយ្យ (អង្គការមិន មែនរដ្ឋាភិបាលមួយដែលមានបំណងលើកកំពស់ការយល់ដឹង និងលើកទឹកចិត្តប្រជាពលរដ្ឋឲ្យប្រើប្រាស់សិទ្ធិដែលត្រូវបានការពារដោយច្បាប់របស់ខ្លួន) បានចូលមកក្នុងភូមិប៉ុន្មានខែមុនហើយបានរៀបចំជួយប្រជាជនឲ្យការពារសិទ្ធិដីធ្លីរបស់ពួកគេ។ ក្នុងខែមេសា ឆ្នាំ២០១២ ប៊ុនរដ្ឋាត្រូវបានចាប់ខ្លួន និងឃុំខ្លួនដ៏ខ្លី និងដោះលែង


*The Borei Keila eviction*
*(3 January 2012)*

វិញបន្ទាប់ពីមានការតវ៉ា និងបិទផ្លូវដោយអ្នកភូមិ។ នៅថ្ងៃទី១៥ ខែកក្កដា លោកម៉មសូណង់ដូ ម្ចាស់វិទ្យុសំបុកឃ្មុំ (FM ១០៥) និងប្រធាន សមាគមអ្នកប្រជាធិបតេយ្យ ត្រូវបានចាប់ខ្លួននៅគេហដ្ឋានរបស់គាត់នៅភ្នំពេញ។ ការចាប់ខ្លួនគាត់ធ្វើឡើង បន្ទាប់ពីសុន្ទរកថារបស់នាយករដ្ឋមន្ត្រី ហ៊ុនសែន ចោទប្រកាន់ថា សូណង់ដូ គឺទទួលខុសត្រូវធ្វើជាមេក្លោងនៅពីក្រោយគម្រោង «អបគមន៍» នៅភូមិប្រម៉ា។ ម៉មសូណង់ដូ ទើបត្រឡប់មកពីបរទេសបានបីថ្ងៃ មុនការចាប់ខ្លួនដោយដឹងខ្លួនថា គាត់ត្រូវបានគំរាមកំហែងជាមួយនឹងវិធានការផ្លូវច្បាប់។

នៅថ្ងៃទី១ ខែតុលា ម៉មសូណង់ដូ ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ ២០ឆ្នាំ ជាសាល ក្រម ដែលបណ្តាលឲ្យមានកំហឹងទាំងក្នុងស្រុក និងអន្តរជាតិ។ នៅថ្ងៃទី១៤ ខែធ្នូ តុលាការសាលាឧទ្ធរណ៍ បានច្រានចោលសំណើសុំនៅក្រៅឃុំរបស់គាត់។ បច្ចុប្បន្ន គាត់កំពុងរង់ចាំការជំនុំជម្រះនៅសាលាឧទ្ធរណ៍។ ពុំមានការស៊ើបអង្កេតទៅលើការសម្លាប់កុមារី ហេងចន្ថា ទេត្បិតអាជ្ញាធរបានប្រកាសថាពុំចាំបាច់ព្រោះការសម្លាប់នោះ គឺជា «ឧប្បត្តិហេតុ។ ដូច្នេះគ្មាននរណាម្នាក់ទទួលខុសត្រូវចំពោះការស្លាប់របស់នាងទេ។

---

ទី ពីរ ពលរដ្ឋ ដែលត្រូវគេបណ្តេញចេញតែងតែទទួលបានការជូនដំណឹងដ៏ខ្លីឲ្យចាកចេញពីលំនៅដ្ឋានរបស់ពួកគេ។ ក្នុងករណីខ្លះ ពលរដ្ឋដែលត្រូវគេបណ្តេញចេញពុំបានទទួលដំណឹងសោះ និងពុំទាំងមានពេលវេលាប្រមែប្រមូលទ្រព្យសម្បត្តិរបស់ពួកគេផង។ ការបណ្តេញចេញខ្លះទៀតត្រូវបានអនុវត្តនៅពេលយប់។ ទីបី ជាទូទៅ ទីតាំងសម្រាប់តាំងលំនៅដ្ឋានថ្មីគ្មានស្តង់ដារពោលគឺខ្វះខាតសេវាសាធារណៈជាមូលដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធ។ ចុងក្រោយ ជាទូទៅសំណងពុំមានយុត្តិធម៌ឡើយ។ ក្នុងករណីខ្លះ គឺពុំមានផ្តល់សំណងអ្វីទាំងអស់ បើពុំដូច្នេះទេ កញ្ចប់សំណងនោះ គឺទំនងជាគ្មានស្តង់ដារ។ ពលរដ្ឋដែលត្រូវគេបណ្តេញចេញទទួលសម្ពាធឲ្យទទួលដំណោះស្រាយមិនយុត្តិធម៌តាមរយៈយុទ្ធវិធីផ្សេងៗ។ ជួនកាល អាជ្ញាធរ និងអ្នកទន្ទ្រានយកដីអូសបន្លាយការចរចាដោយចេតនា ដើម្បីធ្វើឲ្យជនរងគ្រោះអស់សង្ឃឹម (ខណៈដែលជនរងគ្រោះមិនអាចនឹងមានពេលតវ៉ាបាន ពួកគេត្រូវបង្ខំចិត្តទទួលយកលក្ខខណ្ឌដែលដាក់ដោយពួកអ្នកទន្ទ្រានយកដី)។ តំណាងសហគមន៍ និងសកម្មជនដីធ្លីត្រូវបានចាប់ខ្លួន គំរាមកំហែង និងផ្តន្ទាទោស ក្នុងកិច្ចខិតខំប្រឹងប្រែងចាត់វិធានការសមូហភាព និងសាមគ្គីភាព (សូមមើលផ្នែក៣ខាងក្រោម)។

ប្រមាណ១៥០សហគមន៍កំពុងត្រូវបានគំរាមកំហែងឲ្យរើចេញពីលំនៅដ្ឋានរបស់ពួកគេ នៅរាជធានីភ្នំពេញ។ តួលេខនេះ រាប់បញ្ចូលទាំង អ្នកដែលបានទទួលលិខិតជូនដំណឹងអំពីការរើចេញមួយ ឬពីរច្បាប់ និងកំពុងស្ថិតក្នុងស្ថានភាពគំរាមកំហែងធ្ងន់ធ្ងរនៃការបណ្តេញចេញ (ប្រមាណ៥០សហគមន៍) និងប្រជាពលរដ្ឋ ដែលឮពាក្យចចាមអារ៉ាមអំពីការរើចេញ (ប្រមាណ១០០ទីតាំងលំនៅដ្ឋាន)។ ក្រុមទាំងពីរនេះត្រូវបានចាត់ទុកថា កំពុងប្រឈមមុខនឹងហានិភ័យ[៣១]។

បើទោះជាមានសំណើម្តងហើយម្តងទៀតពីស្ថាប័នអង្គការសហប្រជាជាតិ ដូចជាគណៈ-កម្មាធិការទទួលបន្ទុកផ្នែកសិទ្ធិវប្បធម៌ សង្គម និងសេដ្ឋកិច្ច និងអ្នករាយការណ៍ពិសេសអំពីសិទ្ធិទទួលបានលំនៅដ្ឋានគ្រប់គ្រាន់ក្តី ក៏ប្រទេសកម្ពុជានៅពុំទាន់បានអនុម័តទាំងច្បាប់ស្តីពីការបណ្តេញចេញ និងគោលនយោបាយលំនៅដ្ឋានថ្នាក់ជាតិនៅឡើយ។ ប៉ុន្តែលិខិតុបករណ៍ទាំងនេះនឹងមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការពង្រឹងដំណើរការដ៏ត្រឹមត្រូវ និងសន្តិសុខនៃការកាន់កាប់ដី។ លិខិតុបករណ៍ទាំងនេះអាចអនុញ្ញាតឲ្យអាជ្ញាធរដាក់ចេញជាយុទ្ធសាស្ត្រ ដើម្បីដោះស្រាយក្នុងចំណោមបញ្ហាផ្សេងៗទៀត គឺបញ្ហានៃភាពឥតដីធ្លី និងការតាំងលំនៅដ្ឋានក្រៅផ្លូវការ និងដាក់ចេញនូវការការពារសិទ្ធិមនុស្សដ៏ច្បាស់លាស់ស្របទៅតាមស្តង់ដារអន្តរជាតិ។ រហូតមកទល់ថ្ងៃនេះ ដោយរំលោភបំពានលើទាំងច្បាប់ជាតិ និងច្បាប់អន្តរជាតិ ការបណ្តេញចេញពីលំនៅដ្ឋាននៅកម្ពុជាបន្តកើតមានជាដំណោះស្រាយដំបូងបង្អស់ ពុំមែនជាដំណោះស្រាយចុងក្រោយទេ។

---

៣១ STT ការសិក្សាស្រាវជ្រាវដែលពុំបានបោះពុម្ព។

## ធនធានធម្មជាតិ

ក្នុងឆ្នាំ២០១២ សមាគមអាដហុកកាន់ករណីរាប់សិបនៃការទន្ទ្រានលើធនធានធម្មជាតិ រាប់បញ្ចូលទាំងការកាប់ឈើដោយខុសច្បាប់ ការនេសាទត្រីដោយខុសច្បាប់ និងការលក់ឡូត៍នេសាទត្រីដោយខុសច្បាប់។ ទាំងនេះរាប់បញ្ចូលទាំង យ៉ាងតិចណាស់ ករណី៦ដាច់ដោយឡែកនៃការកាប់ឈើក្នុងព្រៃសហគមន៍ដោយខុសច្បាប់ និងករណីច្រើនទៀត ទាក់ទិននឹងការទន្ទ្រានយកដីខ្នាតតូច និងខ្នាតធំ។ នោះគឺជាការកាប់ឈើដោយខុសច្បាប់ និងការទន្ទ្រានលើព្រៃ ទឹក និងជលផល ដោយក្រុមហ៊ុនឯកជន ស្ថាប័នរដ្ឋ (ដូចជា កងកម្លាំងប្រដាប់អាវុធ) ឬអាជ្ញាធរមូលដ្ឋាន។ រីឯការការទន្ទ្រានយកដីខ្នាតតូច និងខ្នាតធំគឺផ្សារភ្ជាប់នឹងគម្រោងអភិវឌ្ឍន៍ធំៗ ដូចជា សម្បទានដីនិងសម្បទានរុករកធនធានរ៉ែ។

បទប្បញ្ញត្តិផ្នែកបរិស្ថាន ដូចជា ច្បាប់ភូមិបាលដែលសមាគមអាដហុកដាក់បញ្ចូលក្នុងកម្មវិធីរបស់ខ្លួនស្តីពីការពង្រឹងអំណាចសហគមន៍ គឺពុំត្រូវបានអនុវត្តត្រឹមត្រូវឡើយ។ បទប្បញ្ញត្តិទាំងនេះពុំធានានូវការការពារសិទ្ធិរបស់ពលរដ្ឋកម្ពុជា ក្នុងការទទួលបានស្បៀងអាហារ ទឹក និងកម្រិតជីវភាពគ្រប់គ្រាន់ទេ។ បើទោះជា មានការផ្អាកបណ្តោះអាសន្នជាផ្លូវការស្តីពីការកាប់ឈើក្តីព្រៃឈើរបស់ប្រទេសកម្ពុជា កំពុងបាត់បង់យ៉ាងកំហុក។ ស្រទាប់ព្រៃឈើធំៗទទួលផលប៉ះពាល់ពីសម្បទានដី និងការកាប់ឈើ និងការធ្វើអាជីវកម្មខ្នាតតូច។



ការកាប់បំផ្លាញព្រៃឈើក្នុងសម្បទានរបស់ក្រុមហ៊ុនCRCK នៅក្នុងព្រៃឡង់

### ករណីសិក្សា៖ ការបំផ្លិតបំផ្លាញព្រៃឡង់

ក្រុមហ៊ុន CRCK ទទួលបានសម្បទាន ដែលមានផ្ទៃដី ៦,០៤៤ហិកតាក្នុងព្រៃឡង់ ដែលលាតសន្ធឹងលើខេត្តបួន (ខេត្តកំពង់ធំ ក្រចេះ ព្រះវិហារ និងខេត្តស្ទឹងត្រែង)។ ជាផ្លូវការក្រុមហ៊ុន CRCK ដាំកៅស៊ូ តែយ៉ាងណាមិញ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ពុំបានបំពេញនៅឡើយ ហើយក្រុមហ៊ុនបានចូលរួមកាប់ព្រៃឈើ និងបំផ្លាញស្រទាប់ព្រៃបឋមដែលមានស្លឹកខៀវគ្រប់រដូវ។ សហគមន៍កាន់តែព្រួយបារម្ភឡើងៗ អំពីការបំផ្លិតបំផ្លាញព្រៃឡង់ ហើយបានចលនាគ្នាដើម្បីការពារការប្រើប្រាស់ប្រកបដោយចីរភាពព្រៃនេះ។

នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១២ តំណាងសហគមន៍ចំនួន ២៤១នាក់ មកពីខេត្តបួន បានប្រមូលផ្តុំគ្នា ដើម្បីស៊ើបអង្កេតសកម្មភាពធ្វើអាជីវកម្មខុសច្បាប់ក្នុងព្រៃឡង់។ ពួកគេបានប្រទះឃើញឈើរាប់ ពាន់ដើម ស្ពាន និងគ្រឿងចក្រសម្រាប់កាប់ឈើនៅអូរឆ្នោលើ និងអូរឆ្នោក្រោម។ នៅថ្ងៃទី២៥ ខែមីនា អាជ្ញាធរ បានបញ្ជូនកងកម្លាំង និងចាប់សកម្មជនសិទ្ធិមនុស្ស (រួមទាំងលោកឈុតវុទ្ធី) និងតំណាង សហគមន៍ ដែលបានដុតឈើ។ នៅថ្ងៃទី២៧ ខែមីនា តំណាងសហគមន៍ ១៣២នាក់ បានជួបគ្នានៅភូមិបឹង ឃុំមានរិទ្ធិ ស្រុកសណ្តាន់ ខេត្តកំពង់ធំ។ ពួកគេមានបំណងតវ៉ា និងបិទផ្លូវនៅថ្ងៃបន្ទាប់។

នៅថ្ងៃទី២៨ ខែមីនា ពួកគេបានបំបែកគ្នាជាច្រើនក្រុម ដើម្បីស៊ើបអង្កេតសកម្មភាពរបស់ក្រុមហ៊ុន CRCK និង

ក្រុមហ៊ុន សេងសារ៉ាវុធ ជាក្រុមហ៊ុនមួយទៀត ដែលទទួលបានសម្បទានដីសេដ្ឋកិច្ចក្នុងតំបន់ព្រៃឡង់។ ឈុតវុទ្ធី ត្រូវបានគេគំរាមបាញ់។ ប្រជាពលរដ្ឋ ក៏ត្រូវបានបំភិតបំភ័យដោយអាជ្ញាធរខេត្ត ដែលចោទប្រកាន់ថា សកម្មភាពរបស់ពួកគាត់គឺ ៉ប្រឆាំងនឹងរដ្ឋាភិបាល។

---

ដូចគ្នាដែរ ជលផលទទួលផលប៉ះពាល់ពីការបំពុល និងប្រតិបត្តិការសហគ្រាសអាជីវកម្ម និងដោយការលក់ឡូត៍នេសាទដោយខុសច្បាប់ ដោយអាជ្ញាធរសាធារណៈ។ សមាគមអាដហុកបានដាក់បញ្ចូលបទប្បញ្ញត្តិទាក់ទងនឹងជលផលក្នុងកម្មវិធីបណ្តុះបណ្តាលរបស់ខ្លួន ដូច្នេះប្រជា ពលរដ្ឋអាចកាន់តែយល់ដឹងអំពីក្របខណ្ឌច្បាប់និងអាចប្រតិកម្មក្នុងពេលមានការរំលោភបំពានកើតឡើង។ ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែង ពួកគេជួបនឹងបញ្ហាប្រឈមយ៉ាងច្រើនក្នុងការការពារការចិញ្ចឹមជីវិតរបស់ពួកគេ។

ជនជាតិដើមភាគតិចទទួលការគំរាមកំហែងយ៉ាងពិសេស ដោយគម្រោងសាងសង់ទំនប់ធំៗ ដូចជាគម្រោងទំនប់វារីអគ្គិសនីខ្នាតធំក្នុងខេត្ត នៅប៉ែកឦសាននៃផ្ទៃប្រទេស។ ហានិភ័យទាំងនេះប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើការចិញ្ចឹមជីវិត និងរបៀបរស់នៅរបស់សហគមន៍រស់នៅតាមបណ្តោយទន្លេ ដោយបណ្តេញពួកគេចេញពីទឹកដីដូនតា និងធ្វើឲ្យលិចលង់ព្រៃឈើ និងដីដាំដុះរាប់ពាន់ហិកតា។ ស្ទឹងត្រែងកំពុងប្រឈមនឹងហានិភ័យ ដែលត្រូវគំរាមកំហែងបន្ថែមទៀត ដោយគម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗ ដូចជាទំនប់សាយ៉ាបូរី នៅប្រទេសឡាវ។

## សេចក្តីសន្និដ្ឋាន

*ភាពខុសគ្នា ដែលសមាគមអាដហុកបានកត់សម្គាល់ (ប្រជាពលរដ្ឋកាន់តែមានសមានចិត្តចាត់វិធានការ ដើម្បីការពារសិទ្ធិរបស់ពួកគេ ប៉ុន្តែតិចតួចណាស់ដែលទទួលបានដីធ្លីពួកគេវិញ ឬសំណងសមស្រប) បង្ហុលបង្ហាញថាស្ថានភាពដីធ្លី កំពុងតែមានលក្ខណៈធ្ងន់ធ្ងរឡើងៗ។ ប្រជាពលរដ្ឋ និងសហគមន៍កំពុងកាន់តែយល់ដឹងអំពីសិទ្ធិ និងមធ្យោបាយផ្លូវច្បាប់ ដើម្បីការពារខ្លួនពួកគេ។ ពួកគេកាន់តែទាមទារនូវយុត្តិធម៌ និងការទទួលខុសត្រូវ។ ទោះជាយ៉ាងនេះក្តីដីធ្លីកាន់តែកម្រ ហើយអាជ្ញាធរខកខានតម្កល់សិទ្ធិរបស់ប្រជាពលរដ្ឋ នៅពេលដែលពួកគេចូលរួមក្នុងវិវាទ ពាក់ព័ន្ធនឹងអតុល្យភាពខ្លាំងពេកនៃអំណាចរវាងភាគី។*

*ច្បាប់ចាំបាច់ត្រូវតែពង្រឹងការអនុវត្តឲ្យបានកាន់តែប្រសើរឡើង និងការធានានូវដំណើរការដ៏ត្រឹមត្រូវ ចាំបាច់ត្រូវតែតម្កល់ នៅគ្រប់កម្រិតនៃរាជរដ្ឋាភិបាលនិងរដ្ឋបាល។ បញ្ហាបច្ចុប្បន្នបណ្តាលឲ្យមានការជះឥទ្ធិពលអវិជ្ជមានធ្ងន់ធ្ងរលើសន្តិសុខកាន់កាប់ដីធ្លី កម្រិតជីវភាព ការចិញ្ចឹមជីវិត ធនធានធម្មជាតិនិងសិទ្ធិវប្បធម៌។ ប្រសិនបើ បញ្ហាទាំងនេះពុំត្រូវបានដោះស្រាយជាបញ្ហាអាទិភាពទេនោះ ស្ថេរភាពសង្គមអាចនឹងរង្គោះរង្គើ។*

# ២. ផលប៉ះពាល់អវិជ្ជមាន និងផលវិបាកផ្សេងៗ

## ក. អសន្តិសុខនៃការកាន់កាប់ដីធ្លី

សន្តិសុខនៃការកាប់ដីធ្លីគឺជាការចាំបាច់បំផុតក្នុងការធានាដល់សិទ្ធិកាន់កាប់ដីធ្លី និងសិទ្ធិលំនៅឋាន។ យោងតាមច្បាប់អន្តរជាតិ ការលើកកម្ពស់សន្តិសុខក្នុងការកាន់កាប់ដីធ្លីគឺជាកាតព្វកិច្ចយ៉ាងចាំបាច់របស់រដ្ឋ។ ដូច្នេះ ច្បាប់ជាតិគួរមានបញ្ញត្តិវិធានការនានាដែល "ធានាឲ្យមានសន្តិសុខដល់អ្នកកាន់កាប់លំនៅដ្ឋាន និងដីធ្លីឲ្យបានល្អបំផុតតាមដែលអាចធ្វើបាន [និង] គ្រប់គ្រងកាលៈទេសៈឲ្យបានតឹងរឹងដែលអាចមានការបណ្តេញចេញពីលំនៅដ្ឋាន និងដីធ្លី"[៣២]។ ស្ថាប័នរៀបចំបទដ្ឋានមួយចំនួនបានទទួលស្គាល់ថា ការកាន់កាប់កន្លែងមួយអាចមានទម្រង់ច្រើនយ៉ាង មានជាអាទិ៍ ភាពជាម្ចាស់ ការជួល ឬការតាំងលំនៅដ្ឋានក្នុងគ្រាមានអាសន្ន និងការតាំងទីលំនៅមិនផ្លូវការ។ "ថ្វីបើការកាន់កាប់កន្លែងមួយមានច្រើនប្រភេទដូចនេះក្តី មនុស្សគ្រប់រូបគួរមានសន្តិសុខនៃការកាន់កាប់ក្នុងកម្រិតមួយដែលមានការធានាពីផ្លូវច្បាប់ប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ ការបៀតបៀន និងការគំរាមកំហែងផ្សេងៗទៀត"[៣៣]។ ហើយប្រសិនបើ រដ្ឋត្រូវការដីធ្លីដើម្បីអភិវឌ្ឍ វិធានការមួយចំនួន (ដូចជា ការគ្មានការរើសអើង) ត្រូវតែយកមកអនុវត្តជាបន្ទាន់[៣៤]។

ជារួម ប្រទេសកម្ពុជាខកខានក្នុងការធានាសិទ្ធិមានសន្តិសុខកាន់កាប់ដីធ្លីរបស់ប្រជាពលរដ្ឋ។ បើទោះបីជាមានការចេញប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុរាប់សែនក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងនេះក៏ដោយ[៣៥] ក៏កម្មវិធីផ្តល់កម្មសិទ្ធិដីធ្លីដែលបានអនុវត្តជាបន្តបន្ទាប់កន្លងមកមិនបានឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋដែលត្រូវការសន្តិសុខក្នុងការកាន់កាប់ដីធ្លីបំផុតនោះទេ ដូចជាប្រជាពលរដ្ឋដែលតាំងទីលំនៅដ្ឋានក្រៅផ្លូវការ និងក្នុងតំបន់មានវិវាទ រួមទាំងជនជាតិដើមភាគតិច។ កង្វះខាតភាពច្បាស់លាស់ជុំវិញស្ថានភាពដីធ្លី ខកខានក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិ កង្វះការធានាទប់ទល់នឹងការបណ្តេញចេញដោយបង្ខំ កង្វះការទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមភាគតិច និងកង្វះខាតឧបាស្រ័យប្រកបដោយប្រសិទ្ធភាព គឺជាការរួមចំណែកដល់បរិយាកាសរួមនៃអសន្តិសុខក្នុងការកាន់កាប់ដីធ្លី។

ប្រទេសកម្ពុជាមានសាវតារមានបញ្ហា។ របបខ្មែរក្រហមមិនត្រឹមតែទទួលខុសត្រូវលើឧក្រិដ្ឋកម្ម និងអំពើឃោរឃៅយ៉ាងរង្គាលប៉ុណ្ណោះទេ តែរបបនេះថែមទាំងបង្កឧបសគ្គដល់ទំនាក់ទំនងក្នុងសង្គមកម្ពុជា។ រហូតដល់ឆ្នាំ ១៩៧៩ ការរៀបចំផ្តល់កម្មសិទ្ធិដីធ្លីផ្លូវការត្រូវរងការបំផ្លិចបំផ្លាញទាំងស្រុង។ គេត្រូវតែទទួលស្គាល់ថា ស្ថានភាពដីធ្លីបច្ចុប្បន្ន គឺជាផលវិបាកនៃសោកនាដកម្មនេះ។ ទោះជាយ៉ាងនេះក្តី អសន្តិសុខនៃការកាប់ដីធ្លីក៏ជាផលវិបាកនៃគោលនយោបាយដីធ្លី *នាពេលបច្ចុប្បន្ន* ដែលបានធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ប្រជាពលរដ្ឋដែលត្រូវប្រានចូលស្ថានភាពគ្មានសិទ្ធិអំណាច។

## ខ. ភាពគ្មានដីធ្លី ភាពក្រីក្រ និងបញ្ហាពាក់ព័ន្ធ

ភាគរយនៃប្រជាពលរដ្ឋកម្ពុជាកាន់តែច្រើនឡើងដែលគ្មានដីគ្មានដីធ្លី[៣៦]។ ដើមចមដែលធ្វើឲ្យគ្មានដីធ្លីនេះមានជាអាទិ៍ កំណើនប្រជាពលរដ្ឋ និងការកែប្រែជាសន្សឹមៗពីសេដ្ឋកិច្ចពឹងផ្អែកលើកសិកម្មទៅជាសេដ្ឋកិច្ចពឹងផ្អែកលើឧស្សាហកម្ម និងសេវា ប៉ុន្តែពុំមានគោលនយោបាយសេដ្ឋកិច្ចនិងដីធ្លីច្បាស់លាស់។ សម្បទានដីសេដ្ឋកិច្ចនិងការទន្ទ្រានយក

---

៣២ គណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, យោបល់ទូទៅ លេខ ៧, op. cit., កថាខណ្ឌ ៩។

៣៣ គណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, យោបល់ទូទៅ លេខ ៤, op. cit., កថាខណ្ឌ ៨(ក)។

៣៤ ដូចខាងលើ កថាខណ្ឌ ១០។

៣៥ រហូតមកដល់ខែវិច្ឆិកា ឆ្នាំ២០១១ ដំណើរការចុះបញ្ជីកម្មសិទ្ធិដីធ្លីជាលក្ខណៈប្រព័ន្ធ បានផ្តល់បណ្ណកម្មសិទ្ធិដីធ្លីចំនួន ១.៧៤០.៨៣៩ (LSSAP, ដីជាជីវិត ៖ ព្រឹត្តិបត្រព័ត៌មានអនុកម្មវិធីគ្រប់គ្រងដីធ្លី, ច្បាប់ចេញផ្សាយលេខ ២ (ខែវិច្ឆិកា ឆ្នាំ២០១១)។ មើល ឯកសារគោលជំហររបស់អង្គការមិនមែនរដ្ឋាភិបាលស្តីពីការអភិវឌ្ឍកម្ពុជា នៅឆ្នាំ ២០១០ ដល់ឆ្នាំ ២០១២ ៖ ត្រួតពិនិត្យការអនុវត្តផែនការអនុវត្តយុទ្ធសាស្ត្រជាតិ និងសុចនាករត្រួតពិនិត្យរួម CDCF ឆ្នាំ២០១០ (ថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ២០១២), ទំព័រ ៧៣។

៣៦ យោងតាមធនធាគារពិភពលោក ភាគរយនៃប្រជាជនគ្មានដីធ្លីបានកើនឡើងពី ១៣% ទៅ២៥% នៅឆ្នាំ២០០៧។

ដីធ្លីបានបង្ខំប្រជាពលរដ្ឋឲ្យចេញពីដីកសិកម្មរបស់គេ ដោយមិនបានផ្ដល់ឱកាសឲ្យបានគ្រប់គ្រាន់ដើម្បីទទួលបានដីនៅកន្លែងផ្សេងៗទៀត។ ទង្វើដូចនេះគឺជាកង្វល់មួយនៅពេលមានកំណើនប្រជាសាស្ត្រ។ សំណួរនៅពេលនេះគឺថា តើប្រទេសកម្ពុជាមានដីគ្រប់គ្រាន់ឬទេ សម្រាប់មនុស្សជំនាន់ក្រោយ នៅពេលដីដែលមានអំណោយផលខាងកសិកម្មស្ទើរតែពាក់កណ្ដាលស្ថិតក្នុងកណ្ដាប់ដៃសម្បទានិកឯកជនរហូតដល់ ៩៩ ឆ្នាំនោះ?

ការអភិវឌ្ឍកសិ-ឧស្សាហកម្ម និងកំណើនផលិតភាពកសិកម្មអាចដំណើរការបាន ប្រសិនបើមានការគ្រប់គ្រង និងត្រួតពិនិត្យសម្បទាដីធ្លីឲ្យបានល្អនោះ។ ទោះជាយ៉ាងនេះក្ដី ការអភិរក្សដីសម្រាប់កសិករដែលកាន់កាប់ទំហំដីតូចៗរបស់ខ្លួនគឺជាការចាំបាច់។ ផ្អែកលើទស្សនៈមួយនៃកិច្ចអភិវឌ្ឍការបន្តអភិរក្សទំហំដីតូចៗ និងក្រុមហ៊ុនឯកជនដែលផ្ដល់ពូជ និងការបណ្ដុះបណ្ដាលដល់កសិករ និង/ឬកែច្នៃផលិតផលសម្រាប់នាំចេញ អាចផ្ដល់ផលប្រយោជន៍ច្រើនជាងយុទ្ធសាស្ត្រដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន។ គំរូជាជម្រើសមួយនេះអាចបង្កើតការងារបង្កើនផលិតភាព និងចែករំលែកកំណើនកាន់តែមានសមភាព។ យោងតាមធនាគារពិភពលោក “យោងតាមការសង្កេត គ្រួសារនៅតាមជនបទក្នុងប្រទេសកម្ពុជាហាក់ដូចជាមានទំហំតូច ប៉ុន្តែគឺជាអ្នកផលិតលើផ្នែកកសិកម្មយ៉ាងមានប្រសិទ្ធភាព។ ការវិភាគមួយចំនួនឆ្លុះបញ្ចាំងថា [...] ទំហំដីកសិកម្មតូចៗអាចផលិតបានផលច្រើនជាដីកសិកម្មទំហំធំនៅពេលធ្វើការវាស់វែងពីប្រាក់ចំណូលពីផលិតផលទិន្នផល ប្រយោជន៍ ឬតម្លៃពីផលិតផលផ្សេងៗទៀតក្នុងមួយហិកតា”។ អាស្រ័យហេតុនេះ “គួរមានការគាំទ្រដល់ការធានាឲ្យមានការកាន់កាប់ដីក្នុងទំហំតូចៗ ជាជាងការកាន់កាប់ដីទំហំធំជាលក្ខណៈពាណិជ្ជកម្ម ដោយធ្វើការសន្មតថាជាមូលដ្ឋានគ្រឹះនៃរចនាសម្ព័ន្ធកសិកម្មកម្ពុជា”[៣៧]។ យើងអាចនិយាយម្យ៉ាងទៀតថាការអនុវត្តកសិកម្មជាលក្ខណៈគ្រួសារតូចៗដោយមានការលើកកម្ពស់សន្តិសុខក្នុងការកាន់កាប់ដីធ្លីអាចជួយកាត់បន្ថយភាពក្រីក្របានលឿន។

នៅពេលបច្ចុប្បន្នបញ្ហាមួយចំនួនបង្កឲ្យមានការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ។ ទីមួយ សហគមន៍ជនជាតិដើមភាគតិចប្រឈមនឹងឧបសគ្គធំធេង ក្នុងការទទួលស្គាល់ថាជាក្រុមស្របច្បាប់ និងចុះបញ្ជីដីធ្លីរបស់ខ្លួនជាកម្មសិទ្ធិសមូហភាព។ រហូតដល់ចុងឆ្នាំ២០១២ មានសហគមន៍ជនជាតិដើមភាគតិចចំនួនបីប៉ុណ្ណោះ (ក្នុងខេត្តរតនគិរី និងមណ្ឌលគិរី) ដែលបានទទួលកម្មសិទ្ធិដីធ្លីជាលក្ខណៈសមូហភាព។ សហគមន៍ជនជាតិដើមភាគតិចផ្សេងៗទៀតកំពុងប្រឈមនឹងការបាត់បង់ដីធ្លីជាប្រពៃណីរបស់ខ្លួន។ ប្រសិនបើ គ្មានការចាត់វិធានការជាបន្ទាន់ដើម្បីការពារសិទ្ធិរបស់ពួកគេទេនោះ សហគមន៍ជនជាតិដើមភាគតិចកាន់តែច្រើនឡើង ប្រឈមមុខនឹងការបាត់បង់ដីធ្លី ដោយសារតែសម្បទានដីសេដ្ឋកិច្ច អ្នកទន្ទ្រានយកដីធ្លី និងអ្នកកាប់ឈើ។ ទីពីរ ពលរដ្ឋដែលត្រូវគេបណ្ដេញចេញប្រឈមមុខទៅនឹងបញ្ហាជាច្រើន ក្រៅពីបញ្ហាបាត់បង់កម្មសិទ្ធិនោះ។ ជាញឹកញាប់ពួកគាត់ពុំមានទឹកស្អាត សម្រាប់ប្រើប្រាស់ពុំមានអនាម័យក្នុងកន្លែងរស់នៅ និងពុំមានអគ្គិសនីប្រើប្រាស់។ នៅក្នុងករណីខ្លះ បើទោះបីជាពួកគាត់ត្រូវបានបណ្ដេញចេញទៅកន្លែងថ្មីរយៈពេល៦ឆ្នាំហើយក៏ដោយ ក៏អាជ្ញាធរបានទាន់បានផ្ដល់សេវាជាចាំបាច់ដល់ពួកគាត់នៅឡើយ។ ប្រជាពលរដ្ឋទាំងនេះត្រូវបង្ខំចិត្តទិញទឹកពីអណ្ដូងឯកជន និងភ្លើងអគ្គិសនីពីអ្នកផ្គត់ផ្គង់អគ្គិសនីនៅតាមមូលដ្ឋាន។ ទីបីប្រជាពលរដ្ឋដែលរងការបណ្ដេញចេញពីតំបន់តាំងទីលំនៅដ្ឋានក្នុងក្រុងទៅកាន់តំបន់តាំងទីលំនៅដ្ឋានថ្មី ជាញឹកញាប់ប្រឈមទៅនឹងបញ្ហាការងារអប់រំ និងសកម្មភាពរកប្រាក់ចំណូលផ្សេងៗទៀត។ ឧទាហរណ៍ ភូមិអណ្ដូង (ដែលជាកន្លែងតាំងទីលំនៅថ្មីរបស់អតីតប្រជាពលរដ្ឋសហគមន៍ពីទន្លេបាសាក់) មានចម្ងាយប្រមាណជា២០គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ ភ្នំបាត (ដែលជាតំបន់តាំងទីលំនៅដ្ឋានថ្មីរបស់អតីតប្រជាពលរដ្ឋពី

៣៧ ធនាគារពិភពលោក, កម្ពុជា ៖ តើអាចកាត់បន្ថយភាពក្រីក្រចំនួនពាក់កណ្ដាលត្រឹមឆ្នាំ ២០១៥ដែរឬទេ? ការវាយតម្លៃពីភាពក្រីក្រ ឆ្នាំ២០០៦ ទំព័រ ៨៧។

ដីក្រហម និងបុរីកីឡា ) មានចម្ងាយ៤០គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ យោងតាមការសិក្សាស្រាវជ្រាវរបស់ក្រុមការងារសិទ្ធិលំនៅដ្ឋាន (HRTF) ដែលមានមូលដ្ឋានក្នុងទីក្រុងភ្នំពេញ[៣៨] បំណុលជាមធ្យមរបស់គ្រួសារបន្ទាប់ពីបណ្តេញពីលំនៅដ្ឋានមានចំនួន៨៦៩ដុល្លារ (ដែលគ្រួសារទាំងនេះមានបំណុលជាមធ្យមតែ៤៥៥ដុល្លារប៉ុណ្ណោះនៅមុនពេលបណ្តេញពីលំនៅដ្ឋាន )។ ដូចគ្នានេះដែរ មានសាលារៀនចំនួនតិចតួចប៉ុណ្ណោះដែលមានទីតាំងស្ថិតនៅក្នុង ឬនៅជិតតំបន់តាំងទីលំនៅដ្ឋានថ្មីទាំងនេះប៉ុណ្ណោះ។ កុមារជាច្រើននាក់បានបោះបង់ការសិក្សា ហើយកុមារដែលអាចបន្តការសិក្សារបស់ខ្លួនទំនងជាមានបញ្ហាក្នុងការរៀនត្រួតថ្នាក់[៣៩]។ ទីបួន សុខភាពរបស់ប្រជាពលរដ្ឋ ដែលត្រូវបានបណ្តេញចេញពីលំនៅដ្ឋានដោយបង្ខំត្រូវរងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។ គ្រួសារភាគច្រើន ដែលត្រូវបានបណ្តេញចេញពីលំនៅដ្ឋានមានបញ្ហាជំងឺ ឬមានរបួស ក្នុងរយៈពេល៣ខែមុនពេលធ្វើការស៊ើបអង្កេតរបស់ HRTF ហើយគ្រួសារភាគច្រើនមានអារម្មណ៍ថា សុខភាពរបស់សមាជិកគ្រួសារមិនល្អឡើយ[៤០]។


ការតាំងទីលំនៅដ្ឋានថ្មីរបស់អតីតប្រជាពលរដ្ឋបុរីកីឡាដែលគ្មានឯកសារត្រឹមត្រូវ

## ករណីសិក្សា ៖ តំបន់តាំងលំនៅដ្ឋានថ្មីភ្នំបាត

ភ្នំបាត គឺជាកន្លែងតាំងទីលំនៅថ្មីរបស់អតីតប្រជាពលរដ្ឋពីសហគមន៍ដីក្រហម និងបុរីកីឡា មានទីតាំងស្ថិតនៅជិតឧត្តុងត្រង់ព្រំប្រទល់រវាងខេត្តកណ្តាល និងខេត្តកំពង់ស្ពឺ។ គ្រួសារចំនួន ៣០៥គ្រួសាររស់នៅក្នុងតំបន់តាំងទីលំនៅថ្មីនេះ (ក្នុងនោះ ១២៥គ្រួសារ មកពីសហគមន៍ដីក្រហម (ពីដំបូងមានចំនួន ៤៦៧) ១៥០គ្រួសារ មកពីបុរីកីឡា និង ៣០គ្រួសារផ្សេងទៀត ដែលគ្មានឯកសារបញ្ជាក់ត្រឹមត្រូវមកពីបុរីកីឡា )។

អតីតប្រជាពលរដ្ឋពីតំបន់ដីក្រហមនេះ បានតាំងទីលំនៅៗឃុំភ្នំបាត ខេត្តកណ្តាល កាលពី៣ឆ្នាំមុន។ នៅពេលនេះ ប្រជាពលរដ្ឋទាំងនេះហៅខ្លួនឯងថា "សមាគមតង់ខៀវ។ ពួកគាត់ប្រើប្រាស់ធនធានផ្ទាល់ខ្លួនដើម្បីសាងសង់បង្គន់ និងប្រព័ន្ធចម្រោះទឹក។ រហូតដល់ពេលនេះ អង្គការមិនមែនរដ្ឋាភិបាលបានសាងសង់ប្រព័ន្ធអនាម័យ និងប្រព័ន្ធបង្ហូរទឹកសំណល់ និងបានសាងសង់ផ្ទះចំនួន ៥៨ខ្នង។ ភូមិ

៣៨ ផលប៉ះពាល់សេដ្ឋកិច្ចសង្គមពីការបណ្តេញចេញពីលំនៅដ្ឋាននៅកម្រិតគ្រួសារ ក្នុងរាជធានីភ្នំពេញ (២០១១), ទំព័រ ១៤ (អាចអានបាននៅ http://www.hrtfcambodia.org/files/SEI_of_Force_Eviction_Report_ENG.pdf).
៣៩ ដូចខាងលើទំព័រ ១៥។
៤០ ដូចខាងលើ ទំព័រ ១៦។

នេះ មានមណ្ឌលសុខភាពតូចមួយ ដែលទទួលបានការឧត្ថម្ភជាថវិកាពីអង្គការមិនមែនរដ្ឋាភិបាលមួយ។ ភូមិនេះស្ថិតនៅចម្ងាយប្រមាណជា៣ទៅ ៤គីឡូម៉ែត្រពីសាលាបឋមសិក្សា និង ៦គីឡូម៉ែត្រ ពី សាលា មធ្យមសិក្សា។ ប្រជាពលរដ្ឋរស់នៅក្នុងភូមិនេះ ប្រើប្រាស់អគ្គិសនីដោយត្រូវចំណាយប្រាក់ប្រមាណជា១២០០រៀងក្នុងមួយគីឡូវ៉ាត់ម៉ោងទៅក្រុមហ៊ុនផ្គត់ផ្គង់អគ្គិសនីឯកជនមួយ (បើប្រៀបធៀបនឹងការចំណាយត្រឹមតែចំនួន ៨២០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោងទៅឲ្យក្រុមហ៊ុនអគ្គិសនីរដ្ឋក្នុងទីក្រុងភ្នំពេញ (Électricité du Cambodge))។ មនុស្សពេញវ័យភាគច្រើនបំផុត បានចាកចេញពីកន្លែងតាំងទីលំនៅថ្មីនេះ ដើម្បីទៅរកការងារធ្វើក្នុងទីក្រុងភ្នំពេញ និងទីប្រជុំជនផ្សេងៗទៀត។

កាលពីមួយឆ្នាំមុន អតីតប្រជាពលរដ្ឋពីសហគមន៍បុរីកីឡាបានតាំងទីលំនៅក្នុងចម្ងាយពីរឬបីគីឡូម៉ែត្រពីកន្លែងតាំងទីលំនៅថ្មីនេះ ស្ថិតក្នុងខេត្តកំពង់ស្ពឺ។ ដោយសារភូមិនេះគ្មានភ្លើងអគ្គិសនី និងគ្មានទឹកម៉ាស៊ីន នោះទើបប្រជាពលរដ្ឋក្នុងភូមិត្រូវពឹងផ្អែកលើភ្លើងអាគុយ និងអណ្តូងទឹក។ ប្រជាពលរដ្ឋពេញវ័យជាច្រើននាក់ពីភូមិនេះ ទៅធ្វើការងារនៅទីក្រុងភ្នំពេញ ដែលមានចម្ងាយចំនួន៤៦គីឡូម៉ែត្រ ហើយបានទុកឪពុកម្តាយ និងកូនរបស់ខ្លួនឲ្យនៅចាំផ្ទះ។ ពួកគេមានការងារ ជាកម្មកររោងចក្រសម្លៀកបំពាក់ អ្នកបោសសម្អាត ឬជាអ្នកលក់ដូរតូចតាចតាមចញ្ចើមផ្លូវ។ អ្នកខ្លះអាចវិលត្រឡប់មកផ្ទះវិញ ដើម្បីសួរសុខទុក្ខសាច់ញាតិមួយដងប៉ុណ្ណោះក្នុងមួយខែ ពីព្រោះតែការចំណាយសម្រាប់ការធ្វើដំណើរទៅមក មានចំនួន ២០.០០០រៀល។ ដើម្បីបំពេញសេចក្តីត្រូវការរបស់ខ្លួន ស្ត្រីមួយចំនួនដេរខ្មើយ ឬសំលៀកបំពាក់ ដើម្បីទ្រទ្រង់គ្រួសារ ប៉ុន្តែពួកគេត្រូវធ្វើដោយដៃ ពីព្រោះម៉ាស៊ីនដេររបស់ពួកគេត្រូវរងការបំផ្លិចបំផ្លាញក្នុងអំឡុងពេលនៃការបណ្តេញចេញពីលំនៅដ្ឋាននៅបុរីកីឡា (ថ្ងៃទី៣ ខែមករា ឆ្នាំ២០១២)។ កូនរបស់ប្រជាពលរដ្ឋក្នុងក្រុមនេះអាចទៅរៀននៅក្នុងសាលាជាមួយនឹងកូនរបស់ប្រជាពលរដ្ឋមកពីសមាគមតង់ខៀវដែរ។ ទោះជាយ៉ាងនេះក្តី សាលាទាំងនេះមានចំនួនសិស្សច្រើនហួសហេតុ និងពុំមានមូលនិធិគ្រប់គ្រាន់ដើម្បីតំណើរការឡើយ។ ក្នុងរយៈពេល ៦ខែដំបូង ប្រជាពលរដ្ឋចាំបាច់ត្រូវទឹកស្អាត ដើម្បីប្រើប្រាស់ដែលមានតម្លៃ៥០០រៀល ក្នុងមួយធុងចំណុះ១៥លីត្រ (បើប្រៀបធៀបនឹងតម្លៃទឹករបស់រដ្ឋករទឹកស្វយ័តក្រុងភ្នំពេញដែលមានតម្លៃរវាង ពី៥៥០ និង ១០១០រៀលក្នុងមួយម៉ែត្រគីប ដែលតម្លៃនេះថោកជាងប្រមាណជាពី ៣០ ទៅ ៦០ដងនៃតម្លៃទឹករបស់ប្រជាពលរដ្ឋក្នុងភូមិ)។ ប៉ុន្តែនោះពេលនេះ ប្រជាពលរដ្ឋក្នុងភូមិនេះ ប្រើប្រាស់ទឹកពីអណ្តូងទឹកសាធារណៈចំនួនបីដោយពុំចាំបាច់បង់ប្រាក់ឡើយ។

ក្រៅពីប្រជាពលរដ្ឋ ដែលត្រូវបានបញ្ជូនឲ្យទៅរស់នៅក្នុងភូមិនេះជាផ្លូវការ គ្រួសារដែលពុំមានឯកសារជាផ្លូវការចំនួន ៣០គ្រួសារមកពីបុរីកីឡា (គ្រួសារចំនួន១០ក្នុងចំណោមគ្រួសារទាំងនេះ គឺជាគ្រួសាររស់នៅជាមួយមេរោគអេដស៍/ជំងឺអេដស៍) បានស្នាក់នៅក្នុងភ្នំបាតនេះដែរ ដោយគ្រួសារទាំងនេះបានបាត់គ្រប់យ៉ាងទាំងអស់ (រួមមានសំលៀកបំពាក់ និងសម្ភារៈប្រើប្រាស់ក្នុងផ្ទះបាយ) ក្នុងអំឡុងពេលនៃការ បណ្តេញចេញពីលំនៅដ្ឋាន។ ពួកគេមិនបានទទួលជំនួយសោះឡើយពីអាជ្ញាធរ។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បានផ្តល់អាហារ និងថ្នាំពេទ្យដល់គ្រួសារទាំងនេះ។ មនុស្សពេញវ័យមួយចំនួនធ្វើការងារជាអ្នករើសសំរាម ឬជាអ្នកបោសសម្អាត។ គ្រួសារដែលបន្តរស់នៅភ្នំបាតរស់នៅក្នុងស្ថានភាពយ៉ាងវេទនាដូចគ្នានឹងជនភៀសខ្លួនដែរ។

---

ក្រៅពីនេះក្រៅពីបញ្ហាជីវភាពរស់នៅ ក្នុងឆ្នាំ២០១២ ប្រជាពលរដ្ឋក្នុងក្រុងបានទទួលរងគ្រោះពីទឹកជំនន់ជាញឹកញាប់ ដែលទឹកជំនន់នេះអាចបណ្តាលមកពីការចាក់បំពេញដីនៅបឹងកក់ដើម្បីយកដីទៅបម្រើគម្រោងលំនៅដ្ឋាន និងមជ្ឈមណ្ឌលពាណិជ្ជកម្ម។ តាមពិត បឹងនេះមិនអាចបំពេញមុខងារជាអាងស្តុកទឹកធម្មជាតិទៀតឡើយ។ ទឹកជំនន់ និងទឹកលាយភក់ដក់មិនប្រែប្រួលអាចបង្កឲ្យមានជំងឺមួយចំនួនដូចជាជំងឺគ្រុនឈាមជំងឺរាគ ឬជំងឺអាសន្នរោគ។ ក្រៅពីបញ្ហាទាំងនេះ បឹងផ្សេងៗទៀតក្នុងក្រុង (ដូចជាបឹងទំពុន) ក៏គ្រោងនឹងចាក់ដីបំពេញផងដែរ។

នៅតាមតំបន់ជនបទ ប្រជាពលរដ្ឋដែលត្រូវបានបណ្តេញចេញពីលំនៅដ្ឋាន និងប្រជាពលរដ្ឋដែលសកម្មភាពចិញ្ចឹមជីវិតរបស់ខ្លួនត្រូវរងការរំខាន ដោយសារសម្បទានដី

សេដ្ឋកិច្ច ឬការទន្ទ្រានយកដីធ្លី ជាញឹកញាប់ ពុំមានជម្រើសអ្វីឡើយក្រៅពីធ្វើការឲ្យក្រុមហ៊ុនសម្បទានក្នុងឋានៈជាពលករប្រចាំថ្ងៃ ឬជាបុគ្គលិកធ្វើការងារពេញម៉ោងរបស់ក្រុមហ៊ុន។ នៅតាមក្រុមហ៊ុនសម្បទានមួយចំនួន ប្រាក់ខែដែលក្រុមហ៊ុនបានផ្តល់ឲ្យអ្នកធ្វើការត្រូវបានរាយការណ៍ថា មានចំនួនខ្ពស់ជាងកម្រិតប្រាក់ខែជាមធ្យម[៤១]ទោះជាយ៉ាងនេះក្តី អ្នកធ្វើការងារទាំងនោះមិនអាចធ្វើការបានក្នុងរយៈពេលពេញ១២ខែទេ ហើយគ្មានអ្វីត្រូវឆ្ងល់ឡើយថា ការកែប្រែការងាររបស់ខ្លួនពីកសិករទៅជាពលករយកប្រាក់ខែ មានទំនាក់ទំនងជាមួយនឹងអសន្តិសុខការងារយ៉ាងធំធេង។ ជាងនេះទៀត លក្ខខណ្ឌការងារមិនត្រូវបានត្រួតពិនិត្យឲ្យបានដិតដល់ឡើយ។ ដំណើរការសេដ្ឋកិច្ចអឺរ៉ុបនៅសតវត្សរ៍ទី១៩ ដែលពាក់ព័ន្ធនឹងការផ្លាស់ប្តូរទីលំនៅយ៉ាងច្រើនពីជនបទ និងការកែប្រែជីវភាពប្រជាកសិករយ៉ាងច្រើន ទៅជាអ្នកធ្វើការងារយកប្រាក់ខែ គ្មានដីធ្លីនោះហាក់ដូចជាមានអត្តសញ្ញាណស្រដៀងគ្នានឹងអ្វីដែលកំពុងតែកើតឡើងក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ រាជរដ្ឋាភិបាលកំពុងប្រើប្រាស់ការផ្លាស់ប្តូរទីលំនៅរបស់ប្រជាពលរដ្ឋ ជាចំណុចសម្គាធមួយ ហើយតាមរយៈបញ្ហានេះធ្វើការនាំកម្លាំងពលកម្ម ដែលគ្មានជំនាញមានតម្លៃថោកទៅកាន់ពីប្រទេសកម្ពុជាទៅកាន់ប្រទេសជិតខាង។ ការធ្វើដូចនេះអាចនាំមកចូលប្រទេសវិញ នូវប្រាក់ពលកម្មដែលជាផ្នែកដ៏សំខាន់ដល់គ្រួសារក្រីក្រ។ ទោះជាយ៉ាងនេះក្តី ពលករចំណាកស្រុកបានប្រឈមទៅនឹងការរំលោភបំពាន ហើយពលករភាគច្រើនប្រហែលជា មិនធ្វើចំណាកស្រុកឡើយ ប្រសិនបើពួកគាត់មានឱកាសការងារនៅក្នុងប្រទេសកម្ពុជានោះ។

### គ. ផលប៉ះពាល់អវិជ្ជមានលើជីវភាពរស់នៅ សន្តិសុខស្បៀង និងសិទ្ធិវប្បធម៌

ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទូទៅក៏ដូចជាជនជាតិដើមភាគតិចដែរ ត្រូវបានរងផលប៉ះពាល់យ៉ាងខ្លាំងដោយសារតែគោលនយោបាយអភិវឌ្ឍន៍។ ដីស្រែ និងដីរបស់ជនជាតិដើមភាគតិចត្រូវបាន (ហើយទំនងជាបន្ត) ទទួលរងផលប៉ះពាល់ ដោយសារសកម្មភាពកសិ-ឧស្សាហកម្ម និងអាជីវកម្មរ៉ែ និងគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ ដូចជាគម្រោងសាងសង់ទំនប់វារីអគ្គិសនី និងផ្លូវរថភ្លើង។ ក្រុមហ៊ុនដែលទទួលបានសម្បទានដីសេដ្ឋកិច្ច (នៅក្នុងករណីជាច្រើនបើទោះបីជាមិនបានធ្វើការសិក្សាវាយតម្លៃហេតុប៉ះពាល់ឲ្យបានគ្រប់ជ្រុងជោយក៏ដោយ) កាប់ឆ្ការយកចម្ការ/ស្រែ ដីចិញ្ចឹមសត្វ និងព្រៃឈើ ដែលប្រជាពលរដ្ឋត្រូវការជាចាំបាច់ដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ ក្រុមហ៊ុនមួយចំនួនបានបង្កើតកន្លែងត្រួតពិនិត្យ និងបិទផ្លូវមិនឲ្យប្រជាពលរដ្ឋប្រើប្រាស់ផ្លូវថ្នល់សាធារណៈ។ សហគមន៍ដែលប្រមូលអនុផលព្រៃឈើ (ដូចជា ជ័រ) នៅក្នុងព្រៃពេលខ្លះ ត្រូវបានហាមឃាត់មិនឲ្យចូលព្រៃ ដើម្បីប្រមូលអនុផលព្រៃឈើឡើយ។

សន្តិសុខស្បៀងត្រូវរងការគំរាមកំហែង ដោយសារតែការបណ្តេញចេញពីលំនៅដ្ឋាន និងការដកហូតទ្រព្យសម្បត្តិ។ នៅតាមតំបន់ទីប្រជុំជន ប្រជាពលរដ្ឋរងការបណ្តេញចេញជាង៥០% បានប្រឈមមុខនឹងការអត់ឃ្លាន ពីព្រោះពួកគេគ្មានស្បៀងគ្រប់គ្រាន់ដើម្បីបរិភោគ ក្នុងរយៈពេល៣ខែមុនការស្រាវជ្រាវដែលធ្វើឡើងដោយHRTF[៤២]។ HRTF បានរាយការណ៍ពីអសន្តិសុខស្បៀងយ៉ាងខ្ពស់នៅក្នុងកន្លែងតាំងទីលំនៅថ្មីទាំងនេះ។ នៅក្នុងតំបន់ជនបទ ការបំផ្លិតបំផ្លាញដីចម្ការ និងដីស្រែ និងសម្លាប់គោ (ដែលប្រជាពលរដ្ឋបានរាយការណ៍មកសមាគមអាដហុក) គំរាមកំហែងកាន់តែខ្លាំងឡើង ដល់សន្តិសុខស្បៀងនៅកម្រិតមូលដ្ឋាន។ កសិករដែលបានទទួលសំណងជាស្រែ/ចម្ការថ្មី ជាញឹកញាប់រាយការណ៍ថា ដីថ្មីទាំងនោះមានទីតាំងឆ្ងាយពីភូមិ មានទំហំតូចជាងដីចាស់របស់ខ្លួន និងពុំសូវមានជីជាតិ។ ជាលទ្ធផល ទិន្នផលពីដីថ្មីទាំងនេះមានការថយចុះ ហើយជាលទ្ធផល ធ្វើឲ្យជីវភាព

៤១ មើល FIDH, កម្ពុជា ៖ ការកាប់ឆ្ការព្រៃដើម្បីដាំកៅស៊ូ, សិទ្ធិស្ថិតក្រោមគ្រឿងចក្រកាយដី; ផលប៉ះពាល់ពីចម្ការកៅស៊ូពីសំណាក់ក្រុមហ៊ុន Socfin-KCD លើសហគមន៍ជនជាតិដើមភាគតិច នៅប៊ូស្រា ខេត្តរតនគិរី (ឆ្នាំ២០១១), ទំព័រ ៤៥។

៤២ HRTF, op. cit., ទំព័រ១៧។

រស់នៅមានភាពដុនដាប។

វិវាទដីធ្លី និងវិវាទផ្សេងៗទៀត ទាក់ទងនឹងអសន្តិសុខនៃការកាន់កាប់ដីធ្លី និងកង្វះខាតការអនុវត្តច្បាប់នៅក្នុងវិស័យដីធ្លី និងបរិស្ថាន មានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើសិទ្ធិវប្បធម៌របស់ជនដើមភាគតិច និងប្រជាពលរដ្ឋមិនមែនជាជនជាតិដើមភាគតិច។ សហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់ជាពិសេស (បានបង់តម្លៃដ៏ខ្ពស់)។ ដូចអ្នករាយការណ៍ពិសេស លោក Surya Subedi បានរាយការណ៍ថា "[...] ជនជាតិដើមភាគតិចនៅក្នុងខេត្តចំនួន១៥ [...] ត្រូវការការគាំទ្រជាចាំបាច់ដើម្បីការពារដល់ការកាន់កាប់ដីជាប្រពៃណីរបស់ខ្លួន ដែលកំពុងតែប្រឈមទៅនឹងការអភិវឌ្ឍគ្មានការគ្រប់គ្រង"[៤៣]។ ការរំលោភបំពានលើសិទ្ធិធ្លី និងសិទ្ធិធនធានមានទំនាក់ទំនងគ្នាទៅនឹងការរំលោភបំពានលើសិទ្ធិវប្បធម៌។ នៅក្នុងឆ្នាំ២០១២ គម្រោងមួយចំនួននៅតែបន្តមានផលប៉ះពាល់ដល់កន្លែងមានតម្លៃខាងវប្បធម៌ និងជំនឿជាច្រើនកន្លែង។ ក្រុមហ៊ុនទទួលបានសម្បទានដីធ្លីបានចូលទៅកាន់កាប់កន្លែងកប់សាកសព និងព្រៃសក្ការៈ ដូចជា ក្រុមហ៊ុនសម្បទានដី Socfin-KCD ក្នុងក្រុងប៊ូស្រា ខេត្តរតនគិរី។ ជារួម សហគមន៍ទាំងនេះមិនត្រូវបានគេជួបពិគ្រោះយោបល់មុននឹងអនុវត្តគម្រោង ហើយត្រូវបានគេធ្វើមិនដឹងឮ ដោយគ្មានដំណោះស្រាយនៅមុនព្រឹត្តិន័យឡើយ។

### ករណីសិក្សា៖ គម្រោងសាងសង់ទំនប់វារីអគ្គីសនីនៅទន្លេសេសានក្រោមពីរ

នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ ប្រជាពលរដ្ឋក្នុងសហគមន៍នៅតាមបណ្តោយទន្លេពីរដែលរងផលប៉ះពាល់ពីគម្រោងសាងសង់ទំនប់វារីអគ្គិសនីខ្នាតធំក្នុងខេត្តស្ទឹងត្រែង បានជួបជុំគ្នាដើម្បីរៀបចំពិធីតាមជំនឿរបស់ខ្លួន និងធ្វើការតវ៉ាដោយសន្តិភាពប្រឆាំងនឹងគម្រោងនេះ។ ទំនប់វារីអគ្គិសនីសេសានក្រោម២ ដែលគ្រោងសាងសង់លើទន្លេសេសាននឹងមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវភាពរស់នៅនិងរបៀបរបនៃការរស់នៅរបស់សហគមន៍នៅតាមបណ្តោយទន្លេសេសាន និងទន្លេស្រែពក ដែលការសាងសង់នេះបង្ខំឲ្យពួកគាត់ចាកចេញពីដីដូនតា និងគំរាមកំហែងដល់សន្តិសុខស្បៀងរបស់ពួកគេ។

គម្រោងសាងសង់ទំនប់វារីអគ្គិសនីនេះ បង្កការគំរាមកំហែងធ្ងន់ធ្ងរដល់ស្តុកត្រី និងតុល្យភាពអេកូឡូស៊ីក្នុងទន្លេទាំងពីរ ដែលជាដៃរបស់ទន្លេមេគង្គ។ នៅថ្ងៃទី២៩ ខែកុម្ភៈ តំណាងសហគមន៍បានធ្វើដំណើរទៅកាន់ទីក្រុងភ្នំពេញដើម្បីជួបតំណាងរាស្ត្រ។ តំណាងរាស្ត្រ បានច្រានចោលសំណើរបស់សហគមន៍ដែលស្នើសុំឲ្យមានការបញ្ឈប់គម្រោងសាងសង់។ គម្រោងនេះ ពុំបានធ្វើការពិគ្រោះយោបល់ឲ្យបានល្អិតល្អន់ជាមួយនឹងសហគមន៍រងផលប៉ះពាល់ទេ។ គេមិនបានដឹងច្បាស់ថា តើគម្រោងបានបញ្ចប់ការសិក្សាអំពីការវាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គម ស៊ីជម្រៅ ឬអត់ទេហើយថា តើមានការបង្កើតគណៈ កម្មាធិការអន្តរក្រសួងដើម្បីដោះស្រាយបញ្ហាតាំងទីលំនៅនិងបញ្ហាសំណង ឬអត់ទេ ?

ព័ត៌មានតែមួយគត់ ដែលបានផ្សព្វផ្សាយយ៉ាងច្បាស់លាស់ជាសាធារណៈគឺថា នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២ ក្រុមហ៊ុនចំនួនពីរ (Cambodia's Royal Group និង China's Hydrolancang International Energy Co. Ltd) បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ ជាមួយ រដ្ឋាភិបាលដើម្បីសាងសង់ទំនប់វារីអគ្គិសនី ប៉ុណ្ណោះ។

## ឃ. ផលប៉ះពាល់អវិជ្ជមានលើធនធានធម្មជាតិ

ការកាប់ឈើខុសច្បាប់ សម្បទានដីធ្លី និងទំនប់វារីអគ្គិសនី បន្តមានផលប៉ះពាល់អវិជ្ជមានលើធនធានធម្មជាតិ និងជីវចម្រុះ។ កង្វះខាតតម្លាភាព ពាក់ព័ន្ធនឹងការកំណត់ព្រំប្រទល់តំបន់ការពារ ហើយព្រំប្រទល់តំបន់ការពារទាំងនេះអាចជាលទ្ធភាពមួយ ដែលធ្វើឲ្យអាជ្ញាធរផ្តល់ដីសម្បទាននៅតាមទីតាំង ដែលត្រូវបានបែងចែកជា "តំបន់ស្នូល" ឬ "តំបន់អភិរក្ស" ជាអាទិភាព និងមិនត្រូវឲ្យមានការប៉ះពាល់។

៤៣ របាយការណ៍របស់អ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា op. cit., កថាខណ្ឌ ១២០។

ព្រៃព្រហ្មចារី ដូចជា ព្រៃឡង់ កំពុងរងគ្រោះថ្នាក់ ដែលការណ៍នេះអាចមានផលប៉ះពាល់អវិជ្ជមានយ៉ាងធ្ងន់ធ្ងរលើសត្វព្រៃ និងជីវចម្រុះ។ ការកាប់បំផ្លាញព្រៃឈើនៅទូទាំងប្រទេសមានកម្រិតខ្ពស់ហួសហេតុ។ កម្ពុជាគឺជាប្រទេសមួយក្នុងចំណោមប្រទេសនានាក្នុងពិភពលោក ដែលមានអត្រាកាប់បំផ្លាញព្រៃឈើខ្លាំងបំផុត ហើយគម្របព្រៃឈើក្នុងប្រទេសមានការធ្លាក់ចុះ[៤៤]។ មូលដ្ឋានយោធាត្រូវបានសាងសង់ក្នុងតំបន់មានព្រៃ ដែលទង្វើនេះគឺជាការគំរាមកំហែងដល់ចីរភាពនៃការប្រើប្រាស់ព្រៃឈើ។ កម្មវិធីអភិរក្សអន្តរជាតិដូចជា REDD ហាក់បី ដូចជា មានឥទ្ធិពលតិចតួចរហូតមកដល់ពេលនេះ។

ភស្តុតាងពីការអង្កេត ដែលបានធ្វើឡើងនៅឆ្នាំ ២០១២ បង្ហាញថា ជលផលក៏ទទួលរងការគំរាមកំហែងស្រដៀងគ្នាដែរ ដោយសារកំណើននៃការបំពុល និងការធ្វើអាជីវកម្ម។ ត្រីគឺជាផ្នែកមួយយ៉ាងសំខាន់នៃអាហាររបស់ប្រជាពលរដ្ឋ ដោយបំពេញតម្រូវការប្រូតេអ៊ីនយ៉ាងច្រើននៅក្នុងអាហារប្រចាំថ្ងៃ។ ដូច្នេះ ការគំរាមកំហែងដល់ស្តុកត្រីជាសកលក្នុងប្រទេស គឺអាចបង្កឲ្យមានកំណើនអសន្តិសុខស្បៀងដែរ។ ដើម្បីទប់ស្កាត់បញ្ហាទាំងនេះពីការឈានទៅរកសភាពធ្ងន់ធ្ងរជាងនេះត្រូវមានការពង្រឹងច្បាប់បុគ្គល និងក្រុមហ៊ុន ដែលមិនគោរពច្បាប់ត្រូវទទួលទណ្ឌកម្ម ហើយអាជ្ញាធរ និងភាគីពាក់ព័ន្ធត្រូវធ្វើការសិក្សាការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាលក្ខណៈប្រព័ន្ធឲ្យបានស៊ីជម្រៅមុននឹងអនុវត្តគម្រោង។ បញ្ហា ដែលទាក់ទងនឹងគម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗ ក៏ជាបញ្ហាឆ្លងព្រំដែនប្រទេសដែរ ដូចជា គម្រោងសាងសង់ទំនប់វារីអគ្គិសនីសាយាបូរី(Xayaburi)ដូច្នេះ តម្រូវឲ្យមានការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិ។

## សេចក្តីសន្និដ្ឋាន

*គោលនយោបាយ និងការអនុវត្តបច្ចុប្បន្ន ពុំមានចីរភាពឡើយ។ នៅពេលបច្ចុប្បន្ននេះ មានកង្វល់ដែលថា តំបន់ការពារ (ក្នុងនោះមាន ព្រៃព្រហ្មចារី និងតំបន់អភិរក្សសត្វព្រៃ) កំពុងតែបាត់បង់ក្នុងល្បឿនមួយយ៉ាងកំហុក ហើយថាពុំមានដីមានជីវជាតិច្រើនឡើយ ដែលនៅសល់សម្រាប់បំពេញតម្រូវការផ្នែកកសិកម្ម ឬចិញ្ចឹមសត្វ។*

*សិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាន និងសិទ្ធិធនធានធម្មជាតិរបស់ប្រជាពលរដ្ឋ និងសហគមន៍ត្រូវរងការរំលោភបំពានដោយសារ ការទន្ទ្រានយកដី និងសម្ពាធលើជីវភាពរស់នៅ។ អាជ្ញាធរត្រូវតែពិចារណាលើគោលនយោបាយអភិវឌ្ឍន៍ និងគ្រប់គ្រងសកម្មភាពទាំងអស់ ដែលធ្វើឡើងក្រោមរូបភាពអភិវឌ្ឍន៍ ដោយយកចិត្តទុកដាក់ពីផលប៉ះពាល់នៃសកម្មភាពទាំងនោះលើមនុស្ស និងសង្គម។ ជាងនេះទៀត មធ្យោបាយដោះស្រាយវិវាទត្រូវតែពង្រឹង និងត្រួតពិនិត្យជាលក្ខណៈប្រព័ន្ធ។*



*ការកាប់ឈើខុសច្បាប់ក្នុងខេត្តរតនគិរី*

៤៤ អង្គការកសិកម្ម និងស្បៀងអង្គការសហប្រជាជាតិ, ការវាយតម្លៃធនធានធម្មជាតិសកល (ឆ្នាំ២០០៥ និងឆ្នាំ២០១០) (មើលhttp://www.fao.org/forestry/fra/fra2005/en/ and http://www.fao.org/forestry/fra/fra2010/en/)។

# ៣. ការដោះស្រាយវិវាទ

## ក. មធ្យោបាយជាធរមានក្នុងការដោះស្រាយវិវាទ

មធ្យោបាយជាច្រើនក្នុងការដោះស្រាយវិវាទមានសរសេរនៅលើក្រដាសដែលទាក់ទងនឹងសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាន ក្នុងនោះមានការសម្រុះសម្រួល ស្ថាប័នរដ្ឋបាល/ស្ថាប័នតុលាការប្រហាក់ប្រហែល និងប្រព័ន្ធតុលាការ។ ដំបូងភាគីមានវិវាទដីធ្លី (ក្នុងការអនុវត្តជាក់ស្តែង ជនរងគ្រោះនៃការទន្ទ្រានយកដីធ្លី) អាចស្វែងបទអន្តរាគមន៍ពីមន្ត្រី និងស្ថាប័ននយោបាយ ឬរដ្ឋបាលផ្សេងៗ។ ប្រធានភូមិ និងមេឃុំ (និងក្រុមប្រឹក្សាឃុំ) រួមទាំងអភិបាលស្រុក និងអភិបាលខេត្ត អាចចូលរួមដោះស្រាយវិវាទក្នុងឋានៈជាអ្នកសម្របសម្រួល។ តាមពិត ដើម្បីទប់ស្កាត់កុំឲ្យមានវិវាទនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន មន្ត្រីនៅថ្នាក់មូលដ្ឋានអាចមានចេតនាក្នុងការដាក់សម្ពាធក្នុងកម្រិតណាមួយលើអ្នកទន្ទ្រានយកដីធ្លី។ សមាគមអាដហុកបំពេញការងារជាប្រចាំជាមួយនឹងជនរងគ្រោះនៃការទន្ទ្រានយកដីធ្លីក្នុងការជួយជនរងគ្រោះរៀបចំពាក្យបណ្តឹង ប្រមូលឯកសារផ្លូវច្បាប់ និងធ្វើការបញ្ចុះបញ្ចូលឲ្យមានការគាំទ្រពីអាជ្ញាធរផ្សេងៗ។ នៅពេលការសម្រុះសម្រួលនៅថ្នាក់មូលដ្ឋានមិនអាចសម្រេចផលបាន ភាគីវិវាទ និងសហគមន៍អាចស្វែងបទអន្តរាគមន៍ពីមន្ត្រីរដ្ឋាភិបាល ឬស្ថាប័នរដ្ឋ ដូចជាទីស្តីការគណៈរដ្ឋមន្ត្រី សភាជាតិ ព្រឹទ្ធសភា និងខុទ្ទកាល័យនាយករដ្ឋមន្ត្រី។

យោងតាមមាត្រា ៤៧នៃច្បាប់ភូមិបាល លទ្ធផលនៃការស៊ើបអង្កេតលើវិវាទត្រូវដាក់ជូនគណៈកម្មាធិការសុរិយោដី ដែលចេញសេចក្តីសម្រេចលើវិវាទនោះ។ ទោះយ៉ាងនេះក៏ដោយ ក្នុងករណីមិនសុខចិត្ត គូវិវាទអាចប្តឹងទៅតុលាការបាន។ នៅក្នុងឆ្នាំ ២០១៣ សមាគមអាដហុកនឹងចាប់ផ្តើមអនុវត្តគម្រោងដ៏ធំមួយ (ដែលបានទទួលមូលនិធិពីសហភាពអឺរ៉ុប) ដោយមានគោលបំណងស៊ើបអង្កេតវិវាទដីធ្លីដោយសហការជាមួយនឹងគណៈកម្មាធិការសុរិយោដី។ គណៈកម្មាធិការសុរិយោដីមានសក្តានុពលភាពខ្ពស់ក្នុងការលើកកម្ពស់ស្ថានភាពដីធ្លី និងលើកកម្ពស់សន្តិសុខក្នុងការកាន់កាប់ដីធ្លីតាមរយៈការចេញកម្មសិទ្ធិដីធ្លីដល់អ្នកកាន់កាប់ដីធ្លី។ ទោះជាយ៉ាងនេះក៏ដោយ ក៏គណៈកម្មាធិការនេះមិនអាចដោះស្រាយវិវាទដីធ្លីទាំងអស់ដែរ។

តាមស្ថានភាពជាក់ស្តែង វិវាទដីធ្លីដែលបានចុះបញ្ជីរួច ហើយត្រូវតែបញ្ជូនទៅដោះស្រាយនៅតុលាការ។ តុលាការខេត្តក្រុងត្រូវធ្វើការសម្រេចជាដំបូង ដោយផ្អែកលើច្បាប់ភូមិបាល និងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗទៀត ហើយក្នុងករណីមិនសុខចិត្តទៅនឹងដំណោះស្រាយភាគីអាចប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចទៅសាលាឧទ្ធរណ៍។ វិវាទពាក់ព័ន្ធនឹងការបណ្តេញចេញពីលំនៅដ្ឋានដោយបង្ខំក៏អាចដោះស្រាយនៅក្នុងតុលាការដែរ (ក្នុងនោះ ដីកាពីតុលាការអាចតម្រូវឲ្យមានការបណ្តេញចេញពីលំនៅដ្ឋានតែម្តង)។ ជាទ្រឹស្តី ប្រជាពលរដ្ឋដែលរងការគំរាមកំហែងក្នុងការបណ្តេញពីលំនៅដ្ឋាន មានសិទ្ធិតវ៉ាទៅនឹងការបណ្តេញចេញដែលទង្វើនេះគឺជាផ្នែកមួយនៃសិទ្ធិទទួលបានសំណងតាមការចង់បានរបស់ខ្លួន។

អាជ្ញាធរជាតិដោះស្រាយជម្លោះដីធ្លី ដែលបានបង្កើតឡើងនៅឆ្នាំ ២០០៦ ពុំមានអាណត្តិរបស់ខ្លួនច្បាស់លាស់ឡើយ។ ក្នុងការអនុវត្តជាក់ស្តែង អាជ្ញាធរនេះដោះស្រាយវិវាទទាំងឡាយដែលគណៈកម្មាធិការសុរិយោដីមិនបាន (ឬមិនអាច) ដោះស្រាយបាន។

## ខ. ស្ថានភាពជាក់ស្តែង ៖ ដំណើរការអយុត្តិធម៌ កង្វះខាតឧបាស្រ័យប្រកបដោយប្រសិទ្ធភាព និងការបៀតបៀនសកម្មជន

នៅពេលពិនិត្យពីដំណោះស្រាយវិវាទដីធ្លី សមាគមអាដហុកបានកត់សម្គាល់ពីភាពខុសគ្នាស្រលះចំពោះអត្រាជោគជ័យ អាស្រ័យលើប្រភេទវិវាទ។ បើទោះបីជាវិវាទដែលមានកម្រិតតឹងតែងទាប ឬមធ្យម ជាធម្មតាអាចដោះស្រាយបានដោយជោគជ័យក៏ដោយ ក៏វិវាទដែលមាន

---

៤៥ វិវាទដែលទាក់ទងនឹងធនធានធម្មជាតិអាចដោះស្រាយបានតាមរយៈប្រព័ន្ធតុលាការ (ការអនុវត្តច្បាប់បរិស្ថាន), តាមរយៈមធ្យោបាយផ្លូវការ, ឬតាមរយៈការដោះស្រាយវិវាទដីធ្លី។

៤៦ គណៈកម្មាធិការសុរិយោដីមានស្ថាប័នដែលត្រូវបង្កើតឡើងនៅបីកម្រិត ៖ ស្រុក ខេត្ត និងជាតិ។

ទំនាក់ទំនងជាមួយនឹងសម្បទានដីសេដ្ឋកិច្ច ការទន្ទ្រានយកដីធ្លីពីសំណាក់ភាគីមានអំណាច និងការបណ្តេញចេញដោយបង្ខំក្រោមមូលហេតុការលម្អទីក្រុង ឬគម្រោងអភិវឌ្ឍន៍ មានការលំបាកដោះស្រាយយ៉ាងខ្លាំង។ ករណីនេះ ហាក់បីដូចជាថាកត្តាសំខាន់ដែលមានឥទ្ធិពលដល់ដំណោះស្រាយវិវាទដីធ្លីគឺសមត្ថភាពរបស់ភាគីមួយនៃភាគីមានវិវាទក្នុងការគំរាមកំហែងភាគីផ្សេងទៀត ទទួលបានការគាំទ្រពីស្ថាប័នរដ្ឋផ្សេងៗតែលើភាគីខ្លួនប៉ុណ្ណោះ និងប្រើប្រាស់ប្រព័ន្ធតុលាការមិនត្រឹមត្រូវ។ នៅក្នុងការអនុវត្តជាក់ស្តែង ដំណើរការ និងស្ថាប័នដោះស្រាយវិវាទផ្លូវការ អាចត្រូវបានត្រូវបានបំភ្លេចចោល ឬអាចគ្មានតួនាទីក្នុងការរក្សាសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ និងសហគមន៍។ ជាលទ្ធផល វិវាទទាំងឡាយជាញឹកញាប់ឈានដល់ទីបញ្ចប់ ពីព្រោះតែភាគីទន់ខ្សោយជាងទទួលរងការគំរាមកំហែង ការបៀតបៀន ឬការបង្ខិតបង្ខំឲ្យទទួលយកសំណងក្នុងកម្រិតមួយក្រោមកម្រិតដែលមានកំណត់នៅក្នុងបទដ្ឋាន។ នៅក្នុងករណីសម្បទានដីសេដ្ឋកិច្ចមួយចំនួន ដីធ្លីត្រូវបានប្រគល់ត្រឡប់ទៅឲ្យប្រជាពលរដ្ឋវិញបន្ទាប់ពីមានការសម្រុះសម្រួល។ ទោះជាយ៉ាងនេះក្តី ជាទូទៅប្រជាជនទទួលបានដីមកវិញតែចំនួនពីរបីហិកតាប៉ុណ្ណោះ។ នេះគឺជាចំនួនដីតិចតួចបំផុត បើធៀបទៅនឹងចំនួនដីដែលក្រុមហ៊ុនទទួលបានក្រោមគម្រោងសម្បទានដីសេដ្ឋកិច្ច។

ដំបូង ជាការធម្មតាគឺថា ជនរងគ្រោះនៃការទន្ទ្រានយកដីធ្លីអាចគ្មានធនធានដើម្បីផ្តួចផ្តើមនីតិវិធីផ្សេងៗ។ តម្លៃផ្លូវការ និងក្រៅផ្លូវការត្រូវចំណាយជាចាំបាច់ ដើម្បីចុះបញ្ជីដីធ្លីរបស់ខ្លួន ឬដើម្បីដាក់បណ្តឹងទៅតុលាការ។ ដំណើរការដែលទាក់ទងនឹងការចុះបញ្ជីដីធ្លី ឬបណ្តឹងស៊ីវិល/ព្រហ្មទណ្ឌត្រូវចំណាយពេលវេលាច្រើន ហើយលទ្ធផលពីដំណើរការមិនអាចស្មានបានត្រឹមត្រូវឡើយ។ នៅពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានពង្រឹងអាណត្តិរបស់គណៈកម្មាធិការសុរិយោដី និងបានអនុវត្តគំនិតផ្តួចផ្តើមថ្មីៗក្នុងគោលបំណងកាត់បន្ថយវិវាទដីធ្លី។ សកម្មភាពទាំងនេះទទួលបានការស្វាគមន៍ ពីព្រោះពលរដ្ឋដែលទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីទាំងនោះ មានអារម្មណ៍ថាមានសុវត្ថិភាពលើដីធ្លីរបស់ខ្លួនជាងមុន ហើយអាចចំណាយពេលវេលារបស់ខ្លួន ដើម្បីសកម្មភាពរកប្រាក់ចំណូល ជំនួសឲ្យការចំណាយពេលវេលាដើម្បីធ្វើប័ណ្ណកម្មសិទ្ធិដីធ្លី។ ទោះជាយ៉ាងនេះក្តី គណៈកម្មាធិការសុរិយោដីពុំមានអាណត្តិក្នុងការដោះស្រាយវិវាទចំពោះដី ដែលបានចុះបញ្ជីឡើយ។ ជាងនេះទៀត ជនរងគ្រោះនៃការទន្ទ្រានយកដីធ្លី ជាញឹកញាប់ ពុំមានព័ត៌មានទាក់ទងនឹងអ្នកទន្ទ្រានយកដីធ្លី (រួមទាំងឈ្មោះសម្បទានិកដីសេដ្ឋកិច្ច)។ ដូច្នេះការដាក់បណ្តឹងត្រូវប្រឈមនឹងឧបសគ្គច្រើន។

ទីពីរ ក្នុងករណីវិវាទ ដែលពាក់ព័ន្ធនឹងអតុល្យភាពអំណាចយ៉ាងខ្លាំងរវាងអ្នកទន្ទ្រានយកដីធ្លី និងជនរងគ្រោះនោះ ដោយជនរងគ្រោះពុំអាចទទួលបានសំណង តាមការចង់បានរបស់ខ្លួនឡើយ។ ជនរងគ្រោះក្នុងករណីនេះត្រូវទទួលរងការបំភិតបំភ័យ និងសម្ពាធជាប្រចាំឲ្យទទួលយកដំណោះស្រាយដែលគ្មានយុត្តិធម៌។ ឧទាហរណ៍ ក្នុងករណីខ្លះអ្នកទន្ទ្រានយកដីធ្លីប្រើប្រាស់អ្នកយាមប្រដាប់ដោយអាវុធដើម្បីការពារបរិវេណក្រុមហ៊ុន ឬដើម្បីឈូសឆាយព្រៃយកដីពីប្រជាពលរដ្ឋ។ អ្នកទន្ទ្រានយកដីធ្លីខ្លះអាចដាក់សម្ពាធលើអាជ្ញាធរមូលដ្ឋាន ដើម្បីកុំឲ្យអាជ្ញាធរមូលដ្ឋានគាំទ្រដល់ការទាមទាររបស់អ្នកភូមិ។ ជាលទ្ធផល នៅក្នុងករណីមួយចំនួន ប្រជាពលរដ្ឋត្រូវបានគេបង្ខំឲ្យលក់ដីក្នុងតម្លៃយ៉ាងទាប (ទាបជាងតម្លៃទីផ្សារ)។ ជាទូទៅ ដំណើរការក្នុងការដោះស្រាយវិវាទស៊ីវិលពុំមានភាពយុត្តិធម៌ទេ។ តុលាការមាននិន្នាការគាំទ្រដល់បុគ្គលមានទ្រព្យសម្បត្តិ អ្នកមានទំនាក់ទំនងនឹងអ្នកមានអំណាច និងក្រុមហ៊ុន ច្រើនជាងអ្នកភូមិ។ វិធីសាស្ត្រច្រើនយ៉ាងត្រូវបានប្រើប្រាស់ ដើម្បីបំបាក់ទឹកចិត្តជនរងគ្រោះ ក្នុងនោះរួមទាំង ការពន្យារពេលក្នុងការស៊ើបអង្កេតដោយចេតនា ការមិនទទួលយកសក្ខីកម្ម និងឯកសារដែលរៀបចំដោយអ្នកភូមិ ឬក៏ធ្វើការកោះហៅតំណាងរបស់អ្នកភូមិច្រើនដង (ដែលទង្វើនេះបង្ខំឲ្យអ្នកភូមិចំណាយប្រាក់ក្នុងការធ្វើដំណើរពីភូមិរបស់ខ្លួនទៅកាន់ទីរួមខេត្ត)។ ជាផលវិបាក ប្រជាពលរដ្ឋពុំមានទំនុកចិត្តលើតុលាការ។ ដើម្បីធានាដល់ឯករាជ្យភាពរបស់តុលាការ ប្រទេសកម្ពុជាគួរអនុម័តច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃតុលាការ ជាការងារអាទិភាពរបស់ខ្លួន។ អង្គការសហប្រជាជាតិបានស្នើសុំឲ្យបង្កើតចំណុចនេះ អស់រយៈពេលជិត២០ឆ្នាំហើយ។ ដូចមានការលើកឡើងរបស់តំណាងពិសេសអង្គការសហប្រជាជាតិដែរ

ថា “ច្បាប់ទាំងនេះគួរត្រូវបានតាក់តែងឡើង ដើម្បីធានាពីភាពឯករាជ្យរបស់ស្ថាប័ន និងបុគ្គលនៅក្នុងប្រព័ន្ធតុលាការ ក៏ដូចជាចាត់វិធានការដាក់ទណ្ឌកម្មប្រឆាំងនឹងការបំពេញការងារតុលាការមិនបានត្រឹមត្រូវ និងចៅក្រមដែលពុករលួយ និងគ្មានសមត្ថភាព។ [...] ច្បាប់ទាំងនេះនឹងរួមចំណែកដល់ការការពារលក្ខន្តិកៈរបស់ចៅក្រម និងការពារលក្ខខណ្ឌនៃការផ្ដល់សេវារបស់ចៅក្រម ដោយផ្អែកលើក្រមវិជ្ជាជីវៈចៅក្រម និងព្រះរាជអាជ្ញា”។

ទីបី នៅឆ្នាំ២០១២ សមាគមអាដហុកបានឃើញផ្ទាល់ភ្នែកលើការបង្ក្រាបការតវ៉ាដោយសន្តិវិធី និងកំណើននៃការបៀតបៀនសកម្មជនសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាន។ នៅក្នុងទីក្រុងភ្នំពេញ បាតុកម្មដោយសន្តិវិធីពាក់ព័ន្ធនឹងសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋានដែលបានធ្វើឡើងដោយសហគមន៍បឹងកក់ សហគមន៍បុរីកីឡា និងសហគមន៍ផ្សេងៗទៀតត្រូវបានបង្ក្រាបជាលក្ខណៈប្រព័ន្ធ។ សមាជិកសហគមន៍នៅទូទាំងប្រទេស ដែលកំពុងតែតវ៉ាប្រឆាំងការរំលោភបំពានសិទ្ធិដីធ្លី ឬការចូលកាន់កាប់ធនធានធម្មជាតិ ត្រូវទទួលរងការបំផិតបំភ័យ ការចាប់ខ្លួន ឬការរំលោភបំពានរាងកាយ។

## ករណីសិក្សា ៖ ការបៀតបៀនដោយប្រើប្រាស់ប្រព័ន្ធតុលាការលើ សកម្មជនសិទ្ធិមនុស្ស និងអ្នកសារព័ត៌មាន

នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១២ ប៉ែន ប៊ុណ្ណារ៍ និងឆាយ ធី ជាអ្នកសម្របសម្រួល និងអ្នកស៊ើបអង្កេតរបស់សមាគមអាដហុកប្រចាំខេត្តរតនគិរី អ្នករាយការណ៍វិទ្យុអាស៊ីសេរី សុក រដ្ឋា និងប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា អ៊ូ វីរៈ ត្រូវបានកោះហៅដោយតុលាការខេត្តរតនគិរី ដើម្បីសាកសួរពាក់ព័ន្ធនឹងបទចោទញុះញង់ប្រជាពលរដ្ឋឲ្យប្រព្រឹត្តបទល្មើស។

បទចោទទាំងនេះ ពាក់ព័ន្ធនឹងការចោទប្រកាន់នានាដែលថា បុគ្គលទាំងបួនរូបនេះបានបានញុះញង់សមាជិកសហគមន៍ជនជាតិភាគតិច ធ្វើការតវ៉ាដោយហឹង្សាប្រឆាំងនឹងក្រុមហ៊ុនកសិ-ឧស្សាហកម្មដ៏មានអំណាចមួយឈ្មោះ D.M. Group នៅឆ្នាំ ២០០។ ពាក្យបណ្តឹងដែលប្តឹងបុគ្គលទាំងបួនរូបនេះ មានទំនាក់ទំនងជាមួយនឹងវិវាទដីធ្លីដែលកំពុងតែកើតមានរវាងក្រុមហ៊ុន D.M. Group និង




ការតវ៉ាដែលរៀបចំឡើងដោយប្រជាពលរដ្ឋពីសហគមន៍បឹងកក់ ក្នុងទីក្រុងភ្នំពេញ
©Erika Pineros www.erikapineros.com

គ្រួសារជនជាតិទំពួនចំនួន ១៣៦គ្រួសារ លើទំហំដីចំនួន ២៦០ហិកតា។ វិវាទនេះ មានពាក់ព័ន្ធនឹងការបំភិតបំភ័យអ្នកភូមិតាមរយៈការគំរាមកំហែង និងវិធានការតុលាការប្រឆាំងនឹងតំណាងសហគមន៍រងផលប៉ះពាល់ចំនួន ១០រូប។ បទចោទប្រឆាំងនឹង ប៉ែនប៊ុនណ្ណារ៍ ឆាយធី សុករដ្ឋា និង អ៊ូវីរៈ ជាចុងក្រោយត្រូវបានទម្លាក់ចោលទៅវិញ នៅចុងខែធ្នូ ឆ្នាំ២០១១។

នៅឆ្នាំ២០០៩ ពាក្យបណ្ដឹងស្រដៀងគ្នានេះ ដែលត្រូវធ្វើឡើងប្រឆាំងនឹង ប៉ែនប៊ុនណារ៍ ឆាយធី និង សុករដ្ឋា ទាក់ទងនឹងការងារការអប់រំច្បាប់ដែលសមាគមអាដហុក បានរៀបចំឡើង ដើម្បីជួយដល់អ្នកភូមិដែលរងផលប៉ះពាល់ពីវិវាទដីធ្លី និងការរាយការណ៍ព័ត៌មាន។ នៅខែតុលា ឆ្នាំ២០១១ បុគ្គលទាំងនេះត្រូវបានសាកសួរនៅក្នុងតុលាការខេត្ត។ ជាចុងក្រោយ បទចោទទាំងនេះត្រូវបានទម្លាក់ចោទវិញ នៅចុងឆ្នាំ២០១១។

---

ទីបួន ក្នុងច្រើនករណី វគ្គបណ្ដុះបណ្ដាល និងកិច្ចប្រជុំលើកកម្ពស់សិទ្ធិអំណាចសហគមន៍ដែលរៀបចំឡើងដោយអង្គការសង្គមស៊ីវិលទទួលរងការរំខាន។ នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ អាជ្ញាធរមូលដ្ឋានប៉ុនប៉ងរំខានដល់វគ្គបណ្ដុះបណ្ដាលមួយអំពីសិទ្ធិដីធ្លី ដែលរៀបចំឡើងដោយសមាគមអាដហុក នៅឃុំភ្នំកុក ស្រុកវើនសៃ ខេត្តរតនគិរី។ មន្ត្រីនគរបាលស្រុកបានទៅគោះទ្វារនៅកន្លែងរៀបចំការបណ្ដុះបណ្ដាល ហើយបានបញ្ជាឲ្យបញ្ឈប់ការបណ្ដុះបណ្ដាល ដោយអះអាងថា សមាគមអាដហុកមិនបានសុំការអនុញ្ញាតរៀបចំការបណ្ដុះបណ្ដាលពីអភិបាលស្រុក។ យ៉ាងណាមិញ ការបណ្ដុះបណ្ដាលនេះបានបន្តដំណើរការ បើទោះបីជាមន្ត្រីនគរបាលបានព័ទ្ធនៅជុំវិញកន្លែងបណ្ដុះបណ្ដាល រហូតដល់ពេលបញ្ចប់ការបណ្ដុះបណ្ដាលក៏ដោយ។ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២ មន្ត្រីនគរបាល និងអាជ្ញាធរមូលដ្ឋានបានរំខានដល់វគ្គបណ្ដុះបណ្ដាលមួយទៀត ដែលរៀបចំរួមគ្នាដោយសមាគមអាដហុក និងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ក្នុងឃុំប៉ាតាង ស្រុកលំផាត់ ខេត្តរតនគិរី។ មន្ត្រីមូលដ្ឋានបានទៅគោះទ្វារកន្លែងបណ្ដុះបណ្ដាល ហើយបញ្ជាឲ្យបញ្ឈប់ការជួបជុំគ្នានោះ ដោយអះអាងថា ពួកគេបានទទួលបញ្ជាឲ្យធ្វើបែបនោះពីអាជ្ញាធរខេត្ត និងថា ការបណ្ដុះបណ្ដាលនោះមិនបំពេញលក្ខខណ្ឌក្នុងការជូនដំណឹងឲ្យបានសមរម្យ។ ប្រមាណជា១៥នាទីក្រោយមក អាជ្ញាធរស្រុកបានបញ្ជូនមន្ត្រីនគរបាលពីររូបបន្ថែមទៀត ទៅកន្លែងបណ្ដុះបណ្ដាល។ មន្ត្រីនគរបាលម្នាក់ ដែលបានមកដល់ក្រោយនេះកាន់អាវុធប្រភេទ M-១៦។ ដោយយល់ឃើញថា ទង្វើនេះគឺជាការគំរាមកំហែង សមាគមអាដហុក និងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានបញ្ឈប់ការជួបជុំគ្នា។ បន្ទាប់ពីបានចេញដំណើរពីកន្លែងជួបជុំគ្នា មេឃុំប៉ាតាង បានចោទសមាគមអាដហុកថា មានការពាក់ព័ន្ធនឹងការញុះញង់។ នគរបាលក៏បានប្រាប់បុគ្គលិកមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាផងដែរថា ប្រសិនបើមិនចាកចេញពីស្រុករបស់គេទេ ពួកគេមិនធានាសន្តិសុខរបស់បុគ្គលិកទាំងនោះឡើយ។

យោងតាមមាត្រា៣ នៃច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធី ឆ្នាំ២០០៩ អ្នករៀបចំការជួបជុំត្រូវបានលើកលែងដោយមិនចាំបាច់បំពេញលក្ខខណ្ឌនៃការជូនដំណឹងឡើយ សម្រាប់ «សកម្មភាពផ្សព្វផ្សាយអប់រំ ដើម្បីបម្រើផលប្រយោជន៍សង្គម» ទាំងអស់។ ដូច្នេះ ការរំខានដល់ការបណ្ដុះបណ្ដាលស្របច្បាប់ពីសំណាក់អាជ្ញាធរគឺជាទង្វើខុសច្បាប់។ អ្វីដែលជាកង្វល់ជាងនេះទៀតនោះគឺថា អំពើហិង្សា និងការគំរាមកំហែងប្រព្រឹត្តអំពើហិង្សាកំពុងត្រូវបានប្រើប្រាស់កាន់តែច្រើនឡើងប្រឆាំងនឹងបុគ្គលិក សកម្មជន និងភ្នាក់ងារសារព័ត៌មាន ដែលធ្វើការលើបញ្ហាសិទ្ធិដីធ្លី។ អ្នកទន្ទ្រានយកដីធ្លីមួយចំនួន ដែលមានអំណាចប្រើប្រាស់កម្លាំងប្រដាប់អាវុធដើម្បីយាមការពារតំបន់ និងបរិវេណដីសម្បទាន ធ្វើការបំភិតបំភ័យអ្នកភូមិ និងហាមឃាត់អ្នកភូមិមិនឲ្យទៅស្រែ/ចម្ការ ឬប្រើប្រាស់ផ្លូវសាធារណៈ។ ក្នុងខែកញ្ញា ឆ្នាំ២០១២ ភ្នាក់ងារសារព័ត៌មានវីរជនខ្មែរ ហង្ស សេរីឧត្ដម ត្រូវបានគេធ្វើឃាត បន្ទាប់ពីគាត់បានសរសេរអត្ថបទជាច្រើនទាក់ទងនឹងការកាប់ឈើខុសច្បាប់ដោយធ្វើការចង្អុលបង្ហាញថាជាទង្វើរបស់មន្ត្រីនគរបាល និងយោធា។ ការធ្វើឃាតនេះនាំឲ្យមានការចាប់ខ្លួនមនុស្សពីរនាក់ ប៉ុន្តែអាចមានទំនាក់ទំនងនឹងមនុស្ស ដែលឋានៈខ្ពស់ផ្សេងទៀត។

បើទោះជា មន្ត្រីកងយោធពលខេមរភូមិន្ទកម្ពុជា

បានច្រានចោលការចោទប្រកាន់ដូចនេះក្តី ក៏ក្នុងរយៈពេលមួយឆ្នាំកន្លងទៅនេះ អង្គភាពយោធាមួយចំនួននៅតែបន្តផ្តល់ការយាមការពារដល់ដីសម្បទាន។ ករណីនៃការគំរាមកំហែង ការបំភិតបំភ័យ និងការរំលោភបំពានត្រូវបានរាយការណ៍ជាប្រចាំ។ សមាគមអាដហុក មានក្តីកង្វល់យ៉ាងខ្លាំងអំពីការប្រើប្រាស់កម្លាំងយោធាសម្រាប់បម្រើផលប្រយោជន៍ឯកជន។ ប្រព័ន្ធនៃការផ្គត់ផ្គង់ ដែលបុគ្គលមានអំណាចផ្តល់មូលនិធិដល់អង្គភាពនៃកងយោធពលខេមរភូមិន្ទកម្ពុជា ធ្វើឲ្យមានកំណើននៃក្តីបារម្ភលើការរំលោភសិទ្ធិមនុស្ស និងខុសទៅនឹងគោលបំណង និងក្រមសីលធម៌កងទ័ព។ នៅក្នុងការអនុវត្តជាក់ស្តែង ទង្វើនេះនាំឲ្យមើលទៅឃើញដូចជា ការប្រើប្រាស់កងកម្លាំងយោធារបស់រដ្ឋ សម្រាប់ផលប្រយោជន៍ឯកជន។ ជាងនេះទៀត ការរំលោភបំពានដែលកងកម្លាំងប្រដាប់អាវុធបានប្រព្រឹត្ត មិនត្រូវបានស៊ើបអង្កេតឲ្យបានពេញលេញឡើយ។


កន្លែងសម្លាប់ ឈុត វុទ្ធី

## ករណីសិក្សា ៖ ការសម្លាប់ ឈុត វុទ្ធី

នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ លោក ឈុត វុទ្ធី ដែលជាសកម្មជនម្នាក់ក្នុងចំណោមសកម្មជនបរិស្ថានយ៉ាងល្បីល្បាញក្នុងប្រទេសកម្ពុជា ត្រូវបានបាញ់សម្លាប់ដោយកងកម្លាំងប្រដាប់អាវុធ ក្នុងស្រុកមណ្ឌលសីមា ខេត្តកោះកុង។ ពេលនោះលោក វុទ្ធី បានចុះទៅស៊ើបអង្កេតករណីកាប់ឈើដែលរងការសង្ស័យថាជាទង្វើខុសច្បាប់ ជាមួយនឹងអ្នកសារព័ត៌មាន ២រូប មកពីសារព័ត៌មាន The Cambodia Daily និងបានបដិសេធមិនប្រគល់រូបថតដែលលោកបានថតទៅឲ្យមន្ត្រីយោធា។ វុទ្ធី មានឈ្មោះល្បីល្បាញដោយ សារតែការងារតស៊ូមតិ និងស៊ើបអង្កេត និងការភ្ជាប់អ្នកជំនួញ ដែលមានទំនាក់ទំនងជាមួយនឹងមន្ត្រីមាន អំណាច មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ និងកងកម្លាំងប្រដាប់អាវុធ ទៅនឹងការលួចប្លន់ធនធានធម្មជាតិក្នុងប្រទេសកម្ពុជា។

អាជ្ញាធរ បានធ្វើការបញ្ជាក់មួយចំនួនដែលមានលក្ខណៈ ផ្ទុយគ្នាទាក់ទងនឹងការស្លាប់របស់លោក វុទ្ធី ប៉ុន្តែរយៈពេលបន្ទាន់ថ្ងៃក្រោយមក កិច្ចស៊ើបអង្កេតជាផ្លូវការបានសន្និដ្ឋានថា លោក វុទ្ធី ត្រូវបានបាញ់ស្លាប់ដោយទាហានម្នាក់ឈ្មោះ អ៊ិនរតនា ដែលក្រោយមកត្រូវបានអ្នកយាមសន្តិសុខបានបាញ់ស្លាប់ ដោយចៃដន្យ ក្នុងពេលព្យាយាមដកអាវុធចេញពី អ៊ិនរតនា។ ការអះអាងដូចនេះ ត្រូវបានច្រានចោលពីសំណាក់ក្រុមសិទ្ធិមនុស្សជាតិ និងអន្តរជាតិ ដែលកត់សម្គាល់ពីភស្តុតាងជាក់ស្តែងដែលមានលក្ខណៈផ្ទុយទៅនឹងការអះអាងនេះ ហើយមានការងឿងឆ្ងល់ទៅលើភាពមិនលម្អៀងនៃគណៈកម្មាធិការស៊ើបអង្កេត។

អ្នកយាមសន្តិសុខឈ្មោះ រ៉ាន់បូរ័ត្ន ត្រូវមានទោសពីបទ «ការធ្វើមនុស្សឃាតដោយអចេតនា» ប៉ុន្តែត្រូវបានដោះលែងមួយខែក្រោយមក បន្ទាប់ពីគាត់ត្រូវបានរកឃើញថាមានទោស ដែលរយៈពេលនេះគឺជារយៈពេលដែលគាត់បានជាប់ពន្ធនាគារ។ សម្រាប់អ្នកស៊ើបអង្កេតជាច្រើនរូប ទង្វើនេះបញ្ជាក់ថា បូរ័ត្នគឺគ្រាន់តែជាមនុស្សដែលទទួលថ្នូរបាក់ប៉ុណ្ណោះ ដែលមានន័យថា ឃាតករសម្លាប់លោក ឈុត វុទ្ធី មិនទាន់ត្រូវបានដាក់ទណ្ឌកម្មនៅឡើយ។ សំណុំរឿងឃាតករសម្លាប់លោក ឈុតវុទ្ធី ត្រូវបានបិទជាផ្លូវការ នៅខែតុលា ឆ្នាំ២០១។

មរណភាពរបស់លោក ឈុតវុទ្ធី គឺជាការភ្ញាក់ផ្អើលមួយជាពិសេស ពីព្រោះថា លោកគឺជាអ្នកការពារធនធានធម្មជាតិយ៉ាងល្បីល្បាញ ក្នុងប្រទេសកម្ពុជា។ កន្លងមក លោកត្រូវបានគំរាមកំហែងជាច្រើនដង ដោយកំណត់គោលដៅមិនត្រឹមតែការងាររបស់លោកប៉ុណ្ណោះទេ តែថែមទាំងការកសាងបណ្តាញការងារ និងសកម្មភាពលើកកម្ពស់សិទ្ធិអំណាច

**ពីព្រោះលោកបានជួយសហគមន៍ក្នុងការការពារសិទ្ធិ និង បញ្ចេញសកម្មភាពប្រឆាំងនឹងការចូលទៅកាប់បំផ្លាញធនធានធម្មជាតិ។**



អាវុធរបស់ អ៊ិន រតនា

ជាចុងក្រោយ នៅឆ្នាំ២០១២ តំណាងសហគមន៍ រួមទាំងអ្នកបម្រើការងារសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋានត្រូវបានប្រឈមទៅនឹងការបៀតបៀនដោយប្រើប្រាស់ប្រព័ន្ធតុលាការតាមរយៈបណ្តឹង និងការជំនុំជម្រះមិនយុត្តិធម៌។ "ទម្រង់ដ៏អាក្រក់ទូទៅទាំងបី" នៃបទចោទព្រហ្មទណ្ឌ (ការញុះញង់ ការបរិហារកេរ្តិ៍ និងការផ្តល់ព័ត៌មានខុស) ត្រូវបានប្រើប្រាស់ដើម្បីបំភិតបំភ័យ និងដាក់ទណ្ឌកម្មលើសកម្មជន ដើម្បីបំបិទមាត់ពួកប្រឆាំង ដើម្បីលាក់បាំងការរកស៊ីខាងដីធ្លី និងទំនាក់ទំនងវិសមភាគរវាងអ្នកភូមិ អ្នកតាំងទីលំនៅស្របច្បាប់ និងផលប្រយោជន៍អាជីវកម្មរបស់អ្នកមានអំណាច។ ជាញឹកញាប់ តុលាការចោទប្រកាន់ប្រជាពលរដ្ឋពីបទល្មើសព្រហ្មទណ្ឌ ដូចជា ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជន ដើម្បីបំភិតបំភ័យសហគមន៍។

ផ្ទុយទៅនឹងលិខិត និងស្មារតីនៃច្បាប់ព្រហ្មទណ្ឌ តុលាការបានប្រើប្រាស់ការឃុំខ្លួនមុនការជំនុំជម្រះ ជាវិធានច្បាប់មួយ (ពុំមានករណីលើកលែង) និងឃុំខ្លួនសកម្មជនដើម្បីបំបាក់ឆន្ទៈរបស់ពួកគេ។ ដូចក្នុងរបាយការណ៍របស់ខ្លួន ក្នុងឆ្នាំ២០១១ សមាគមអាដហុកយល់ថា នេះគឺជាភាពអយុត្តិធម៌យ៉ាងខ្លាំង ជាពិសេសក្នុងករណី ដែលតុលាការត្រូវសម្រេចថាតើនរណាជាម្ចាស់ដីត្រឹមត្រូវ។ ក្នុងករណីនៃការទន្ទ្រានយកដីធ្លី នៅពេលតំណាងសហគមន៍ត្រូវបានឃុំខ្លួន អ្នកទន្ទ្រានយកដីធ្លីអាចបន្តកាប់ឆ្ការព្រៃយកដី។ សមាគមអាដហុកបានរាយការណ៍ថា ប្រជាពលរដ្ឋចំនួន ៩៥នាក់ត្រូវបានចាប់ខ្លួន ហើយ៤៨នាក់ត្រូវបានឃុំខ្លួន ទាក់ទងនឹងវិវាទដីធ្លី និងលំនៅដ្ឋាន នៅឆ្នាំ២០១១។ នៅឆ្នាំ២០១២ ប្រជាពលរដ្ឋ២៣២នាក់ត្រូវបានចាប់ខ្លួន ដែលការចាប់ខ្លួននេះមានកំណើនរហូតដល់១៤៤%។ ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ប្រជាពលរដ្ឋ៣៨នាក់កំពុងស្ថិតក្នុងគុកនៅឡើយ



*ប្រជាពលរដ្ឋនៅថ្មគោលត្រូវបានចាប់ខ្លួនពេលនៃដំណើរទស្សនកិច្ចរបស់ប្រធានាធិបតីអាមេរិក Barack Obama*

*©Erika Pineros www.erikapineros.com*

និង ៥០នាក់កំពុងរត់គៀសខ្លួន។ រឿងក្តីល្បីៗមួយចំនួនដូចជា ការជំនុំជម្រះ លោក ម៉ម សូណង់ដូ និងតំណាងសហគមន៍អ្នកបឹងកក់ និងតំណាងអ្នកបុរីកីឡា គឺជារឿងក្តីដែលមានផលប៉ះពាល់បំផុតលើការងារសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាន។ បច្ចុប្បន្ននេះ ការភ័យខ្លាចមានការរាលដាលនៅពេលដែលប្រព័ន្ធតុលាការបានគាំទ្រជាប្រចាំដល់រាជរដ្ឋាភិបាល និងខកខានមិនបានគាំទ្រ សិទ្ធិបញ្ចេញមតិដោយសេរី សិទ្ធិជួបប្រជុំគ្នា និងសិទ្ធិបង្កើតសមាគម។ បទចោទកាន់តែច្រើនឡើងៗត្រូវបានប្រើប្រាស់ ដើម្បីបំបិទមាត់សកម្មជន។ លោក ឈុត វុទ្ធី បានបង់តម្លៃខ្ពស់បំផុត គឺជីវិតរបស់លោក។ និយាយឲ្យខ្លីគឺថា វាកាន់តែមានគ្រោះថ្នាក់ខ្លាំងឡើង ក្នុងការធ្វើជាអ្នកតំណាងរបស់សហគមន៍ និងជាអ្នកការពារសិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាន និងសិទ្ធិធនធានធម្មជាតិរបស់ប្រជាពលរដ្ឋកម្ពុជា។

## ករណីសិក្សា ៖ ការជំនុំជម្រះយ៉ាងអយុត្តិធម៌លើអ្នកតំណាងសហគមន៍បឹងកក់ និងបុរីកីឡា

នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២ ប្រជាពលរដ្ឋជាស្ត្រីពីសហគមន៍បឹងកក់ក្នុងទីក្រុងភ្នំពេញចំនួន ១៣នាក់ត្រូវបានចាប់ខ្លួន ក្នុងពេលពួកគេកំពុងធ្វើការតវ៉ាដោយសន្តិភាពប្រឆាំងនឹងការបំផ្លិចបំផ្លាញលំនៅដ្ឋានរបស់ខ្លួន។ នគរបាលបានចាប់ខ្លួនអ្នកដឹកនាំសហគមន៍ក្រោមការ ចោទប្រកាន់ថាបានជេរប្រមាថមន្ត្រីអនុវត្តច្បាប់ និងញុះញង់បាតុករ។ អ្នកខ្លះក្នុងចំណោមអ្នកត្រូវបានចាប់ខ្លួនទាំងនេះ គឺជាសមាជិកក្រុមដែលត្រូវបានគេដកចេញពីការផ្តល់សំណងទៅឲ្យគ្រួសាររងការបណ្តេញចេញពីដីធ្លី។ នៅថ្ងៃទី២៤ ខែឧសភា បន្ទាប់ពីបានបើកការជំនុំជម្រះចំនួនពីរម៉ោង ស្ត្រីទាំង ១៣រូប (រួមទាំងលោកយាយម្នាក់អាយុ ៧២ឆ្នាំផង) ត្រូវបានកាត់ទោសដាក់ពន្ធនាគារចំនួនពីរឆ្នាំកន្លះពីបទចោទថា បាន "កាន់កាប់ដីខុសច្បាប់" និង "ការរំខានដល់មន្ត្រីសាធារណៈ" ដោយមានស្ថានទម្ងន់ទោស (ប៉ុន្តែតុលាការព្យួរទោសមួយចំនួនដែលចោទប្រឆាំងនឹងអ្នកទោសមួយចំនួនក្នុងចំណោមអ្នកទោសទាំងនេះ)។

សិទ្ធិជាមូលដ្ឋានក្នុងការទទួលការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានរំលោភបំពាន[៤៨]។ មេធាវីរបស់ប្រជាពលរដ្ឋទាំងនេះ មិនត្រូវបានអនុញ្ញាតឲ្យចូលមើលសំណុំរឿងឡើយនៅមុនពេលជំនុំ ជម្រះ។ ពួកគេ មិនត្រូវបានផ្តល់ពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំខ្លួនការពារខ្លួន ហើយសាក្សីដោះបន្ទុកមិនត្រូវបានអនុញ្ញាតឲ្យចូលក្នុងបន្ទប់សវនាការឡើយ។ ក្នុងពេលជាមួយគ្នានេះ នៅខាងក្រៅតុលាការ អ្នកភូមិបឹងកកចំនួន ២នាក់ ដែលបានទៅទីនោះ ដើម្បីផ្តល់សក្ខីកម្មក្នុងនាមជាសាក្សី ត្រូវបានចាប់ខ្លួន។ បន្ទាប់ពីមានយុទ្ធនាការយ៉ាងទទូចឲ្យមានការដោះលែង ស្ត្រីទាំង១៣នាក់ ត្រូវបានដោះលែងពីពន្ធនាគារ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ បន្ទាប់ពីតុលាការសាលាឧទ្ធរណ៍ បានកាត់បន្ថយទោសមកត្រឹម មួយខែនិងបីថ្ងៃ ដែលជារយៈពេលពួកគាត់ បានជាប់ក្នុងពន្ធនាគាររួចហើយ។ ទោះជាយ៉ាងនេះក្តី ស្ត្រីទាំងនេះនៅតែមានកំណត់ហេតុមានទោសព្រហ្មទណ្ឌ។

នៅខែកញ្ញា សកម្មជនដីធ្លីដ៏ល្បីល្បាញ ២រូបពីសហគមន៍បឹងកក់ និងបុរីកីឡាត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងត្រូវបានបញ្ជូនទៅដាក់ពន្ធនាគាររង់ចាំការបើកសវនាការ។ អ្នកស្រី យ៉ោមបុប្ផា (អាយុ ២៩ឆ្នាំ) ត្រូវបានចោទប្រកាន់ថា បានបង្កហឹង្សាលើបុរសម្នាក់ដែលសង្ស័យថាជាចោរ។ អ្នកស្រីបានច្រានចោលបទចោទទាំងនេះ។ អ្នកស្រី ទឹមសាក់មុន្នី (អាយុ ៦៥ ឆ្នាំ) ដែលតំណាងម្នាក់ក្នុងចំណោមតំណាងសហគមន៍បុរីកីឡា ដែលបានបញ្ចេញមតិយ៉ាងច្រើន ត្រូវបានចោទប្រកាន់ថាបានផ្សព្វផ្សាយព័ត៌មានមិនពិត។ ការចោទប្រកាន់នេះ ហាក់បីដូចជាសំដៅ ទៅលើសំណើរបស់អ្នកស្រី សុំឲ្យក្រុមហ៊ុន ផានអ៊ីមិច ផ្តល់សំណងដល់កូនប្រុសពិការរបស់គាត់ ដែលក្រុមហ៊ុន មិនបានផ្តល់ឲ្យ បន្ទាប់ពីកូនប្រុសនោះ បានបណ្តេញចេញពីសហគមន៍

៤៨ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ការវិភាគច្បាប់លើការចោទប្រកាន់ និងការផ្តន្ទាទោសតំណាងសហគមន៍បឹងកកទាំង ១៣ នាក់ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ (សំណុំរឿងប្រហ្មទណ្ឌលេខ ១៥៧៦/២៤-០៥-២០១២)។

បុរីកីឡា នៅខែមករា ឆ្នាំ២០១១។

នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ អ្នកស្រី ទឹមសាក់មុន្នី ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារចំនួន ៦ខែ ដោយមានការព្យួរផ្នែកខ្លះនៃទោសរបស់គាត់។ អ្នកស្រី បានដោះលែងក្នុងថ្ងៃបើកសវនាការ ប៉ុន្តែនៅតែមានកំណត់ហេតុមានទោសព្រហ្មទណ្ឌ។ នៅថ្ងៃទី២៧ ខែធ្នូ បុប្ផា ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារចំនួន ៣ឆ្នាំ បើទោះបីជាការបើកសវនាការនោះពុំមានភស្តុតាងគ្រប់គ្រាន់ក៏ដោយ។ ដោយមានការរំលោភបំពានលើគោលការណ៍ ជាមូលដ្ឋាននៃច្បាប់ព្រហ្មទណ្ឌ ជនជាប់ចោទមិនបានទទួលប្រយោជន៍ពីវិមតិសង្ស័យឡើយ។ អ្នកស្រី បានក្លាយជាគោលដៅដោយសារតែសកម្មភាពសិទ្ធិលំនៅដ្ឋានរបស់ខ្លួនប៉ុណ្ណោះ។

---

## សេចក្តីសន្និដ្ឋាន

*មធ្យោបាយជាធរមានក្នុងការដោះស្រាយវិវាទដីធ្លី និងលំនៅដ្ឋានពុំមានប្រសិទ្ធភាពឡើយ ដោយសារតែនិទណ្ឌភាពទាក់ទងនឹងការប្រើប្រាស់អំណាចដោយបំពាន កង្វះខាតការអនុវត្តច្បាប់ និងកង្វះខាតឯករាជ្យភាពរបស់តុលាការ។ តុលាការអនុវត្តច្បាប់យ៉ាងតឹងរឹងជាមួយនឹងអ្នកទន់ខ្សោយ ហើយអនុវត្តច្បាប់យ៉ាងធូររលុងជាមួយនឹងមានអំណាច ដែលជាស្ថានភាពមួយធ្វើឲ្យប៉ះពាល់កិត្តិយសប្រទេសកម្ពុជា។*

*អាជ្ញាធរគួរពង្រឹងសមត្ថភាពគណៈកម្មាធិការសុរិយោដីនៅគ្រប់កម្រិតទាំងអស់ និងធ្វើការត្រួតពិនិត្យតុលាការឲ្យបានតឹងរឹង។ ចៅក្រម និងព្រះរាជអាជ្ញា ដែលបំពេញការងារលម្អៀងទៅបម្រើផលប្រយោជន៍អ្នកមានអំណាចច្រើនជាងប្រយោជន៍របស់ប្រជាពលរដ្ឋកម្ពុជាក្រីក្រ និងងាយរងគ្រោះត្រូវតែទទួលទណ្ឌកម្ម។ ដើម្បីធានាឲ្យតុលាការមានឯករាជ្យ គួរមានការអនុម័តជាអាទិភាពនូវច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃតុលាការ។*

*ការផ្តន្ទាទោសផ្លូវច្បាប់ និងអំពើហិង្សាប្រឆាំងនឹងតំណាង ភ្នាក់ងារ និងសកម្មជនសិទ្ធិមនុស្ស មិនត្រឹមតែជាទង្វើខុសច្បាប់ និងអយុត្តិធម៌ប៉ុណ្ណោះទេ តែថែមទាំងជាទង្វើពុំមានប្រសិទ្ធភាពទៀតផង។ អាជ្ញាធរមិនគួរគិតថា វិធីដូចនេះអាចដោះស្រាយវិបត្តិដីធ្លីបានឡើយ។*

# ៤. គំនិតផ្តួចផ្តើមថ្មីៗរបស់រាជរដ្ឋាភិបាល

## ក. ការផ្អាកបណ្តោះអាសន្នជាផ្លូវការស្តីពីការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មីៗ

នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថាលោកបានចុះហត្ថលេខាលើបទបញ្ជាមួយធ្វើការផ្អាកជាបណ្តោះអាសន្នផ្លូវការស្តីពីការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មីៗ និងពង្រឹងអ្វីដែលហៅថាគោលនយោបាយ «ស្បែកខ្លា» ពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ដើម្បីផាត់ចោលតំបន់ ដែលមានពលរដ្ឋរស់នៅពីសម្បទាន និងសម្រាលការទន្ទ្រានយកដីលើដីសហគមន៍ និងដីកសិករ។ បទបញ្ជាលេខ០០១ ក៏អំពាវនាវផងដែរឲ្យពិនិត្យមើលគ្រប់សម្បទានដែលមានស្រាប់ ដើម្បីត្រួតពិនិត្យការអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។ ប្រសិនបើ ត្រូវបានគូសបញ្ជាក់ឡើងវិញថា សម្បទានដែលគេរកឃើញថា បានបំពារបំពានលើបទប្បញ្ញត្តិច្បាប់ ឬកិច្ចសន្យាសម្បទាន នោះនឹងត្រូវបានលុបចោល។

សមាគមអាដហុក ស្វាគមន៍យ៉ាងកក់ក្តៅចំពោះបទបញ្ជាលេខ០០១។ សមាគមអាដហុកនិងអង្គការសង្គមស៊ីវិលផ្សេងៗទៀត បានស្នើសុំទៅរាជរដ្ឋាភិបាលអស់ជាច្រើនឆ្នាំមកហើយឲ្យបញ្ឈប់ការផ្តល់សម្បទានដីថ្មីៗទៀត ពិនិត្យឡើងវិញនូវសម្បទានដែលមានស្រាប់ និងពង្រឹងការអនុវត្តបទប្បញ្ញត្តិ និងច្បាប់ពាក់ព័ន្ធ។ ពាក់ព័ន្ធនឹងបញ្ហានេះ បទបញ្ជា០០១ គឺជាអ្វីដែលត្រូវការជាចាំបាច់។ បទបញ្ជានេះក៏មានសារៈសំខាន់ផងដែរ ក្នុងការផាកពិន័យក្រុមហ៊ុនដែលត្រូវបានគេរកឃើញថា បានបំពារបំពានលើកាតព្វកិច្ចរបស់ពួកគេ។ រាជរដ្ឋាភិបាលចាំបាច់ត្រូវហាកហូតសម្បទានរបស់ពួកគេ និងប្រគល់ដីនោះមកអ្នកកាន់កាប់ដើមវិញ។ ប្រសិនបើ សម្បទានិកបណ្តាលឲ្យមានការខូចខាតដល់ដី ឬព្រៃឈើ គឺចាំបាច់បង្ខំពួកគេឲ្យផ្តល់សំណងដល់រដ្ឋ និងពលរដ្ឋ ដែលទទួលរងផលប៉ះពាល់។

យ៉ាងណាក៏ដោយ ចន្លោះប្រហោងដ៏សំខាន់កើតមានក្នុងការផ្អាកបណ្តោះអាសន្នជាផ្លូវការនេះ។ តាមពិត សម្បទានដីសេដ្ឋកិច្ច ដែលស្ថិតក្រោមការពិចារណា នៅពេលដែលប្រកាសការផ្អាកបណ្តោះអាសន្ននេះ គឺត្រូវមិនរាប់បញ្ចូលក្នុងការអនុវត្តនេះទេ។ ក្នុងការអនុវត្តជាក់ស្តែងវាមានន័យថា សម្បទានដីសេដ្ឋកិច្ចថ្មីអាច និងត្រូវបានផ្តល់ឲ្យ បើទោះជាមានការផ្អាកនេះក្តី។ អង្គការ LICADHO ហៅ ចន្លោះប្រហោងនេះថា «ធំធេងពេកដែលវាលេបត្របាក់ការហាមឃាត់នេះខ្លួនឯងតែម្តង»[៤៩] ហើយសមាគមអាដហុកបានរកឃើញថា សម្បទានដីសេដ្ឋកិច្ចចំនួន៣៣ ត្រូវបានផ្តល់ឲ្យចាប់តាំងពីថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ គឺរាប់បញ្ចូលទាំង សម្បទានដីចំនួន១៣កន្លែងក្នុងខែមិថុនា និង១០កន្លែងទៀត ក្នុងខែសីហា (ទោះជាយ៉ាងនេះក្តី ចាប់តាំងពីខែកញ្ញា ដល់ខែធ្នូ ឆ្នាំ២០១២ មានតែសម្បទានដីសេដ្ឋកិច្ចបួនប្លង់ប៉ុណ្ណោះត្រូវបានផ្តល់ឲ្យ)។ សម្បទានទាំងនេះគ្របដណ្តប់លើផ្ទៃដីយ៉ាងហោចណាស់២០៨,៨០៥ហិកតា។ ដោយគ្មានព័ត៌មានអំពីចំនួនសម្បទានដីសេដ្ឋកិច្ចកំពុងត្រូវបានរៀបចំនៅពេលប្រកាសការផ្អាកនេះ អ្នកអង្កេតការណ៍ស្ថិតក្នុងភាពងងឹត។ រាជរដ្ឋាភិបាលគួរបញ្ឈប់ការលាក់ការណ៍សម្ងាត់ ជុំវិញការចរចាផ្តល់សម្បទានដីសេដ្ឋកិច្ច និងព័ត៌មានពិស្តារអំពីគោលនយោបាយរបស់ខ្លួនពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ច ដែលបានលុបចោល។ សម្បទាន ដែលដកហូតគួរប្រគល់ត្រឡប់ឲ្យកសិករ និងពលរដ្ឋ ដែលធ្លាប់កាន់កាប់ដីនោះវិញ ហើយពលរដ្ឋដែលទទួលរងប៉ះពាល់ចាំបាច់ត្រូវបានប្រឹក្សាយោបល់ស្តីពីបញ្ហាពាក់ព័ន្ធ ដូចជា ការស្តារលទ្ធភាពដីឡើងវិញ ឬសំណង។

បើទោះជា មានការធានាថា ការផ្អាកបណ្តោះអាសន្នជាផ្លូវការនេះនឹងត្រូវបានពន្យារក្តីប្រសិនបើ រាជរដ្ឋាភិបាលពុំបង្ហាញព័ត៌មានអំពីចំនួនជាក់លាក់នៃសម្បទានដីសេដ្ឋកិច្ចកំពុងត្រូវបានរៀបចំនៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ អ្នកអង្កេតការណ៍ឯករាជ្យអាចឆ្ងល់នឹងឆន្ទៈនយោបាយក្នុងការសម្រាលអានុភាពនៃគោលនយោបាយសម្បទានដីសេដ្ឋកិច្ច។ តាមពិត បើទោះជាមានការផ្អាកបណ្តោះអាសន្ននេះក្តី ការផ្តល់សម្បទានថ្មីៗនឹងមានន័យថាការសន្យាជាមួយក្រុមហ៊ុនឯកជនគឺសំខាន់ជាងការសន្យាជាមួយពលរដ្ឋកម្ពុជា។

---

៤៩ "លោកនាយករដ្ឋមន្ត្រីការពារការចុះហត្ថលេខាលើសម្បទានដីសេដ្ឋកិច្ច" ក្នុងកាសែតភ្នំពេញប៉ុស្តិ៍ចុះថ្ងៃទី២៧ ខែមិថុនាឆ្នាំ២០១២។

## ខ. គម្រោងផ្តល់ប័ណ្ណកម្មសិទ្ធិដីថ្មី តាមរយៈការកំណត់ព្រំប្រទល់ដោយក្រុមយុវជនស្ម័គ្រចិត្ត

នៅថ្ងៃទី១៤ ខែមិថុនា លោកនាយករដ្ឋមន្ត្រីបានប្រកាសអំពីចេតនារបស់គាត់ ក្នុងការដាក់ចេញនូវកម្មវិធីប្រគល់ប័ណ្ណកម្មសិទ្ធិដីធ្លីដ៏លឿន និងថ្មីមួយ ដែលត្រូវអនុវត្តដោយក្រុមយុវជនស្ម័គ្រចិត្ត។ ប័ណ្ណកម្មសិទ្ធិដីធ្លីរាប់ម៉ឺនសន្លឹកត្រូវបានគេរំពឹងថានឹងចេញឲ្យគ្រួសាររស់នៅតាមទីជនបទ ទូទាំងប្រទេស ក្រោយពីការវាស់វែង និងកំណត់ព្រំប្រទល់ដីធ្លីរបស់ ក្រុមយុវជនស្ម័គ្រចិត្ត។ កម្មវិធីនេះគឺជាការអនុវត្តបន្ថែមនូវគោលនយោបាយ "ស្បែកខ្លា" ដោយបង្អកការទាមទារដីធ្លីរបស់កសិករ។

យោងតាមទិន្នន័យជាផ្លូវការត្រឹមថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១២ រាជរដ្ឋាភិបាលបានប្រគល់ប័ណ្ណកម្មសិទ្ធិដីចំនួន៧១,២២០សន្លឹកឲ្យពលរដ្ឋ ហើយក្រុមយុវជនបានកំណត់ព្រំប្រទល់ដីប្រមាណ៣៣៣,២៧៥ប្លង់ គ្របដណ្តប់លើផ្ទៃដី៤៣៣,៩៨៧ហិកតា[៥០]។ សមាគមអាដហុកស្វាគមន៍ការវិវឌ្ឍនេះដោយសារថា បច្ចុប្បន្ន ពលរដ្ឋរាប់ម៉ឺនគ្រួសារមានអារម្មណ៍ថា មានសន្តិសុខជាងមុនអំពីការកាន់កាប់ដីធ្លីរបស់ពួកគាត់។

ទោះជាយ៉ាងនេះក្តី សមាគមអាដហុកចង់លើកក្តីបារម្ភមួយចំនួន ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីប្រគល់ប័ណ្ណកម្មសិទ្ធិដីធ្លីថ្មីនេះ។ ក្តីបារម្ភទាំងនេះគឺឆ្លុះបញ្ចាំងពីគំហើញ និងរបាយការណ៍ *បឋម*ៗ។ បណ្តុំទិន្នន័យ និងការសិក្សាស្រាវជ្រាវលក្ខណៈស៊ីជម្រៅនឹងមានសារៈសំខាន់ក្នុងការវាយតម្លៃឲ្យបានពេញលេញអំពីគម្រោងថ្មីនេះ និងផ្តល់ជាអានុសាសន៍។

ទីមួយ វាហាក់ដូចថា អាជ្ញាធរមូលដ្ឋាន និងស្ថាប័នរដ្ឋទទួលបន្ទុកផ្នែកផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ការប្រើប្រាស់ និងការគ្រប់គ្រង មិនត្រូវបានប្រឹក្សាយោបល់ មុនពេលការប្រកាសដែលធ្វើឡើងនៅថ្ងៃទី១៤ ខែមិថុនា ទេ។ ទីពីរ តំបន់មានវិវាទត្រូវបានដាក់ឲ្យស្ថិតនៅក្រៅវិសាលភាពកម្មវិធីនេះ។ ដូច្នេះ ពលរដ្ឋ ដែលត្រូវការប័ណ្ណកម្មសិទ្ធិដីបំផុត (ដើម្បីការពារខ្លួនពីការគំរាមកំហែងបណ្តេញចេញ) នឹងមិនទទួលបានប័ណ្ណកម្មសិទ្ធិក្រោមកម្មវិធីនេះដដែល។ ប៉ុន្តែការទទួលស្គាល់សិទ្ធិកាន់កាប់ (ស្របតាមច្បាប់ភូមិបាល) ត្រូវបានរាប់បញ្ចូលក្នុងកម្មវិធីនេះ បន្ថែមទៅលើការកំណត់ព្រំប្រទល់ដី។ នេះគឺពិតជាជួយពង្រឹងសន្តិសុខកាន់កាប់ដីធ្លី ដោយដោះស្រាយតម្រូវការ របស់ពលរដ្ឋ ដែលរស់នៅក្នុងតំបន់លំនៅដ្ឋានក្រៅផ្លូវការ ឬក្នុងតំបន់ដែលអាចនឹងទទួលរងផលប៉ះពាល់ដោយគម្រោងអភិវឌ្ឍន៍។ ក្តីបារម្ភមួយទៀតគឺថា ក្នុងពេលបច្ចុប្បន្ន អាជ្ញាធរមូលដ្ឋាន ចំណាយពេលវេលាភាគច្រើនរបស់ពួកគេជួយដល់ក្រុមយុវជនស្ម័គ្រចិត្ត ហើយពុំមានសល់ពេលវេលាច្រើនសម្រាប់ដោះស្រាយវិវាទដីធ្លីទេ។ ទីបី កម្មវិធីនេះពុំដោះស្រាយស្ថានភាពរបស់ជនជាតិដើមភាគតិចទេ។ របាយការណ៍ដែលសមាគមអាដហុកទទួលបានពីទីស្នាក់ការប្រចាំខេត្តមួយចំនួនចង្អុលបង្ហាញថា សមាជិកនៃសហគមន៍ជនជាតិដើមភាគតិច កំពុងទទួលរងសម្ពាធឲ្យទទួលយកប័ណ្ណកម្មសិទ្ធិដីជាលក្ខណៈឯកជនជាជាងជាលក្ខណៈសមូហភាព។ ដោយសារតែពួកគេខ្លាចបាត់បង់ដីធ្លីរបស់ខ្លួន អ្នកខ្លះត្រូវបង្ខំចិត្តទទួលយកប័ណ្ណកម្មសិទ្ធិដីជាលក្ខណៈឯកជន ត្បិតគ្មានជម្រើសល្អជាងនេះ។ ការពិតដែលថាដីធ្លីរបស់ជនជាតិដើមភាគតិច ដែលទទួលរងផលប៉ះពាល់ដោយប្រតិបត្តិការក្រុមហ៊ុនឯកជនជួយជម្រុញដល់និន្នាការនេះ។

---

**ករណីសិក្សា៖ ការវាស់វែងដីទៅតាមករណីក្នុងខេត្តកោះកុង**

ក្នុងខេត្តកោះកុង ក្រុមយុវជនស្ម័គ្រចិត្ត បានបដិសេធវាស់វែងដីរបស់ប្រជាជនដែលបានចូលរួមក្នុងវិវាទដីធ្លី។ ក្នុងស្រុកបុទុមសាគរ និង គីរីសាគរពលរដ្ឋ ៣០០គ្រួសារ (ក្នុងចំណោម ១,១៤៣គ្រួសារ) ដែលមានវិវាទជាមួយក្រុមហ៊ុន Union Development Group (UDG) ត្រូវបានដាក់ឲ្យស្ថិតក្នុងស្ថានភាពមួយ ដែលគ្មានដំណោះស្រាយ។

---

៥០ គេហទំព័រMLMUPC (ប្រឹក្សាយោបល់នៅថ្ងៃទី៩ខែមករាឆ្នាំ២០១៣)។

ក្រុមយុវជនស្ម័គ្រចិត្តបដិសេធវាស់វែងប្លង់ដីជាលក្ខណៈឯកជន ដោយចោទថា ពួកគាត់ស្ថិតក្នុងតំបន់មានវិវាទ។ ដូចគ្នាដែរ ក្រុមយុវជនស្ម័គ្រចិត្ត បានបដិសេធវាស់វែងដីឲ្យប្រជាពលរដ្ឋ ២០២គ្រួសារ ដែលមានវិវាទជាមួយនឹងក្រុមហ៊ុន Koh Kong Plantation Company ក្នុងភូមិត្រពាំងកណ្តាល ឃុំជីខលើ ស្រុកស្រែអំបិល។ ក្នុងស្រុកស្រែអំបិល និងស្រុកបុទុមសាគរ ក្រុមយុវជនស្ម័គ្រចិត្តបដិសេធវាស់វែងប្លង់ដីឲ្យពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយការទន្ទ្រានយកដីដោយឧកញ៉ាហេងហ៊ុយ។

ប៉ុន្តែផ្ទុយទៅវិញ ក្រុមយុវជនស្ម័គ្រចិត្ត បានជួយរកដោះស្រាយ និងបានវាស់វែងប្លង់ដីជាលក្ខណៈបុគ្គលឲ្យពលរដ្ឋ ៨៤គ្រួសារ ដែលមានវិវាទជាមួយអង្គការមិនមែនរដ្ឋាភិបាលមួយឈ្មោះ Wild Aid ក្នុងភូមិ កោះប៉ោ ឃុំបាក់ខ្លង ស្រុកមណ្ឌលសីមា។

---

សមាគមអាដហុកសូមទទូចថា ការអនុវត្តនូវបទប្បញ្ញត្តិច្បាប់ ពាក់ព័ន្ធនឹងដីជនជាតិដើមភាគតិច គឺពិតជាមានសារៈសំខាន់ដ៏ខ្លាំង និងពុំអាចរង់ចាំបាន។ ទីបួន សមាគមអាដហុកបានរបាយការណ៍ពីថ្នាក់មូលដ្ឋានអំពីក្រុមមនុស្សដែលបានឆ្លៀតឱកាសកាប់បំផ្លាញដីព្រៃឈើ និងដីដាំដុះ ក្នុងបំណងធ្វើជាអ្នកស្នាក់នៅស្របច្បាប់ និងទទួលបានប័ណ្ណកម្មសិទ្ធិដី។ ជាចុងក្រោយអាជ្ញាធរសាធារណៈបានព្យាយាមធ្វើឲ្យអង្គការមិនមែនរដ្ឋាភិបាល និងអ្នកអង្កេតការណ៍រួញរាពីការត្រួតពិនិត្យការអនុវត្តកម្មវិធីថ្មីនេះ។ ជាឧទាហរណ៍បន្ទាប់ពីទិតៀនយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងបទសម្ភាសន៍មួយ លោក សៀ ភារម្យ នាយកលេខាធិការដ្ឋានក្រុមការងារពិសេសសិទ្ធិលំនៅដ្ឋានទទួលការគំរាមកំហែងពីក្រុមនិស្សិត ដែលជាប់ពាក់ព័ន្ធរាជរដ្ឋាភិបាល។ ក្រុមនេះបានព្រមានដល់លោក សៀ ភារម្យ ឬបុគ្គលិកសង្គមស៊ីវិលផ្សេងៗទៀត ដែលនៅតែបន្តទិតៀនកម្មវិធីនេះពួកគេនឹងពុំអាចធានាបាននូវប្រតិកម្មដោយសន្តិវិធីពីសំណាក់ក្រុមយុវជនស្ម័គ្រចិត្តទេ។ ទោះជាយ៉ាងនេះក្តីពុំមានករណីប្រើប្រាស់អំពើហិង្សាណាមួយកើតឡើងឡើយ។

នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០១៣ លោកនាយករដ្ឋមន្ត្រីបានប្រកាសថា ដំណាក់កាលទីពីរនៃកម្មវិធីនឹងបញ្ចប់ក្នុងខែមិថុនា ឆ្នាំ២០១៣ ពោលគឺមួយខែមុនការបោះឆ្នោតជាទូទៅ។

## គ. កិច្ចសហប្រតិបត្តិការជាមួយអង្គការសង្គមស៊ីវិល និងអង្គការដៃគូ

ក្នុងឆ្នាំ២០១២ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា(CHRC) បានព្រមព្រៀងបង្កើនកម្រិតកិច្ចសហប្រតិបត្តិការរបស់ខ្លួនជាមួយសមាគមអាដហុក និងអង្គការដៃគូផ្សេងទៀត តាមរយៈកម្មវិធីកសាងសមត្ថភាព និងការស៊ើបអង្កេតរួមគ្នាមួយទៅលើករណីនៃការរំលោភបំពានសិទ្ធិមនុស្ស រួមទាំងករណីពាក់ព័ន្ធនឹងដីធ្លី។ ក្នុងខែមិថុនាបុគ្គលិកសមាគមអាដហុករួមគ្នានឹង ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា(OHCHR) និង ក្រុមមេធាវីសំរឹទ្ធ បានផ្តល់វគ្គបណ្តុះបណ្តាលមួយស្តីពី "ការវិភាគការត្រួតពិនិត្យ ការវាយតម្លៃនិងការធ្វើសេចក្តីរាយការណ៍អំពីករណីសិទ្ធិមនុស្ស ឆ្លុះទៅរកដំណោះស្រាយ" ទៅដល់បុគ្គលិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ព្រឹទ្ធសភា រដ្ឋសភា អង្គភាពប្រឆាំងអំពើពុករលួយ និងអង្គភាពប្រឆាំងអំពើភេរវកម្ម។ នៅចន្លោះពីខែសីហា ឆ្នាំ២០១២ និង ខែមករា ឆ្នាំ២០១៣ ករណីដីធ្លីចំនួនបី (រួមទាំងករណីនៅភូមិវល្លិព្រេង សូមខាងលើ) ត្រូវបានស៊ើបអង្កេតរួមគ្នា តាមរយៈការចុះផ្ទាល់ទៅមូលដ្ឋាន។ សមាគមអាដហុកស្វាគមន៍យ៉ាងកក់ក្តៅចំពោះកិច្ចសហប្រតិបត្តិការបែបនេះ ក៏ដូចជាការពង្រីកឲ្យបានពេញឆ្នាំ២០១៣។

## សេចក្តីសន្និដ្ឋាន

*គំនិតផ្តួចផ្តើមរបស់អង្គនីតិប្រតិបត្តិ ដែលមានគោលបំណងផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់ គ្រួសារនៅទីជនបទ និងការពារដីធ្លីរបស់ពួកគេពីការទន្ទ្រានយកដី គឺជាការស្វាគមន៍ ប៉ុន្តែនៅពុំទាន់បានគ្រប់គ្រាន់នៅឡើយ។ គំនិតផ្តួចផ្តើមទាំងនេះពុំដោះស្រាយនូវតម្រូវការរបស់ប្រជាពលរដ្ឋ និងសហគមន៍ដែលត្រូវការប័ណ្ណកម្មសិទ្ធិដីជាចាំបាច់នោះទេ។ ជាមួយនឹងជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសអន្តរជាតិគ្រប់គ្រាន់ រាជរដ្ឋាភិបាលនឹងពុំមានលេសអ្វីទៀតទេ ប្រសិនបើខ្លួន*

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ឆ្នាំ២០១២ អាចជាផ្លូវរបត់សម្រាប់សិទ្ធិដីធ្លី និងលំនៅដ្ឋាននៅប្រទេសកម្ពុជា។ គំនិត ផ្តួចផ្តើមថ្មីៗរបស់រាជរដ្ឋាភិបាលបង្ហាញនូវការទទួលស្គាល់ថា មានអ្វីម៉្យាងដូចជាខុសឆ្គងនិងថាវិបត្តិ ដីធ្លី បានចាប់ផ្តើមគំរាមកំហែងដល់ស្ថេរភាពប្រទេសជាតិ។ ប៉ុន្តែបើទោះជាអាជ្ញាធរ បានយល់ពី ភាពធ្ងន់ធ្ងរនៃស្ថានភាពយ៉ាងណាក្តី ក៏ការទន្ទ្រានលើធនធានធម្មជាតិ និងធនធានចិញ្ចឹមជីវិត នៅតែបន្តកើតមានមិនស្រាកស្រាន ហើយគោលនយោបាយ ដែលជាដើមចមនៃភាពរំជើបរំជួល ក៏នៅតែបន្តកើតមានដែរ។ គម្រោងនានាដែលមានបំណងផ្តល់អានុភាពដល់ច្បាប់ភូមិបាល និងបទប្បញ្ញត្តិផ្សេងៗ ដូចជា គម្រោងរដ្ឋបាលនិងគ្រប់គ្រងដីធ្លី(LMAP) និងក្រោយមកទៀត កម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី(LASSP) បានខកខានក្នុងការផ្តល់សន្តិសុខនៃការកាន់កាប់ដល់គ្រួសារដែលងាយរងគ្រោះបំផុត និងដើម្បីដោះស្រាយ "និន្នាការអំណាចមិនយុត្តិធម៌ [...] បណ្តាលឲ្យមានការ ទាត់ចោលនូវក្រុមពលរដ្ឋ ដែលត្រូវបានគេផាត់ចេញ ការចាក់ឫសដ៏ជ្រៅនៃប្រព័ន្ធបំពានអំណាច និងការរួមចំណែកដល់ការបែងចែកគ្មានសមធម៌នូវបន្ទុក និងអត្ថប្រយោជន៍នៃការអភិវឌ្ឍន៍"[៥១]។ ចំណែកដ៏ធំ នៃប្រជាពលរដ្ឋកម្ពុជារាប់បញ្ចូលទាំងកសិករគ្មានដីធ្លី អ្នកតាំងលំនៅដ្ឋានក្រៅផ្លូវការនៅតាមទីប្រជុំ ជន និងជនជាតិដើមភាគតិច បច្ចុប្បន្នកំពុងតែស្ថិតក្នុងស្ថានភាពគ្មានអ្វីទាំងអស់។

ក្នុងប៉ុន្មានឆ្នាំខាងមុខ កំណើនភាគរយនៃវិវាទដីធ្លីនឹងទំនងជាពាក់ព័ន្ធនឹងការទន្ទ្រានយក ដីធ្លីក្នុងតំបន់ជនបទ និងតំបន់ទីក្រុងផងដែរ។ បច្ចុប្បន្ន សម្បទានដីសេដ្ឋកិច្ចគ្របដណ្តប់លើភាគរយ ដ៏ធំនៃដីដាំដុះរបស់ប្រទេសកម្ពុជា ដូច្នេះហើយរាជរដ្ឋាភិបាល នឹងពុំអាចបន្តផ្តល់សម្បទានបានច្រើនទៀតដូចក្នុងឆ្នាំមុនៗបានទេ។ សម្បទានដីសេដ្ឋកិច្ចថ្មីអាចនឹងត្រូវយកចេញពីតំបន់ការពារ កោះ ឬសម្បទានដែលបានលុបចោល ប៉ុន្តែវិវាទ នឹងមានចំនួនតិចតួចជាងមុនដែលជាប់ពាក់ព័ន្ធនឹងសម្បទានថ្មីៗទាំងនេះ។ ផ្ទុយទៅវិញ វិវាទពាក់ព័ន្ធនឹងការទន្ទ្រានយកដីដោយក្រុមហ៊ុនឯកជន និងអ្នកមានអំណាច ទំនងបន្តនៅតែមានដោយសារតែសេចក្តីលោភលន់ និងនិទណ្ឌភាព។ ក្នុងទីក្រុង តំបន់តាំងលំនៅដ្ឋានក្រៅផ្លូវការជាច្រើន ទំនងនឹងត្រូវបានរុះរើ ដើម្បីបើកផ្លូវឲ្យគម្រោងអភិវឌ្ឍន៍។ នៅទីជនបទវិវាទថ្មីៗអាចផ្ទុះឡើង និងវិវាទដែលកំពុងកើតមានស្រាប់ជាច្រើនអាចនឹងកាន់តែមានលក្ខណៈធ្ងន់ធ្ងរដោយសារតែកង្វះខាតនៃដំណោះស្រាយគួរឲ្យពេញចិត្ត។

អ្វីដែលត្រូវការជាចាំបាច់ជាងគេ បច្ចុប្បន្នបន្ថែមលើការពង្រឹងនីតិរដ្ឋ និងការពិនិត្យឡើងវិញនូវគោលនយោបាយអភិវឌ្ឍន៍ នោះគឺការទទួលស្គាល់ថា ការអភិវឌ្ឍរបស់ប្រទេសកម្ពុជាបានដំណើរទៅដោយពុំមានបទប្បញ្ញត្តិ។ ផលប្រយោជន៍អ្នកខ្លាំងបានផ្តល់ជាប្រយោជន៍មិនសមាមាត្រពីការចាត់ចែងដីធ្លី និងគោលនយោបាយ ខណៈដែលសហគមន៍និងពលរដ្ឋដែលត្រូវបានគេផាត់ ចេញ ក៏ដូចជាធនធានធម្មជាតិរបស់ប្រទេសជាតិ បានទទួលបន្ទុកនៃការផ្លាស់ប្តូរ។ តម្លាភាពនៅ មានខ្វះខាតគ្រប់កម្រិតរដ្ឋបាល និងនីវទណ្ឌភាពមានលក្ខណៈរាលដាលជាទូទៅ។

ពុំមែនអ្វីៗគ្រប់យ៉ាង ត្រូវបានអនុញ្ញាតក្រោមឈ្មោះអភិវឌ្ឍន៍នោះទេ។ សមធម៌ ការរាប់ បញ្ចូល និងការការពារផ្នែកសិទ្ធិមនុស្ស គួរជាចំណុចកណ្តាលនៃគោលនយោបាយអភិវឌ្ឍន៍។ រាជរដ្ឋាភិបាល ពុំមែនមានសិទ្ធិផ្តាច់មុខលើនិយមន័យនៃការអភិវឌ្ឍន៍នោះទេ គឺត្រូវអនុញ្ញាតឲ្យមានសំឡេងដ៏សំខាន់ ក្នុងការលើកឡើងអំពីក្តីបារម្ភអំពីគម្រោងអភិវឌ្ឍន៍ និងអានុភាពអវិជ្ជមានរបស់វាទៅលើក្រុមប្រជាពលរដ្ឋដែលក្រីក្រស្រាប់ និង ក្រុមប្រជាពលរដ្ឋដែលត្រូវបានគេផាត់ចេញ។ ជម្រើសដែលអាចយកមកជំនួសមានច្រើនដែលអាចអនុវត្តទៅបាន ដូចជាការជួយគាំទ្រដល់ កសិករដែលកាន់កាប់លើដីតូចៗ។

ប្រសិនបើ ពុំមានយុទ្ធសាស្ត្រដ៏ទូលំទូលាយមួយក្នុងការដោះស្រាយបញ្ហារចនាសម្ព័ន្ធ ដូចជាការផាត់ចេញអយុត្តិធម៌ និងការរំលោភបំពានអំណាចនោះទេ នោះគំនិតផ្តួចផ្តើមជាបណ្តោះអាសន្នរបស់រាជរដ្ឋាភិបាល ទាក់ទិននឹងដីធ្លីនិងលំនៅដ្ឋាន នឹងគ្រាន់តែអាចដោះស្រាយបញ្ហាបានសម្រាប់រយៈពេលដ៏ខ្លីតែប៉ុណ្ណោះ។ ដំណាក់កាលទីមួយ

៥១ BABC/អង្គការសមធម៌កម្ពុជានិង Heinrich BöllStiftung យុទ្ធសាស្ត្រសិទ្ធិមនុស្សចំពោះការអភិវឌ្ឍន៍នៃវិស័យដីធ្លីរបស់កម្ពុជា(ឆ្នាំ២០១២)ទំព័រ. lv។ សូមមើលផងដែរទំព័រ២៨-៣១។

ត្រូវតែបំពេញបង្គ្រប់ដោយដំណាក់កាល ទីពីរ (ដែលកាន់តែលំបាក) ពោលគឺការពង្រឹងការអនុវត្តច្បាប់ជាធរមាន និងការបង្កើនសន្តិសុខនៃការកាន់កាប់ *សម្រាប់ទាំងអស់គ្នា* គឺពុំមែនសម្រាប់តែអ្នកដែលរស់នៅក្នុងតំបន់គ្មានវិវាទនោះទេ។ ក្នុងដំណាក់កាលនេះ រាជរដ្ឋាភិបាលត្រូវធ្វើការជ្រើសរើសដ៏ច្បាស់លាស់មួយ។

## អនុសាសន៍

### សមាគមអាដហុកសូមដាក់ជូនអនុសាសន៍ខាងក្រោមដល់រាជរដ្ឋាភិបាលកម្ពុជា៖

### ១. សិទ្ធិដីធ្លីនិងសិទ្ធិលំនៅដ្ឋាន

- អនុម័តសេចក្តីព្រាងនៃគោលនយោបាយលំនៅដ្ឋានថ្នាក់ជាតិ បន្ទាប់ពីច្បាស់លាស់ថាវា ស្របនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ ពាក់ព័ន្ធនឹងបញ្ហានេះដូចបានស្នើសុំដោយអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស សិទ្ធិទទួលបានលំនៅដ្ឋានសមស្របគួរធ្វើការកំណត់ផែនទីនៃតម្រូវការផ្នែកលំនៅដ្ឋានរបស់ប្រទេសជាតិទាំងមូល។
- អនុម័តនូវច្បាប់ស្តីពីការបណ្តេញចេញពីលំនៅដ្ឋានឲ្យស្របគ្នានឹងច្បាប់សិទ្ធិមនុស្សអន្តរ ជាតិ។ ទន្ទឹមនឹងនោះដែរ ដាក់ចេញនូវការផ្អាកបណ្តោះអាសន្នជាផ្លូវការ ស្តីពីការបណ្តេញ ចេញពីលំនៅដ្ឋានក្នុងតំបន់ជនបទនិងទីក្រុង រហូតទាល់តែ ដំណើរការនៃការធ្វើប័ណ្ណកម្ម សិទ្ធិដីធ្លីបានបញ្ចប់។
- អនុវត្តកម្មវិធីធ្វើប័ណ្ណកម្មសិទ្ធិដីធ្លីជាផ្លូវការ និងដោះស្រាយវិវាទដីធ្លី ជាបញ្ហាអាទិភាព។
- ពន្លឿនការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចជានីតិបុគ្គល និងផ្តល់អាទិភាពការចុះ បញ្ជីដីធ្លីរបស់ពួកគេស្របទៅតាមច្បាប់ភូមិបាល។
- ទទួលស្គាល់សិទ្ធិកាន់កាប់របស់ប្រជាពលរដ្ឋ ដែលកំពុងរស់នៅក្នុងតំបន់តាំងលំនៅដ្ឋានក្រៅផ្លូវការ ដោយផ្តល់ការយកចិត្តទុកដាក់ជាពិសេសទៅលើតំបន់តាំងលំនៅដ្ឋានក្រៅផ្លូវ ការនៅទីក្រុង។
- ក្នុងតំបន់តាំងលំនៅដ្ឋានថ្មីសម្រាប់អ្នកដែលត្រូវបានបណ្តេញចេញពីលំនៅដ្ឋាន ត្រូវកសាងហេដ្ឋារចនាសម្ព័ន្ធ អនាម័យ ទឹក និងអគ្គិសនីជាមូលដ្ឋាន និងផ្តល់សេវាសន្តិសុខ សុខភាព និងការអប់រំសាធារណៈ។

### ២. សម្បទានដីសេដ្ឋកិច្ចនិងសម្បទានផ្សេងៗទៀត

- បើកបង្ហាញភ្លាមៗនូវព័ត៌មានអំពីសម្បទានដីសេដ្ឋកិច្ចដែលមានទាំងអស់ ដោយរាប់បញ្ចូលទាំងទីតាំងពិតប្រាកដ ទំហំ ព្រំប្រទល់ រយៈពេល សម្បទានិក គោលបំណងនៃការប្រើប្រាស់ ការវាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គម ដំណើរការប្រឹក្សាយោបល់ និងគម្រោងផ្តល់សំណង។ ធ្វើបច្ចុប្បន្នភាពជាប្រចាំនូវគេហទំព័ររបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពាក់ព័ន្ធនឹងបញ្ហានេះ។
- ផ្តល់អាទិភាពក្នុងការផ្តល់សំណងគ្រប់គ្រាន់ដល់ពលរដ្ឋ ដែលទទួលរងផលប៉ះពាល់ដោយសម្បទានដីសេដ្ឋកិច្ច និងគម្រោងអភិវឌ្ឍន៍ផ្សេងៗទៀត។
- ធ្វើការពិនិត្យឡើងវិញឲ្យបានទូលំទូលាយនូវសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ និងបើកបង្ហាញព័ត៌មានស្តីពីសម្បទានដែលបានលុបចោល សកម្មភាពតាមដានក្រោយពីការលុប ចោល និងចំណូលរដ្ឋបានមកពីសម្បទានដីសេដ្ឋកិច្ច។
- បង្កើនពន្ធអាករលើសម្បទានដីសេដ្ឋកិច្ច ដោយផ្អែកទៅលើផលិតកម្ម និងធ្វើឲ្យទៅជាកាតព្វកិច្ចផ្នែកច្បាប់ សម្រាប់ឲ្យក្រុមហ៊ុនបោះពុម្ពផ្សាយគ្រប់ព័ត៌មានហិរញ្ញវត្ថុទាំងអស់ ដែលពាក់ព័ន្ធនឹងសម្បទានដីរបស់ពួកគេ។
- ដាក់ពិន័យដល់ក្រុមហ៊ុនដែលពុំអនុវត្តតាមលក្ខខណ្ឌតម្រូវក្នុងកិច្ចសន្យា និងច្បាប់ ដោយដកហូតសម្បទានរបស់ពួកគេនិងចាត់វិធានការផ្លូវច្បាប់ប្រឆាំងនឹងពួកគេ។
- កាត់បន្ថយទំហំសម្បទានដែលមានផ្ទៃដីលើសពីការកម្រិតត្រឹម ១០,000ហិកតា និងដីដែល ប្រើ

ប្រាស់មិនស្របតាមលក្ខណៈលើកលែងដូចបានកំណត់ក្នុងច្បាប់។

- ពន្លាតការផ្អាកបណ្តោះអាសន្នជាផ្លូវការស្តីពីការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មី និងបើក បង្ហាញជាផ្លូវការអំពីចំនួនគម្រោងសម្បទានដីសេដ្ឋកិច្ច ដែលត្រូវបានរៀបចំស្នើសុំនៅត្រឹម ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ (អមដោយភស្តុតាង)។
- ត្រួតពិនិត្យយ៉ាងដិតដល់ចំពោះសម្បទានដីសង្គមកិច្ច និងស៊ើបអង្កេតការចោទប្រកាន់អំពីការរំលោភបំពាន អំពើពុករលួយ និងការគ្រប់គ្រងមិនត្រឹមត្រូវពាក់ព័ន្ធនឹងសម្បទានដី សង្គមកិច្ច។

### ៣. ធនធានធម្មជាតិ

- កំណត់ព្រំប្រទល់ និង ផ្សព្វផ្សាយ ព័ត៌មាន អំពីតំបន់ការពារ និងតំបន់ផ្ទៃក្នុងរបស់តំបន់ការពារទាំងនោះ។ ស្វែងរកជំនួយបច្ចេកទេស ពីដៃគូអភិវឌ្ឍន៍ ដើម្បីបញ្ចប់ការផ្តល់សម្បទានដី សេដ្ឋកិច្ច និងសកម្មភាពដ៏គ្រោះថ្នាក់ផ្សេងៗទៀត ក្នុងតំបន់ដែលបំពេញលក្ខណៈវិនិច្ឆ័យនៃតំបន់ «ស្នូល» និងតំបន់ «អភិរក្ស»។
- ផ្តល់អាទិភាពដល់ការអភិរក្សព្រៃឈើបឋមនិងបៃតងជានិច្ច និងពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងបរិស្ថាន។
- វាយតម្លៃ ជាលក្ខណៈប្រព័ន្ធនូវផលប៉ះពាល់ផ្នែកបរិស្ថាននៃគម្រោងអភិវឌ្ឍន៍ធំៗដូចជា ទំនប់ទឹក និងសម្បទានដី មុននឹងការអនុវត្តគម្រោងទាំងនេះ និងវាយតម្លៃឡើងវិញនូវផល ប៉ះពាល់របស់គម្រោងទាំងនេះបន្ទាប់ពីចាប់ផ្តើមអនុវត្តគម្រោងទាំងនេះ។
- ដាក់ពិន័យដល់មន្ត្រីរដ្ឋបាលមូលដ្ឋាន និងមន្ត្រីព្រៃឈើ ដែលជាប់ពាក់ព័ន្ធក្នុងការកាប់ឈើដោយខុសច្បាប់ និងបទល្មើសផ្សេងៗទៀត អនុលោមតាមមាត្រា១០០ និង១០១នៃច្បាប់ ស្តីពីព្រៃឈើ។

### ៤. ដំណោះស្រាយវិវាទ

- ផ្តល់អាទិភាពដល់ការដោះស្រាយវិវាទដីធ្លី និងផ្តល់ឲ្យយន្តការ និង ស្ថាប័នដោះស្រាយវិវាទនូវធនធានស្ថាប័ន ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុគ្រប់គ្រាន់។
- ពង្រឹងគណៈកម្មការសុរិយោដីនៅគ្រប់កម្រិត និងគូសបញ្ជាក់ក្របខណ្ឌផ្លូវច្បាប់និង ស្ថាប័នរបស់អាជ្ញាធរជាតិសម្រាប់ការដោះស្រាយវិវាទដីធ្លី។
- អនុម័តច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញាក៏ដូចជា ច្បាប់ស្តីពីការរៀបចំ និងការ ប្រព្រឹត្តិទៅនៃតុលាការ ជាបញ្ហាអាទិភាពសម្រាប់ត្រួតពិនិត្យលើតុលាការ និងដាក់ពិន័យមន្ត្រីរាជការ និងអ្នកដែលរកឃើញថា មានការកេងបំបាត់លុយកាក់ ឬប្រព្រឹត្តកំហុសវិជ្ជាជីវៈ។
- បន្តស៊ើបអង្កេតរួមគ្នាក្នុងករណីដីធ្លី ជាមួយនឹងអង្គការសង្គមស៊ីវិល។

### ៥. នីតិរដ្ឋនិងសេរីភាពបែបប្រជាធិបតេយ្យ

- ឈប់បង្ក្រាបលើការតវ៉ាប្រកបដោយសន្តិវិធីរបស់សហគមន៍ ដែលទទួលរងប៉ះពាល់ដោយការរំលោភបំពានសិទ្ធិដីធ្លី និងលំនៅដ្ឋាន។
- ឈប់បៀតបៀនដោយប្រើប្រាស់ប្រព័ន្ធតុលាការទៅលើតំណាងសហគមន៍ បុគ្គលិកសិទ្ធិមនុស្ស និងសកម្មជន។
- ផ្តល់អាជ្ញាធរមូលដ្ឋាននិងរដ្ឋនូវការបណ្តុះបណ្តាលអំពីច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី ពិសេសមាត្រា៣ ដែលលើកលែងចំពោះអ្នករៀបចំការប្រជុំពីការតម្រូវឲ្យផ្តល់សេចក្តីជូន ដំណឹងសម្រាប់គ្រប់សកម្មភាពផ្សព្វផ្សាយអប់រំជាផលប្រយោជន៍សង្គម។
- ឈប់ផ្តល់ការការពារដោយកងកម្លាំងប្រដាប់អាវុធខេមរភូមិន្ទ ដល់ក្រុមហ៊ុនឯកជន និងសម្បទានិក។ ធ្វើការស៊ើបអង្កេតប្រកបដោយខ្លឹមសារទៅលើការចោទប្រកាន់ អំពីការរំលោភបំពានប្រព្រឹត្តដោយកងកម្លាំងប្រដាប់អាវុធ។
- បញ្ចប់ប្រព័ន្ធ «ឧបត្ថម្ភ» ដែលបុគ្គលដែលមានអំណាចផ្តល់មូលនិធិដល់អង្គភាពកងកម្លាំងប្រដាប់អាវុធខេមរភូមិន្ទ។

### ៦. យុទ្ធសាស្ត្រនិងគោលនយោបាយអភិវឌ្ឍន៍

- បង្កើនការជួយឧបត្ថម្ភដល់ការធ្វើកសិកម្មរបស់កសិករកាន់កាប់ដីខ្នាតតូច ជាយុទ្ធសាស្ត្រអភិវឌ្ឍន៍ដែលយកមកអនុវត្តបាន និងបើកឲ្យមានការប្រឹក្សាយោបល់ទូលំទូលាយស្តីពីគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍និងផលប៉ះពាល់របស់វាទៅលើសិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាននិងសិទ្ធិធនធានធម្មជាតិ។
- ស្វែងរកជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ ដើម្បីរៀបចំការវាយតម្លៃទូលំទូលាយមួយអំពីគោលនយោបាយអភិវឌ្ឍន៍ ដោយពិនិត្យទៅលើទិដ្ឋភាពផ្នែកសេដ្ឋកិច្ចនយោបាយ និងអានុភាពអវិជ្ជមានរបស់វា។
- ធ្វើការគោរពអញ្ជើញអ្នកកាន់អាណត្តិនីតិវិធីពិសេសរបស់អង្គការសហប្រជាជាតិ ដែលបាន ស្នើសុំមកទស្សនកិច្ចនៅកម្ពុជា ពិសេសគឺ អ្នករាយការណ៍ពិសេស ទទួលបន្ទុកផ្នែកឯករាជ្យ ភាពចៅក្រមនិងមេធាវី និង អ្នករាយការណ៍ពិសេស ទទួលបន្ទុកផ្នែកសិទ្ធិទទួលបាន សេរីភាពនៃការប្រជុំដោយសន្តិវិធី និងសមាគម និងអញ្ជើញដល់គ្រប់នីតិវិធីពិសេសទាំងអស់។
- ធ្វើសហប្រតិបត្តិការពេញលេញ ជាមួយស្ថាប័នសន្ធិសញ្ញាអង្គការសហប្រជាជាតិ ដើម្បីអនុវត្តអនុសាសន៍ដែលបានដាក់ជូនប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៣មក ក៏ដូចជា ក្រុម ប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិដើម្បីអនុវត្តអនុសាសន៍ ដែលបានដាក់ជូនក្នុងក្របខណ្ឌនៃដំណើរការពិនិត្យឡើងវិញជាសកល។

### សមាគមអាដហុកសូមដាក់ជូនអនុសាសន៍ខាងក្រោមទៅសហគ្រាសអាជីវកម្មះ

- នៅពេលធ្វើសកម្មភាពអាជីវកម្ម សូមយកចិត្តទុកដាក់ឲ្យបានសមស្របនិងកំណត់ បង្ការ និងសម្រាលផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្សស្រប នឹងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្សនិងធុរកិច្ច។
- ប្រើប្រាស់សម្បទានឲ្យស្របទៅតាមលក្ខខណ្ឌតម្រូវតាមកិច្ចសន្យានិងច្បាប់។ ពិសេស សូមកុំបណ្តាលឲ្យមានការអន់ថយគុណភាពដី និងការឈូសឆាយព្រៃ។ សូមកុំចូលរួមកាប់ ឈើដោយខុសច្បាប់ក្នុងព្រៃ។
- សូមកុំចាប់ផ្តើមប្រតិបត្តិការ មុននឹងទទួលបានការបញ្ជាក់ជាផ្លូវការ (តាមរយៈអនុក្រឹត្យ) ដែលសម្បទានត្រូវបានផ្តល់ឲ្យ។ សូមកុំប្រើប្រាស់សេចក្តីជូនដំណឹងមិនផ្លូវការពីអាជ្ញាធររដ្ឋ ធ្វើជាលេស ដើម្បីចាប់ផ្តើមឈូសឆាយដីដាំដុះរបស់ប្រជាពលរដ្ឋ។
- គោរពសិទ្ធិរបស់ពលរដ្ឋរស់នៅក្នុងតំបន់ និងចូលរួមក្នុងការប្រឹក្សាយោបល់នៅគ្រប់ពេលទាំងអស់និងអំពីគ្រប់បញ្ហា ដែលបម្រើឲ្យផលប្រយោជន៍ពួកគេ។

### ចុងក្រោយសមាគមអាដហុកសូមដាក់ជូនដល់ដៃគូអភិវឌ្ឍន៍ទាំងអស់របស់ប្រទេសកម្ពុជានូវអនុសាសន៍ដូចខាងក្រោមះ

- វាយតម្លៃអំពីប្រសិទ្ធភាពរបស់កម្មវិធី និងគម្រោងជំនួយនានាដែលបានផ្តល់ជូនដល់វិស័យដីធ្លីរបស់ប្រទេសកម្ពុជា ដោយផ្តោតទៅលើការពង្រឹងសន្តិសុខនៃការកាន់កាប់ដីធ្លីសម្រាប់ទាំងអស់គ្នាជំនួសពឹងផ្អែកទៅលើទិន្នន័យបែបបរិមាណ (ចំនួនប័ណ្ណកម្មសិទ្ធិដីដែលត្រូវបានផ្តល់ជូន)។
- ស៊ើបអង្កេតការចោទប្រកាន់អំពីការរំលោភបំពានដែលបានប្រព្រឹត្ត ពាក់ព័ន្ធនឹងកម្មវិធីជំនួយអភិវឌ្ឍន៍និងព្យជំនួយផ្នែកហិរញ្ញវត្ថុ ក្នុងករណីមានភស្តុតាងបង្ហាញអំពីបទល្មើសអនុវត្តដោយអាជ្ញាធរកម្ពុជា។
- ពិចារណាដកជំនួយដល់វិស័យដីធ្លី ប្រសិនបើ អាជ្ញាធរពុំបង្ហាញនូវឆន្ទៈនយោបាយច្បាស់លាស់ ក្នុងការផ្តល់អាទិភាពដល់តម្រូវការរបស់ប្រជាពលរដ្ឋ និងសហគមន៍ ដែលត្រូវការបំផុតនូវប័ណ្ណកម្មសិទ្ធិដី ក្នុងនោះរាប់បញ្ចូលទាំងអ្នកតាំងលំនៅដ្ឋានក្រៅផ្លូវការ និងជនជាតិដើមភាគតិចផង។
- បន្តប្រឹក្សាយោបល់ជាមួយអង្គការសង្គមស៊ីវិលដែលធ្វើការក្នុងវិស័យបញ្ហាធនធានធម្មជាតិ លំនៅដ្ឋាន និងដីធ្លី។

# ឧបសម្ព័ន្ធ

| ១. សម្បទានដីសេដ្ឋកិច្ច ដែលផ្តល់ឲ្យក្នុងតំបន់ការពារ | | | | | |
|---|---|---|---|---|---|
| | តំបន់ការពារ | ផ្ទៃដីដើមតាមព្រះរាជក្រឹត្យឆ្នាំ១៩៩៣ (ហិកតា) | សម្បទានដីសេដ្ឋកិច្ច ២០០៨-២០១១ (ហិកតា) | សម្បទានដីសេដ្ឋកិច្ច ២០១២ (ហិកតា) | ផ្ទៃដីនៅសេសសល់ (ហិកតា) |
| ១ | ឧទ្យានជាតិវីរៈជ័យ | ៣៣២,៥០០ | ១០៨,៥១៣ | 0 | ២២៣,៩៨៧ |
| ២ | ដែនជម្រកសត្វព្រៃគូលេនព្រហ្មទេព | ៤០២,៥០០ | ៧៩,៣៤៩ | ១២៦,៧៩៦ | ១៩៦,៣៥៥ |
| ៣ | ឧទ្យានជាតិបុទុមសាគរ | ១៧១,២៥០ | ៨៤,០៧៤ | 0 | ៨៧,១៧៦ |
| ៤ | ឧទ្យានជាតិបូកគោ | ១៤០,០០០ | ៤០,៧០៤ | 0 | ៩៩,២៩៦ |
| ៥ | ឧទ្យានជាតិរាម | ១៥០,០០០ | ៩,៩១៥ | 0 | ១៤០,០៨៥ |
| ៦ | ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ | ២៥៣,៧៥០ | ៧៨,២០៨ | ២,៨០០ | ១៧២,៧៤២ |
| ៧ | ដែនជម្រកសត្វព្រៃពាមក្រសោប | ២៣,៧៥០ | ២៥,៨៩៧ * | 0 | 0 * |
| ៨ | ដែនជម្រកសត្វព្រៃភ្នំសំកុស | ៣៣៣,៧៤០ | ១៦,៦២២ | 0 | ៣១៧,១១៨ |
| ៩ | ដែនជម្រកសត្វព្រៃរនាមដូនសំ | ១៧៨,៧៥០ | ៨,១៩០ | ៩,១១៤ | ១៦១,៤៤៦ |
| ១០ | ដែនជម្រកសត្វព្រៃបឹងពែរ | ២៤២,៥០០ | ១១២,៦៣១ | 0 | ១២៩,៨៦៩ |
| ១១ | ដែនជម្រកសត្វព្រៃលំផាត់ | ២៥០,០០០ | ៦៧,២៨៧ | ២៧,១៧៣ | ១៥៥,៥៤០ |
| ១២ | ដែនជម្រកសត្វព្រៃភ្នំព្រេច | ២២២,៥០០ | ២៩,០០៩ | ២៩,០៧២ | ១៦៤,៤១៩ |
| ១៣ | ដែនជម្រកសត្វព្រៃភ្នំណាមលៀរ | ៤៧,៥០០ | ៩,៥៤៦ | ២៥,៥១៣ | ១២,៤៤១ |
| ១៤ | ដែនជម្រកសត្វព្រៃស្នួល | ៧៥,០០០ | ១២៦,០២៧ * | 0 | 0 * |

| | | | | | |
|---|---|---|---|---|---|
| ១៥ | តំបន់ការពារទេសភាពបន្ទាយឆ្មារ | ៨១,២០០ | ៩,០០០ | ០ | ៧២,២០០ |
| ១៦ | តំបន់ការពារទេសភាពព្រះវិហារ | ៥,០០០ | ៥១,២៦៨ * | ០ | ០ * |
| ១៧ | ឧទ្យានជាតិគីរីរម្យ | ៣៥,០០០ | ១,៤៩៤ | ៥១,៨០៨ * | ០ * |
| ១៨ | តំបន់ដែលទទួលរងនូវការប្រើប្រាស់ច្រើនមុខដងពែង | ២៧,៧០០ | ០ | ៣២១ | ២៧,៣៧៩ |
| | **សរុប** | | | **២៧២,៥៩៧** * | |

*ដែនជម្រកសត្វព្រៃពាមក្រសោប, ដែនជម្រកសត្វព្រៃស្នួល, តំបន់ការពារទេសភាពព្រះវិហារ និងឧទ្យានជាតិគីរីរម្យត្រូវបានបំបាត់ដានមិនឲ្យឃើញនឹងភ្នែកដោយសម្បទានដីសេដ្ឋកិច្ច។ នៅពេលផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មី (ឬកំណត់ចំណាត់ថ្នាក់ដីឡើងវិញ) ក្នុងតំបន់ការពារទាំងនេះចាប់តាំងពីឆ្នាំ២០០៨-២០១១ និងក្នុងឆ្នាំ២០១២រដ្ឋាភិបាលហាក់ដូចជាបរាជ័យពុំបានវាយតម្លៃថាតើនៅសេសសល់ប៉ុន្មានហិកតាទៀតទេ។ ជាលទ្ធផលចំនួនហិកតាដែលត្រូវបានផ្តល់ជាសម្បទានដីសេដ្ឋកិច្ច (ឬត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញជាដីរដ្ឋឯកជន) គឺមានទំហំលើសពីផ្ទៃដីជាផ្លូវការរបស់តំបន់ការពារទាំងនេះ។ បុព្វហេតុអាចថាសម្បទានមួយចំនួនជាន់លើគ្នាឬថាតំបន់ការពារទាំងនេះត្រូវបានរាប់បញ្ចូលក្នុងសម្បទានដីសេដ្ឋកិច្ចធំៗ (ដែលប៉ះពាល់ផងដែរទៅលើតំបន់ដែលមិនមែនជាតំបន់ការពារ)។

សមាគមអាដហុកបានជ្រើសរើសផ្តល់តួលេខរួមមួយសម្រាប់ឆ្នាំ២០១២ (២៧២,៥៩៧ហិកតា)។ យ៉ាងណាមិញយើងអាចនឹងដក១៨,៣០២ហិកតា [៥១,៨០៨ + ១,៤៩៤ - ៣៥,០០០] ចេញពីតួលេខសរុបនេះដោយសារអតិបរមានៃដី៣៥,០០០ ហិកតាអាចត្រូវបានផ្តល់ឲ្យជាសម្បទានដីសេដ្ឋកិច្ចក្នុងឧទ្យានជាតិគីរីរម្យ។ តួលេខសរុបដូចបានលើកឡើងខាងលើនឹងទៅជាមានចំនួន២៥៤,២៩៥ហិកតា។ ហេតុផលដូចគ្នាត្រូវបានអនុវត្តចំពោះតំបន់ការងារបីផ្សេងទៀត(ដែនជម្រកសត្វព្រៃពាមក្រសោប, ដែនជម្រកសត្វព្រៃស្នួលនិងតំបន់ការពារទេសភាពព្រះវិហារ)ដូច្នេះផ្ទៃដី៩៩,៤៤២ហិកតា [(២៥,៨៩៧ - ២៣,៧៥០)+(១២៦,០២៧ - ៧៥,០០០) + (៥១,២៦៨ - ៥,០០០)] នឹងត្រូវបានកាត់ចេញពីចំនួនសរុបគិតជាហិកតា ដែលផ្តល់ឲ្យជាសម្បទានដីសេដ្ឋកិច្ចក្នុងតំបន់ការពារ។

ជាថ្មីម្តងទៀតតួលេខដែលយើងផ្តល់ក្នុងរបាយការណ៍នេះគឺផ្អែកទៅលើឯកសារជាផ្លូវការ (អនុក្រឹត្យ)។ ភាពមិនស្របគ្នានឹងស្ថានភាពជាក់ស្តែង និងព័ត៌មានជាផ្លូវការស្តីពីតំបន់ការពារគឺដោយសារតែកង្វះខាតនូវតម្លាភាពជុំវិញដំណើរការនិងគោលនយោបាយពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ចប៉ុណ្ណោះ។

## ២. សម្បទានដីសេដ្ឋកិច្ច ដែលបានផ្តល់ឲ្យ ក្រោយថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២

| | អនុក្រឹត្យលេខ | កាលបរិច្ឆេទ | សម្បទានិក | រយៈពេល (ឆ្នាំ) | ទំហំ (ហិកតា) | គោលបំណង | តំបន់ | ខេត្ត |
|---|---|---|---|---|---|---|---|---|
| ១ | ៧០ | ១៧/០៥/២០១២ | មិនដឹង | មិនដឹង | ៩,០១៨ | ដំណាំកៅស៊ូ | កោះញែក | មណ្ឌលគិរី |
| ២ | ៧១ | ១៨/០៥/២០១២ | S.K. Plantation (Cambodia) PTE | មិនដឹង | ៨,០០០ | ដំណាំកៅស៊ូ | កូនមុំ | រតនគិរី |
| ៣ | ៧២ | ១៨/០៥/២០១២ | Ly Ye Rubber Co. Ltd. | មិនដឹង | ៧,៧១០ | ដំណាំកៅស៊ូ & កសិឧស្សាហកម្ម | តាសៀម | សៀមរាប |
| ៤ | ៧៣ | ១៨/០៥/២០១២ | H.M.H. Kampong Thom | មិនដឹង | ៥,៩១៤ | ដំណាំកៅស៊ូ | សន្ទុក | កំពង់ធំ |
| ៥ | ៧៤ | ០៦/០៦/២០១២ | KhunSeu Import Export | ៧០ | ៨,២០០ | ដំណាំកៅស៊ូ & កសិឧស្សាហកម្ម | គូលេន ព្រហ្មទេព | ឧត្តរមានជ័យ |
| ៦ | ៧៩ | ០៧/០៦/២០១២ | Lim Royal Joint Stock | ៧០ | ៩,០៦៨ | កសិឧស្សាហកម្ម | ភ្នំព្រិច | មណ្ឌលគិរី |
| ៧ | ៨០ | ០៧/០៦/២០១២ | Roat So Khorn | ៧០ | ៩,០០០ | ដំណាំកៅស៊ូ & កសិឧស្សាហកម្ម | លំផាត់ | រតនគិរី |
| ៨ | ៨១ | ០៧/០៦/២០១២ | A.2.A. ក្រុង (Cambodia) Co. Ltd. | ៧០ | ៧,៦៦៨ | អភិវឌ្ឍន៍ | គីរីរម្យ | កំពង់ស្ពឺ កំពង់ស្ពឺ |
| ៩ | ៨២ | ០៧/០៦/២០១២ | មិនដឹង | មិនដឹង | ៩,១២៩ | កសិឧស្សាហកម្ម | គូលេន ព្រហ្មទេព | ព្រះវិហារ |
| ១០ | ៨៣ | ០៧/០៦/២០១២ | មិនដឹង | មិនដឹង | ១,៨៦៥ | ដំណាំកៅស៊ូ & កសិឧស្សាហកម្ម | គូលេន ព្រហ្មទេព | ឧត្តរមានជ័យ |
| ១១ | ៨៤ | ០៧/០៦/២០១២ | មិនដឹង | មិនដឹង | ១,១៩៥ | ដំណាំកៅស៊ូ & កសិឧស្សាហកម្ម | គូលេន ព្រហ្មទេព | ឧត្តរមានជ័យ |
| ១២ | ៨៥ | ០៧/០៦/២០១២ | មិនដឹង | មិនដឹង | ៩,៤៧៧ | កសិឧស្សាហកម្ម | ភ្នំណាម លៀរ | មណ្ឌលគិរី |
| ១៣ | ៨៦ | ០៧/០៦/២០១២ | មិនដឹង | មិនដឹង | ៤,០៩៥ | ដំណាំកៅស៊ូ & កសិឧស្សាហកម្ម | គូលេន ព្រហ្មទេព | ព្រះវិហារ |
| ១៤ | ៨៧ | ០៧/០៦/២០១២ | មិនដឹង | មិនដឹង | ៩,៧០០ | កសិឧស្សាហកម្ម | គូលេន ព្រហ្មទេព | ព្រះវិហារ |
| ១៥ | ៩០ | ១២/០៦/២០១២ | BSC Import Export Co. Ltd. | ៧០ | ៤,៥៥៧ | កសិឧស្សាហកម្ម | រនាមដូនសំ | បាត់ដំបង បាត់ដំបង |

## ២. សម្បទានដីសេដ្ឋកិច្ច ដែលបានផ្តល់ឲ្យ ក្រោយថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២

| | អនុក្រឹត្យលេខ | កាលបរិច្ឆេទ | សម្បទានិក | រយៈពេល (ឆ្នាំ) | ទំហំ (ហិកតា) | គោលបំណង | តំបន់ | ខេត្ត |
|---|---|---|---|---|---|---|---|---|
| ១៦ | ៩១ | ១៤/០៦/២០១២ | L.K.L. Construction Co. Ltd. | ៧០ | ៥,៥៥៩ | កសិឧស្សាហកម្ម | ភ្នំណាម លៀរ | មណ្ឌលគិរី |
| ១៧ | ៩២ | ១២/០៦/២០១២ | Metrey Pheap Kase Usahakam | ៧០ | ៨,៥២០ | កសិឧស្សាហកម្ម | គូលេន ព្រហ្មទេព | ព្រះវិហារ |
| ១៨ | ១០៣ | ១៦/០៧/២០១២ | មិនដឹង | មិនដឹង | ៧,៦៦៨ | សាលារៀន ( ? ) | គីរីរម្យ | កំពង់ស្ពឺ |
| ១៩ | ១០៤ | ១៦/០៧/២០១២ | មិនដឹង | មិនដឹង | មិនដឹង | ទេសចរណ៍ | កោះក្បាល | កែប |
| ២០ | ១១៥ | ០៣/០៨/២០១២ | Green Choice (Cambodia) Co. Ltd. | មិនដឹង | ៧,៨៦៣ | ដំណាំកៅស៊ូ & កសិឧស្សាហកម្ម | សង្គមថ្មី និងរវៀង | ព្រះវិហារ |
| ២១ | ១១៦ | ០៣/០៨/២០១២ | A Me Nen (Cambodia) Co. Ltd. | មិនដឹង | ៧,៣៥៩ | ដំណាំកៅស៊ូ & កសិឧស្សាហកម្ម | គូលេន | ព្រះវិហារ |
| ២២ | ១១៧ | ០៣/០៨/២០១២ | Distinct Harvest (Cambodia) Co. Ltd. | មិនដឹង | ៧,៩៦០ | ដំណាំកៅស៊ូ & កសិឧស្សាហកម្ម | សង្គមថ្មី និងរវៀង | ព្រះវិហារ |
| ២៣ | ១២៥ | ១៨/០៨/២០១២ | មិនដឹង | មិនដឹង | ៨,២០០ | ដំណាំកៅស៊ូ & កសិឧស្សាហកម្ម | គូលេន ព្រហ្មទេព | ឧត្តរមានជ័យ |
| ២៤ | ១២៦ | ១៧/០៨/២០១២ | មិនដឹង | មិនដឹង | ៨,៥២០ | ដំណាំកៅស៊ូ & កសិឧស្សាហកម្ម | គូលេន ព្រហ្មទេព | ព្រះវិហារ |
| ២៥ | ១២៧ | ១៧/០៨/២០១២ | មិនដឹង | មិនដឹង | ៤,៥៥៧ | កសិឧស្សាហកម្ម | រនាមដូនស | បាត់ដំបង |
| ២៦ | ១៣០ | ២៣/០៨/២០១២ | Angkor Sugar | មិនដឹង | ៦,៣២៨ | ដំណាំអំពៅ | កូនក្រៀល | បាត់ដំបង |
| ២៧ | ១៣១ | ២៣/០៨/២០១២ | Tun Le Sugarcane | មិនដឹង | ៦,១៦៤ | ដំណាំអំពៅ | ចុងកាល់ | ឧត្តរមានជ័យ |
| ២៨ | ១៣២ | ២៣/០៨/២០១២ | Cambodia Cane En Sugar Welly | មិនដឹង | ៥,៩០៨ | ដំណាំអំពៅ | សំរោង | ឧត្តរមានជ័យ |
| ២៩ | ១៣៣ | ២៤/០៨/២០១២ | Rat Sokhorn Inc. | មិនដឹង | ៩,០០០ | ដំណាំកៅស៊ូ & កសិឧស្សាហកម្ម | លំផាត់ | រតនគិរី |

## ២. សម្បទានដីសេដ្ឋកិច្ច ដែលបានផ្តល់ឲ្យ ក្រោយថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២

| | អនុក្រឹត្យលេខ | កាលបរិច្ឆេទ | សម្បទានិក | រយៈពេល (ឆ្នាំ) | ទំហំ (ហិកតា) | គោលបំណង | តំបន់ | ខេត្ត |
|---|---|---|---|---|---|---|---|---|
| ៣០ | ១៣៥ | ០៤/០៩/២០១២ | មិនដឹង | មិនដឹង | មិនដឹង | មិនដឹង | មិនដឹង | មិនដឹង |
| ៣១ | ១៤៩ | ១៤/០៩/២០១២ | HengHeang – SivChanthu Green Sport | មិនដឹង | ៤,000 | ដំណាំកៅស៊ូ | សែន មនោរម្យ, ពេជ្រាដា | មណ្ឌលគិរី |
| ៣២ | ១៥១ | ១៨/០៩/២០១២ | មិនដឹង | មិនដឹង | ៦,000 | ដំណាំកៅស៊ូ& កសិឧស្សាហកម្ម | គូលេន ព្រហ្មទេព | ព្រះវិហារ |
| ៣៣ | ២២០ | ០៣/១២/២០១២ | មិនដឹង | មិនដឹង | ៦០៣ | អភិវឌ្ឍន៍ | រមាសហែក | ស្វាយរៀង |
| | | | **សរុប** [យ៉ាងតិច] * | | **២០៨,៨០៥** | | | |

*សមាគមអាដហុកនឹងបន្តរុករកព័ត៌មានដែលនៅខ្វះចន្លោះ។

# ទីស្នាក់សារសមាគមអាដហុកទូទាំង ២៣ខេត្ត/ក្រុង

### ១ - ភ្នំពេញ ( ទីស្នាក់ការកណ្ដាល )

ផ្ទះលេខ៣ផ្លូវ១៥៨ ( ផ្លូវឧកញ៉ាត្រឹងកាង,សង្កាត់បឹងរាំង, ខណ្ឌដូនពេញ, ប្រអប់សំបុត្រ១០២៤, ភ្នំពេញ, កម្ពុជា
ទូរស័ព្ទ: ០២៣២១៨៦៥៣/០២៣៩៩០ ៥៥៤
ទូរសារ: ០២៣២១៧២២៩
អ៊ីមែល: adhoc@forum.org.kh
គេហទំព័រ: www.adhoc-cambodia.org

### ២ - បន្ទាយមានជ័យ

ផ្ទះលេខ១៩៨, ភូមិ៣, ឃុំពន្លា, ក្រុងសិរីសោភ័ណ, ខេត្តបន្ទាយមានជ័យ
ទូរស័ព្ទ: ០៥៤៩៥៨៨៦៧

### ៣ - បាត់ដំបង

ផ្ទះលេខ៨៥៩, ក្រុមទី១២, ភូមិរំចេក៤, ឃុំរតនៈ, ខេត្តបាត់ដំបង
ទូរស័ព្ទ: ០៥៣៩៥២៨២៩

### ៤ - កំពង់ចាម

ភូមិអំពិលលើ, ឃុំអំពិល, ស្រុកកំពង់សៀម, ខេត្តកំពង់ចាម
ទូរស័ព្ទ: ០៤២៩៤១៣២៦

### ៥ - កំពង់ឆ្នាំង

ផ្ទះលេខA១៦៧, ផ្លូវជាតិលេខ៥, ភូមិកណ្ដាល, ឃុំកំពង់ឆ្នាំង, ខេត្តកំពង់ឆ្នាំង
ទូរស័ព្ទ: ០២៦៩៨៨៧១៦

### ៦ - កំពង់ស្ពឺ

ផ្លូវជាតិលេខ៤, ភូមិពាណិជ្ជកម្ម, ឃុំរកាធំ, ស្រុកច្បារមន, ខេត្តកំពង់ស្ពឺ
ទូរស័ព្ទ: ០២៥៩៨៧២៦៥

### ៧ - កំពង់ធំ

ផ្ទះលេខ១១, ផ្លូវប្រជាធិបតេយ្យ, ក្រុមទី២, ភូមិ៧, ឃុំកំពង់ធំ, ស្រុកស្ទឹងសែន, ខេត្តកំពង់ធំ
ទូរស័ព្ទ: ០៦២៩៦១២៩៥

### ៨ - កំពត

**( ទទួលបន្ទុកខេត្តកែបផងដែរ )**
ផ្ទះលេខ៣០, ផ្លូវ៧មករា, ភូមិកំពង់បាយខាងត្បូង, ឃុំកំពង់បាយ, ខេត្តកំពត

### ៩ - កណ្ដាល

ផ្ទះលេខ២៤១, ផ្លូវជាតិលេខ២, ភូមិក្រពើហា, ឃុំព្រែកឫស្សី, ស្រុកខ្សាច់កណ្ដាល... 

### ១០ - កោះកុង

ផ្ទះលេខ១៨៧, ភូមិ៣, ក្រុងខេមរភូមិន្ទ, ខេត្តកោះកុង
ទូរស័ព្ទ: ០៣៥៩៣៦១២៩

### ១១ - ក្រចេះ

ផ្ទះលេខ២៨៣E០, ផ្លូវព្រះសីហនុ, ក្រុមទី៤, ភូមិវត្ត, ឃុំក្រចេះ, ខេត្តក្រចេះ
ទូរស័ព្ទ: ០៧២៩៧១៥១៥

### ១២ - មណ្ឌលគិរី
ភូមិដោះក្រមុំ, សង្កាត់សុខដុម, ក្រុងសែនមនោរម្យ,
ខេត្តមណ្ឌលគិរី
ទូរស័ព្ទ: ០១៥៤១០ ៤៤៧

### ១៣ - ឧត្តរមានជ័យ
ផ្ទះលេខ៧០, ក្រុមទី៦, ភូមិឈូក, ឃុំសំរោង, ក្រុងសំរោង,
ខេត្តឧត្តរមានជ័យ
ទូរស័ព្ទ: ០១១៧១៣៣២៤

### ១៤ - ប៉ៃលិន
ក្រុមទី១, ភូមិតាពុកលើ, សង្កាត់ប៉ៃលិន, ក្រុងប៉ៃលិន,
ខេត្តប៉ៃលិន
ទូរស័ព្ទ: ០១២៧៨៧៧៧៤

### ១៥ - ព្រះសីហនុ
ផ្ទះលេខ១១៩E១, ផ្លូវបុរីកម្មករ, សង្កាត់លេខ៣, ខណ្ឌមិត្តភាព,
ក្រុងសីហនុ, ខេត្តព្រះសីហនុ
ទូរស័ព្ទ: ០៣៤៩៣៣៧២២

### ១៦ - ព្រះវិហារ
ផ្ទះលេខ៦៩៩, ផ្លូវទី២, ភូមិអណ្តូងពោធិ៍, ឃុំកំពង់ប្រណាក,
ស្រុកត្បែងមានជ័យ, ខេត្តព្រះវិហារ
ទូរស័ព្ទ: ០១២៤៩៥ ០៧៧

### ១៧ - ព្រៃវែង
ផ្ទះលេខ២៨២ឡូលេខ២, ឃុំកំពង់ឡាវ, ក្រុងព្រៃវែង,
ខេត្តព្រៃវែង
ទូរស័ព្ទ: ០៤៣៩៤៤៥២៨

### ១៨ - ពោធិ៍សាត់
ផ្លូវបុំបៀកឡាច (កាច់ជ្រុងផ្លូវជាតិលេខ៥), ភូមិថ្នល់បំបែក,
ឃុំរលាប, ក្រុងពោធិ៍សាត់, ខេត្តពោធិ៍សាត់
ទូរស័ព្ទ: ០៥២៩៥១៥៥២

### ១៩ - រតនគិរី
ភូមិ៣, ឃុំឡាបានសៀក, ស្រុកបានលុង, ខេត្តរតនគិរី
ទូរស័ព្ទ: ០៧៥៩៧៤ ០៧៦

### ២០ - សៀមរាប
ផ្ទះលេខ១១D៤, ភូមិបន្ទាយចាស់, សង្កាត់ស្លក្រាម,
ក្រុងសៀមរាប, ខេត្តសៀមរាប
ទូរស័ព្ទ: ០៦៣៩៦៣៤០២

### ២១ - ស្ទឹងត្រែង
ភូមិត្រពាំងព្រីង, ឃុំស្ទឹងត្រែង, ស្រុកស្ទឹងត្រែង, ខេត្តស្ទឹងត្រែង
ទូរស័ព្ទ: ០៧៤៩៧៣៨៥៣

### ២២ - ស្វាយរៀង
ភូមិកៀនសាំង, ឃុំស្វាយរៀង, ក្រុងស្វាយរៀង, ខេត្តស្វាយរៀង
ទូរស័ព្ទ: ០៤៤៩៤៥៩១០

### ២៣ - តាកែវ
ផ្លូវទី២, ភូមិផ្សារតាកោ, ឃុំរកាក្នុង, ស្រុកដូនកែវ, ខេត្តតាកែវ
ទូរស័ព្ទ: ០៣២៩៣១៣

សមាគមអាដហុក
ADHOC

ឧបត្ថម្ភថវិកាដោយ

សហគមន៍អឺរ៉ុប

Oxfam Novib

CCFD

Oxfam
Oxfam GB in Cambodia

ផ្ទះលេខ៣ ផ្លូវ១៥៨ ឬឧកញ៉ាទ្រឿងកាង សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ/ P.O.BOX : 1024,
ទូរស័ព្ទលេខ: (855-23) 218 653, 990 544, | ទូរសារលេខ: (855-23) 217 229,
E-mail: adhoc@forum.org.kh | Website: www.adhoc-chra.org